# មេរៀនអានាបានស្សតិ

## តាមគោលបដិបត្តិក្នុងព្រះពុទ្ធសាសនា

ចងក្រងដោយ

**ធម្មានន្ទ  វ៉ាន់  ចាន់សារ៉ែន**

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

**ព.ស.២៥៥៦**

**គ.ស.២០១២**

ឈ្មោះសៀវភៅ មេរៀនអានាបានស្សតិ
ចងក្រងដោយ ធម្មានន្ទ វ៉ាន់ ចាន់សាវ៉ែន
កាលបរិច្ឆេទ ២៧ សីហា ព.ស.២៥៥៦
ការផ្សាយរបស់ ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ

រក្សាសិទ្ធិគ្រប់យ៉ាង

www.khmerbuddhist.net

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# បុព្វកថា

អានាបានស្សតិ ជាគោលបដិបត្តិមួយចំណែកក្នុងសតិប្បដ្ឋាន ដែលជាផ្លូវឯកនាំសត្វចេញចាកទុក្ខ ។ សត្វទាំងឡាយ ដែលត្រាច់ចរទៅក្នុងសង្សារវដ្ត ព្រោះមិនបានជួបព្រះធម៌ដែលជាមគ្គញ្ញាណ និងផលញ្ញាណ ក៏ហេតុនាំឲ្យសត្វ មិនដឹងខាងដើមនៃកំណើតនិងចុងបំផុតនៃសង្សារវដ្ត ។ ព្រះពុទ្ធទ្រង់ជាចម្បង បានរកឃើញមោក្ខធម៌ ដែលសត្វលោកបដិបត្តិនឹងនាំឲ្យបានចេញចាកទុក្ខ ។ ព្រះធម៌ដ៏មានជម្រៅដែលយើងត្រូវការមានចំពោះមុខ តែអាស្រ័យអវិជ្ជា តណ្ហា ដឹកមុខធ្វើឲ្យសត្វលោក ឃើញថា ជាគុណជាតដែលមិនមានខ្លឹមសារ ហើយបណ្តោតបណ្តោយពេលវេលា ជ្រុបង៉ុបជាមួយនឹងលោភៈ ទោសៈ និងមោហៈ ហើយចេះតែត្រាច់ទៅក្នុងសង្សារវដ្តពីមួយជាតិ ទៅមួយជាតិទៀត ។ ឥឡូវបានជួបប្រសព្វនឹងព្រះពុទ្ធកំពុងមានក្នុងលោក សូមកុំឲ្យខណៈនេះ កន្លងទៅឥតប្រយោជន៍ឡើយ សូមចាប់ផ្តើមបដិបត្តិនូវព្រះធម៌ ជាបច្ច័យឲ្យបាននូវសន្តិពោលគឺសេចក្តីសុខដ៏ក្រៃលែងក្នុងការរួចផុតចាកទុក្ខទាំងពួង ។

សត្វដែលមិនបានត្រាស់ដឹងធម៌ ព្រោះមិនមានព្រះពុទ្ធ
សត្វដែលមិនបានត្រាស់ដឹងធម៌ ព្រោះមិនបានជួបធម៌
សត្វដែលមិនបានត្រាស់ដឹងធម៌ ព្រោះមិនច្បាស់ព្រះបរិយត្តិ
សត្វដែលមិនបានត្រាស់ដឹងធម៌ ព្រោះមិនបានបដិបត្តិ ។

*សត្វដែលមិនបានត្រាស់ដឹងធម៌ ព្រោះបានបដិបត្តិហើយ តែបុណ្យបារមី ឧបនិស្ស័យមិនទាន់គ្រប់គ្រាន់ ។*

*ព្រះធម្មសេនាបតីសម្ដែងថា*

អានាបានស្សតិ យស្ស　　　បរិបុណ្ណា សុភាវិតា
អនុបុព្វំ បរិចិតា　　　យថា ពុទ្ធេន ទេសិតា
សោ ឥមំ លោកំ បភាសេតិ　　　អព្ភា មុត្តោវ ចន្ទិមា

*អានាបានស្សតិ បុគ្គលណាបានបំពេញហើយ ចម្រើនហើយ*
*ដោយប្រពៃ សន្សំហើយដោយលំដាប់ ឲ្យដូចព្រះពុទ្ធទ្រង់*
*សម្ដែងទុកហើយ បុគ្គលនោះឯង រមែងញុំាងលោកនេះ*
*ឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទ ដែលផុតស្រឡះចាកពពក ។*

*ការចម្រើនអានាបានស្សតិឲ្យបរិបូណ៌ត្រឹមត្រូវហើយ ឈ្មោះថាចម្រើនសតិប្បដ្ឋានទាំង ៤ ឲ្យបរិបូណ៌បាន ។ ការចម្រើនអានាបានស្សតិគឺការចម្រើនកាយានុបស្សនា វេទនានុបស្សនា ចិត្តានុបស្សនា និង ធម្មានុបស្សនានោះឯង ។*

*អានាបានស្សតិមាន ៤ ចតុក្កៈ គឺកាយានុបស្សនា ជាចតុក្កៈទី ១ វេទនានុបស្សនា ជាចតុក្កៈទី ២ ចិត្តានុបស្សនា ជាចតុក្កៈទី ៣ ធម្មានុបស្សនា ជាចតុក្កៈទី ៤ ។ ចតុក្កៈទាំង ៣ គឺកាយានុបស្សនា វេទនានុបស្សនា និងចិត្តានុបស្សនានេះ មានទាំងសមថៈនិងវិបស្សនា*

ចំណែកចតុក្កៈទី ៤ គឺវិបស្សនាសុទ្ធ ដូចក្នុងគម្ពីរវិសុទ្ធិមគ្គ (ភាគទី ២ ទំព័រ៥៦៩) បញ្ជាក់ថា ៖

ឥទំ ចតុក្កំ សុទ្ធវិបស្សនាវសេនេវ វុត្តំ ។ បុរិមានិ បន តីណិ សមថវិបស្សនាវសេន ។

ចតុក្កៈទី ៤ នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង ដោយអំណាចវិបស្សនាសុទ្ធតែម្យ៉ាង ។ ចំណែកចតុក្កៈទាំង ៣ ខាងដើម ព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយអំណាចសមថៈនិងវិបស្សនា ។

ការចម្រើនអានាបានស្សតិ មានគុណប្រយោជន៍ទាំងបច្ចុប្បន្ន ទាំងបរលោក កាលបើដូច្នោះ សូមពុទ្ធសាសនិកជនទាំងអស់ នាំគ្នាចម្រើនអានាបានស្សតិ តាមន័យក្នុងសៀវភៅនេះចុះ។

២ ១០ ៩ ឆ្នាំ រោង ចត្វាស័ក ព.ស.២៥៥៦

ត្រូវនឹងថ្ងៃទី ២៧ ខែ សីហា គ.ស.២០១២

**ធម្មានន្ទ ទ៊ាន់ ចាន់សារ៉ែន**

# សម្មោទនីយកថា

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនាចំពោះវិរិយភាពយ៉ាងវិសេសវិសាលរបស់លោកគ្រូ **ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន** និងសហការីទាំងអស់ ដែលបានផ្តួចផ្តើមបរិវត្ត គម្ពីរ អដ្ឋកថា ដីកា សម្រាប់ទុកជាឯកសារសិក្សាស្រាវជ្រាវក្នុងព្រះពុទ្ធសាសនា ។

ខ្ញុំព្រះករុណា ខ្ញុំបាទមានចិត្តរំភើបយ៉ាងខ្លាំង រកអ្វីមកប្រៀបពុំបាន ចំពោះការងារដ៏លំបាក ហើយកម្រនឹងធ្វើបាននេះ ។ ក្នុងនាមពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលមានខ្ញុំព្រះករុណា ខ្ញុំបាទ ជាប្រធានក្រុមប្រឹក្សាភិបាល បានដំណើរការបរិវត្ត និងបោះពុម្ពគម្ពីរធម៌ទាំងនោះ ជាបណ្តើរៗ សម្រាប់ទុកជាឯកសារសិក្សាស្រាវជ្រាវក្នុងព្រះពុទ្ធសាសនា ។ នេះចាត់ទុកជាឯកសារដ៏ពិសិដ្ឋមួយរបស់ពុទ្ធិកបណ្ឌិតសភា នៃសាកលវិទ្យាល័យ-បញ្ញាសាស្ត្រកម្ពុជាដែលបានសម្រេច ។

នេះជាកូនសៀវភៅមួយទៀតដែលមានឈ្មោះថា **អានាបានស្សតិ** ដែលបានចង្អុលបង្ហាញពីវិធីបដិបត្តិក្នុងសមថៈនិងវិបស្សនា ដោយបានដកស្រង់ចេញពីព្រះត្រៃបិដក អដ្ឋកថា និងដីកា ។ អត្ថបទនេះនឹងបានផ្តល់ប្រយោជន៍ដ៏ធំធេងចំពោះពុទ្ធសាសនិកក្នុងការសិក្សាស្រាវជ្រាវព្រះសទ្ធម្មក្នុងព្រះត្រៃបិដក នឹងជួយទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យគង់វង្សក្នុងពិភពលោកទាំងមូល អស់កាលជាអង្វែងពុំខានឡើយ ។

សព្វេ សត្តា អវេរិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយ កុំមានពៀរនឹងគ្នា*

សព្វេ សត្តា ខេមិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយ បានដល់នូវសេចក្តីក្សេម*

សព្វេ សត្តា សុខិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយបានប្រកបដោយសេចក្តីសុខជានិច្ចនិរន្តរ៍!*

*៣ ១១ ៩ ឆ្នាំ រោង ចត្វាស័ក ព.ស.២៥៥៦*

*ត្រូវនឹងថ្ងៃទី ២៨ ខែ សីហា គ.ស.២០១២*

**ក្រុលដេង**

*ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា*

# បញ្ជីមាតិកា


| មាតិកា | ទំព័រ |
|---|---|
| អានាបានស្សតិ | ១ |
| បុព្វភាគខាងដើមសម្រាប់អ្នកបដិបត្តិសមាធិ | ៤ |
| បលិពោធ ១០ | ៤ |
| សប្បាយៈ ៧ យ៉ាង | ៥ |
| ស្ថានទីមិនគួរនៅ ដើម្បីបដិបត្តិធម៌ | ៦ |
| ស្ថានទីគួរនៅ ដើម្បីបដិបត្តិធម៌ | ៧ |
| បូជាព្រះរតនត្រ័យ និងរក្សាសីល | ៨ |
| ថ្វាយខ្លួនដល់ព្រះពុទ្ធមុនបដិបត្តិសមាធិ | ១០ |
| ថ្វាយខ្លួនដល់គ្រូមុនបដិបត្តិសមាធិ | ១០ |
| តាំងចិត្តបដិបត្តិសមាធិ | ១០ |
| អានាបានស្សតិ ពោលដោយកិច្ច មាន ៥យ៉ាង | ១១ |
| អានិសង្សចម្រើនអានាបានស្សតិ | ១១ |
| គោលបដិបត្តិអានាបានស្សតិ | ១៣ |
| ការអង្គុយពែនភ្នែនមាន ៣ បែប | ១៤ |
| ទីតាំងនៃការតម្កល់សតិ | ១៦ |
| មានសតិក្នុងវត្ថុ ១៦ | ១៧ |
| អានាបានស្សតិទាំង ១៦ ខ | ២២ |
| សន្ធិ ៥ | ២៤ |

វិធីចម្រើនអានាបានស្សតិសមាធិ
តាមន័យរបស់អដ្ឋកថា ២៦
គណនា ២៧
អនុពន្ធនា ៣២
ឋបនាន័យ ៣២
អសប្បាយៈ ៧ យ៉ាង ៣៣
អប្បនាកោសល ១០ យ៉ាង ៣៣
និមិត្ត ៣ សមាធិ ៣ ៣៤
ការប្រៀបធៀបព្រះបាលី និងអដ្ឋកថា ៣៧
ឧបកិលេស មាន ១៨ យ៉ាង ៤១
និមិត្ត អស្សាសៈ និងបស្សាសៈមិនប្រាកដ
ជាអន្តរាយដល់សមាធិ ៤៥
ញាណក្នុងវោទាន ១៣ វិធីកែឧបកិលេស១៨ ៤៩
ឧបសគ្គដោយទូទៅនិងឧបការៈរបស់សមាធិ ១៦ ៥២
ឧបកិលេស ១៦ ៥៥
ឧបកិលេសនៃចិត្តដទៃទៀត ១៦ យ៉ាង ៥៧
សមាធិ ៥៨
សមាធិក្នុងគម្ពីរនេត្តិប្បករណ៍ ៦១
អប្បនាសមាធិ ៦១
បឋមជ្ឈាន ៦២

| | |
|---|---|
| ទុតិយជ្ឈាន | ៦៣ |
| តតិយជ្ឈាន | ៦៤ |
| ចតុត្ថជ្ឈាន | ៦៥ |
| ចតុក្កៈទី ២ វេទនានុបស្សនា | ៦៥ |
| ចតុក្កៈទី ៣ ចិត្តានុបស្សនា | ៦៧ |
| ចតុក្កៈទី ៤ ធម្មានុបស្សនា | ៦៩ |
| ចម្រើនអានាបានស្សតិការនាតាមវិបស្សនានយ័ | ៧០ |
| ចម្រើនវិបស្សនាតាមនយ័កំណត់ដឹងខ្យល់មាន ២ វិធី | ៧១ |
| ចម្រើនវិបស្សនារបស់បុគ្គលសុទ្ធវិបស្សនាយានិក | ៧៥ |
| វិបស្សនាញាណ ៣ លំដាប់ | ៨២ |
| វិសុទ្ធិ ៧ | ៨៩ |
| ១.សីលវិសុទ្ធិ | ៨៩ |
| ២.ចិត្តវិសុទ្ធិ | ៩០ |
| ៣.ទិដ្ឋិវិសុទ្ធិ | ៩០ |
| ៤.កង្ខាវិតរណវិសុទ្ធិ | ៩២ |
| ៥.មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ | ៩៦ |
| វិបស្សនូបកិលេស មាន ១០ យ៉ាង | ៩៧ |
| ៦.បដិបទាញាណទស្សនវិសុទ្ធិ | ៩៨ |
| ៧.ញាណទស្សនវិសុទ្ធិ | ៩៩ |
| សោឡសញាណ | ១០០ |

| | |
|---|---|
| បរិញ្ញា ៣ | ១០១ |
| បហានៈ ៥ យ៉ាង | ១០២ |
| ចម្រើនសតិប្បដ្ឋាន ៤ ដោយអានាបានស្សតិភាវនា | ១០៣ |
| ចម្រើនពោជ្ឈង្គៈ ៧ ដោយអានាបានស្សតិភាវនា | ១០៦ |
| សាសនព្រហ្មចរិយៈ | ១០៨ |
| រូបភាពសមាធិ | ១១០ |

៩ជ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតិំ ឧបដ្ឋបេត្វា។

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះដ៏ស្ងាត់ក្តី អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់តម្កល់សតិឲមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។*



# អានាបានស្សតិ

*សតិដែលកំណត់ដឹងអស្សាសៈ គឺខ្យល់ចូល បស្សាសៈ ខ្យល់ចេញ ឈ្មោះថា អានាបានស្សតិ ។*

*ជួបក្នុងសុត្តន្តបិដក ក្រុមជំនុំបានប្រែថា អស្សាសៈ ខ្យល់ចេញ, បស្សាសៈ ខ្យល់ចូល ដូចក្នុងពាក្យថា* សោ សតោវ អស្សសតិ សតោ បស្សសតិ *ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល*[1] ។

*តើខនេះគួរប្រែយ៉ាងណា ?*

*ក្នុងព្រះវិន័យគួរប្រែថា អស្សាសៈខ្យល់ចេញ, បស្សាសៈ ខ្យល់ចូល ព្រោះអដ្ឋកថាព្រះវិន័យសមន្តប្បាសាទិកាបញ្ជាក់ថា*

អស្សាសោតិ ពហិ និក្ខមនវាតោ ។ បស្សាសោតិ អន្តោ បវិសនវាតោ ។ សុត្តន្តដ្ឋកថាសុ បន ឧប្បដិបាដិយា អាគតំ ។

*ពាក្យថា អស្សាសៈ គឺខ្យល់ចេញទៅខាងក្រៅ ។ ពាក្យថា បស្សាសៈ គឺខ្យល់ចូលទៅខាងក្នុង ។ តែក្នុងអដ្ឋកថាព្រះសូត្រទាំងឡាយ ជួបខសេចក្ដីមិនលំដាប់គ្នា ។*

*តាមគោលភាសា ពាក្យថា អស្សាសៈ (សំស្ក្រឹតប្រើជា អាគ្វស) មកពី អា ស័ព្ទ + សាស ស័ព្ទ មានរូបវិគ្រោះថា* អាទិម្ហិ សាសោ អស្សាសោ *អស្សាសៈ គឺខ្យល់ក្នុងខាងដើម ។ ខ្យល់ក្នុងខាងដើម ក៏គឺ*

---

[1] មជ្ឈិម.ឧបរិ.២៦/៣៦០ ។

ខ្យល់ចេញដែលកើតមុន ដល់ទារកដែលចេញចាកគភ៌របស់មាតា ។ ចំណែក បស្សាសៈ (សំស្រ្កឹតប្រើជា ប្រគ្វស) មកពីពាក្យថា ប ស័ព្ទ + សាស ស័ព្ទ មានរូបវិគ្រោះថា បច្ឆា សាសោ បស្សាសោ បស្សាសៈ គឺ ខ្យល់ចូលខាងក្រោយ ។

យ៉ាងណាក៏ដោយ គម្ពីរអដ្ឋកថារបស់ព្រះសូត្រប្រែ អស្សសតិ ថា រមែងដកដង្ហើមចូល និងប្រែថា បស្សសតិ ថា រមែងដកដង្ហើមចេញ ដោយបំណងសម្ដែងការបដិបត្តិកំណត់ដឹងខ្យល់ចូលមុន ដូចសេចក្ដីក្នុងគម្ពីរ វិសុទ្ធិមគ្គមហាដីកាថា

វិនយនយេន អន្តោ ឧដ្ឋិតសសនំ អស្សាសោ, ពហិ ឧដ្ឋិតសសនំ បស្សាសោ ។ សុត្តន្តនយេន បន ពហិ ឧដ្ឋហិត្វាបិ អន្តោ សសនតោ អស្សាសោ, អន្តោ ឧដ្ឋហិត្វាបិ ពហិ សសនតោ បស្សាសោ ។

តាមន័យព្រះវិន័យ ខ្យល់ចូលដែលកើតឡើងខាងក្នុង ឈ្មោះថា អស្សាសៈ (ខ្យល់ដង្ហើមចេញ), ខ្យល់ដែលកើតឡើងខាងក្រៅ ឈ្មោះថា បស្សាសៈ (ខ្យល់ដង្ហើមចូល) ។ តែតាមន័យព្រះសូត្រ ឈ្មោះថា អស្សាសៈ (ខ្យល់ដង្ហើមចូល) ព្រោះជាខ្យល់ដែលកើតពីខាងក្រៅហើយចូលទៅខាងក្នុង និងឈ្មោះថា បស្សាសៈ (ខ្យល់ដង្ហើមចេញ) ព្រោះជាខ្យល់ដែលកើតខាងក្នុងហើយចេញទៅខាងក្រៅ ។

បើពិនិត្យមើលឲ្យច្បាស់ ក្នុងគម្ពីរបដិសម្ភិទាមគ្គនឹងឃើញប្រាកដថា អស្សាសៈ ខ្យល់ដង្ហើមចូល បស្សាសៈ ខ្យល់ដង្ហើមចេញ ដូចព្រះ

*ធម្មសេនាបតីសារីបុត្រសម្តែងទុកក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ភាគទី ៧០ ទំព័រ ៨៨ ថា*

អស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ អជ្ឈត្តវិក្ខេបគតំ ចិត្តំ សមាធិស្ស បរិបន្ថោ *កាលបញ្ជូនសតិទៅតាមខាងដើម កណ្តាល និងខាងចុងនៃខ្យល់ដកដង្ហើមចូល ចិត្តដែលបោះទៅខាងក្នុង ជាអន្តរាយដល់សមាធិ ។*

បស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ ពហិទ្ធាវិក្ខេបគតំ ចិត្តំ សមាធិស្ស បរិបន្ថោ *កាលបញ្ជូនសតិទៅតាមខាងដើម កណ្តាល និងខាងចុងនៃខ្យល់ដកដង្ហើមចេញ ចិត្តដែលបោះទៅខាងក្រៅ ជាអន្តរាយដល់សមាធិ ។*

*ម្យ៉ាងទៀត ពាក្យថា អស្សាសបស្សាសៈ នេះ ជាពាក្យវេវចនៈនឹង ពាក្យថា* អានាបានៈ ។ អានាបានៈ *មកពី* អាន *ស័ព្ទ +* អបាន *ស័ព្ទ មានសេចក្តីថា ខ្យល់ចូលនិងខ្យល់ចេញ ។ មានគោលស្ថានក្នុងអដ្ឋកថាថេរគាថាថា*

អានន្តិ អស្សាសោ ។ អបានន្តិ បស្សាសោ ។ អស្សាសបស្សាសនិមិត្តារម្មណា សតិ អានាបានស្សតិ ។ សតិសីសេន ចេត្ថ តំសម្បយុត្តសមាធិភាវនា អធិប្បេតា ។

*ពាក្យថា អាន គឺខ្យល់ចូល ។ ពាក្យថា អបានៈ គឺខ្យល់ចេញ ។ សតិដែលមានខ្យល់ចូល និងខ្យល់ចេញជាអារម្មណ៍ ឈ្មោះថា អានាបានស្សតិ ។*

## បុព្វភាគខាងដើមសម្រាប់អ្នកបដិបត្តិសមាធិ

*យោគាវចរអ្នកបដិបត្តិសមាធិ ជាដំបូងត្រូវលះបង់នូវបលិពោធ គឺសេចក្តីកង្វល់ផ្សេងៗ និងទៅនៅក្នុងទីសប្បាយ ជាកន្លែងដែលសមគួរដល់ការធ្វើសមាធិ ហើយឧទ្ទិសខ្លួនដល់ព្រះរតនត្រ័យ តាំងចិត្តជំមាំដើម្បីជាបុព្វភាគក្នុងការបដិបត្តិសមាធិ ។*

### បលិពោធ ១០[១]

*សេចក្តីកង្វល់ ហៅថា បលិពោធ មាន ១០ យ៉ាងគឺ ៖*

**១.អាវាសបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងទីនៅ*

**២.កុលបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងក្នុងត្រកូល*

**៣.លាភបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងលាភ*

**៤.គណបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងពួកគណៈ*

**៥.កម្មបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងការងារ*

**៦.អទ្ធានបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងដើរផ្លូវ*

**៧.ញាតិបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងញាតិ*

**៨.អាពាធបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងជំងឺ*

**៩.គន្ថបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងសិក្សារៀនសូត្រ*

---

[១] *វិសុទ្ធិមគ្គ ១/១៧៣ ។*

**១០.ឥទ្ធិបលិពោធ** *សេចក្តីកង្វល់ក្នុងរឿងឫទ្ធិ ។*

*បលិពោធទាំង ១០ នេះ ព្រះពុទ្ធឃោសាចារ្យ បានអធិប្បាយដ៏ល្អិតក្នុងគម្ពីរវិសុទ្ធិមគ្គ សម្រាប់ព្រះភិក្ខុដោយត្រង់ ដែលលោកជាអ្នកស្វែងរកនូវលោកុត្តរធម៌ ។ តែសម្រាប់យោវាសជាអ្នកនៅគ្រប់គ្រងផ្ទះ ជាអ្នកមានកង្វល់ច្រើន ដូច្នេះខ្ញុំសូមលើកយកចំណុចសំខាន់ៗ ដើម្បីជាគោលសម្រាប់យោវាស ដែលជាអ្នកមានបំណងក្នុងការបដិបត្តិសមាធិ ។*

*ពាក្យថា* **លះបង់បលិពោធ** *សេចក្តីសម្រាប់យោវាសទូទៅ គឺគប្បីចាត់ចែងការងារឲ្យមានរបៀប ធ្វើការដោយកំណត់ពេលវេលាឲ្យច្បាស់លាស់ថា តើក្នុងមួយថ្ងៃ គួរប្រើពេលណា សម្រាប់អង្គុយសមាធិ, គួរធ្វើក្នុងផ្ទះឬនឹងទៅវត្ត ឬនឹងទៅទីដ៏ស្ងប់ស្ងាត់ណាមួយក៏ដោយ ។ មុនអង្គុយសមាធិ គួរចាត់ចែងនូវអ្វីៗ ដែលជារឿងកង្វល់ឲ្យហើយ ទើបគួរចម្រើនសមាធិ ។ តែសម្រាប់មនុស្ស ដែលជាអ្នកសម្បូរដោយមេត្តា ករុណា មានបុណ្យបានធ្វើទុកហើយ ។ មនុស្សប្រភេទនេះ មិនសូវមានបញ្ហា ជាអ្នកអាចកាត់កង្វល់បានដោយងាយ ។*

**សប្បាយៈ**[១]

*ពាក្យថា* **នៅនៅក្នុងទីជាទីសប្បាយ** *មានន័យថា សប្បាយៈ គឺទៅនៅក្នុងទីស្រួលបដិបត្តិ មាន ៧ យ៉ាង ៖*

**១.អាវាសសប្បាយៈ** *ទីនៅសប្បាយ*

---

[១] *វិសុទ្ធិមគ្គ ១/២៥០ ។*

**២.គោចរសប្បាយៈ** *ទីស្វែងរកអាហារសប្បាយ*

**៣.ភស្សសប្បាយៈ** *ពាក្យនិយាយសប្បាយ*

**៤.បុគ្គលសប្បាយៈ** *បុគ្គលសប្បាយ*

**៥.ភោជនសប្បាយៈ** *អាហារសប្បាយ*

**៦.ឧតុសប្បាយៈ** *អាកាសសប្បាយ*

**៧.ឥរិយាបថសប្បាយៈ** *ឥរិយាបថសប្បាយ*

*ពាក្យថា* **ទីនៅសប្បាយ** *អធិប្បាយថា ទីនៅឯណា កាលនៅហើយ ធ្វើនិមិត្តមិនកើត ឲ្យកើតឡើងបាន នឹងកើតឡើងហើយ អាចរក្សាទុកបាន ធ្វើសតិឲ្យមាំ ធ្វើចិត្តឲ្យជាសមាធិងាយ ទីនៅយ៉ាងនេះ ហៅថាអាវាសសប្បាយៈ ។*

*ម៉្យាងទៀត លោកនៅណែនាំទៀតថា ទីនៅមានសភាពដូច្នេះ មិនគួរនៅ ដើម្បីបដិបត្តិធម៌ គឺ ៖*

**១.វិហារធំ**

**២.វិហារថ្មី**

**៣.វិហារចាស់**

**៤.វិហារជិតផ្លូវ**

**៥.វិហារជិតស្រះទឹក**

**៦.វិហារមានស្លឹកឈើ**

**៧.វិហារមានផ្កាឈើ**

**៨.វិហារមានផ្លែឈើ**

**៩.វិហារដែលមនុស្សច្រើនចេញចូលមកច្រើន**

**១០.វិហារជិតក្រុង**

**១១.វិហារជិតព្រៃឧស**

**១២.វិហារជិតស្រែ**

**១៣.វិហារមានមនុស្សដែលមិនត្រូវគ្នា**

**១៤.វិហារនៅជិតកំពង់ទឹក**

**១៥.វិហារជិតព្រំដែន**

**១៦.វិហារដែលនៅចន្លោះព្រំដែន**

**១៧.វិហារដែលមិនមានសប្បាយៈ**

**១៨.វិហារដែលមិនមានកល្យាណមិត្រ**

*ពាក្យថា* **វិហារ** *ក្នុងទីនេះ សំដៅដល់វត្តទាំងមូល ឬខ្ទម ឬក៏កុដិ មិនមែនសំដៅដល់ រោងឧបោសថនោះទេ ។ សូមអ្នកសិក្សាមើលបន្ថែមទៀត ដោយខ្លួនឯង ក្នុងគម្ពីរវិសុទ្ធិមគ្គ ភាគទី ១ ទំព័រ ២៣៣ ។*

*ស្ថានទីនៅ ដើម្បីបដិបត្តិធម៌ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងលក្ខណៈទុកដូច្នេះ*[១] *៖*

*១.ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងលោកនេះ មិនឆ្ងាយពេក មិនជិតពេក ល្មមទៅមកស្រួល មិនកុះករដោយមនុស្សក្នុងវេលាថ្ងៃ មិនសូវ*

*[១] អង្គុត្តរ.ទសក.៥០/៣៣ ។*

មានសំឡេង មិនសូវគឹកកងក្នុងរាត្រី មិនសូវមានសម្ផស្ស ដោយរបោម មូស ខ្យល់ កំដៅថ្ងៃនិងពស់តូច ពស់ធំ ។

២.ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ កើតឡើង ដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះ ដោយមិនលំបាក ។

៣.ពួកភិក្ខុជាថេរៈដែលនៅក្នុងសេនាសនៈនោះ ជាពហុស្សូត ចេះ ចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ។

៤.ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្តងៗ ហើយសួរ ប្រឹក្សាថា បពិត្រលោកដ៏ចម្រើន រឿងនេះតើដូចម្តេច? សេចក្តីអធិប្បាយនៃរឿងនេះ តើដូចម្តេច? ។

៥.លោកដ៏មានអាយុទាំងនោះ រមែងពន្យល់រឿងដែលមិនទាន់ ច្បាស់លាស់ផង ធ្វើឲ្យងាយនូវរឿងដែលជ្រៅផង បន្ទោបង់នូវសេចក្តី សង្ស័យក្នុងធម៌ទាំងឡាយផង ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើន ប្រការ ។

នៅក្នុងគម្ពីរវិសុទ្ធិមគ្គ មានអធិប្បាយច្បាស់លាស់អំពីទីសប្បាយ ទាំង ៧ នេះ ។ តែក្នុងគម្ពីរសម្មោហវិនោទនី លោកបន្ថែមមួយទៀត គឺ **ធម្មស្សវនសប្បាយៈ** ការស្តាប់ព្រះធម៌សប្បាយ ។

## បូជាព្រះរតនត្រ័យ និងរក្សាសីល

យោគាវចរអ្នកបដិបត្តិសមាធិ ដែលបានកាត់បលិពោធ និងចូល ទៅកាន់ទីកន្លែង ឬសេនាសនៈជាទីសប្បាយហើយ គប្បីដល់ព្រះត្រៃសរ-

ណាគមន៍ និងរក្សាសីលឲ្យស្អាតបរិសុទ្ធជាមុនសិន ទើបចាប់ផ្តើមបដិបត្តិសមាធិ ។ បើជាព្រះភិក្ខុ ឬសាមណេរ គប្បីជម្រះសីលរបស់ខ្លួនឲ្យស្អាតបរិសុទ្ធ មុនធ្វើសមាធិ[១] ។

## ព្រះត្រៃសរណគមន៍

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ពុទ្ធំ សរណំ គច្ឆាមិ

ធម្មំ សរណំ គច្ឆាមិ

សង្ឃំ សរណំ គច្ឆាមិ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ។

## បញ្ចសីល

១. បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ។

---

[១] គម្ពីរវិសុទ្ធិមគ្គ,សម្មោហវិនោទនី អដ្ឋកថា សតិប្បដ្ឋាន។

២. អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ។

៣. កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ។

៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ។

៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិ-យាមិ។

## ថ្វាយខ្លួនដល់ព្រះពុទ្ធមុនបដិបត្តិសមាធិ

ឥមាហំ ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជាមិ *បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមថ្វាយនូវអត្តភាពនេះ ចំពោះព្រះអង្គ ។*

## ថ្វាយខ្លួនដល់គ្រូមុនបដិបត្តិសមាធិ

ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ *បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា សូមថ្វាយនូវអត្តភាពនេះ ចំពោះលោកម្ចាស់*[១] *។*

## តាំងចិត្តបដិបត្តិសមាធិ

*យោគាវចរជាអ្នកបដិបត្តិសមាធិ ត្រូវតាំងចិត្តឲ្យមាំក្នុងការយកចិត្តទុកដាក់ក្នុងការបដិបត្តិសមាធិ ។ ការបដិបត្តិធម៌ ជាទាទីដ៏សំខាន់សម្រាប់ជីវិត ព្រោះធម៌ដែលបានបដិបត្តិល្អហើយ រមែងបានជាទីពឹងទាំងក្នុងបច្ចុប្បន្នជាតិ និងបរលោក ។*

---

[១] *វិសុទ្ធិមគ្គ ១/២២៦-២២៧ ។*

# **អានាបានស្សតិ**

**អានាបានស្សតិ** *ពោលដោយកិច្ច មាន ៥យ៉ាង គឺ*

**១.កាយគតាសតិភាវនាកិច្ច** *កិច្ច គឺការចម្រើនសមថភាវនា ដោយការកំណត់ខ្យល់អានាបានៈ*

**២.សមថភាវនាកិច្ច** *កិច្ច គឺការចម្រើនសមថភាវនា បានដល់ អប្បនាឈាន ៤ ប្រភេទ*

**៣.វិបស្សនាភាវនាកិច្ច** *កិច្ច គឺការចម្រើនវិបស្សនាភាវនា*

**៤.មគ្គភាវនាកិច្ច** *កិច្ច គឺចម្រើនមគ្គ បានដល់ វិជ្ជា* (*មគ្គញ្ញាណ*) *និងវិមុត្តិ* (*ផលញ្ញាណ*)

**៥.ផលសច្ឆិកិរិយាកិច្ច** *កិច្ច គឺការធ្វើផលឲ្យជាក់ច្បាស់ ។*

(*អានាបានទីបនី លេឌីសយាដោ*)

# **អានិសង្សចម្រើនអានាបានស្សតិ**

*ព្រះពុទ្ធជាអម្ចាស់ ទ្រង់ត្រាស់សម្តែងនូវអានិសង្សនៃការចម្រើន អានាបានស្សតិថា ៖*

សង្ឃិ ភិក្ខវេ ភិក្ខុ ឥមស្មិំ ភិក្ខុសង្ឃេ អានាបានស្សតិ- ភាវនានុយោគមនុយុត្តា វិហរន្តិ។ អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកប រឿយៗ នូវសេចក្ដីព្យាយាមជាគ្រឿងចម្រើននូវអានាបានស្សតិ សម្រាន្ត នៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែល បុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយរមែងមានផលច្រើន មាន អានិសង្សច្រើន ។

អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា ចត្តារោ សតិបដ្ឋានេ បរិបូរេតិ ។ ចត្តារោ សតិបដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិំ បរិបូរេន្តិ។

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើន បាន ធ្វើឲ្យរឿយ ៗ ហើយ រមែងញ៉ាំងសតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូណ៌បាន។ សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែង ញ៉ាំងពោជ្ឈង្គៈទាំង ៧ ឲ្យពេញបរិបូណ៌បាន ។ ពោជ្ឈង្គៈទាំង ៧ ដែលបុគ្គល បានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញ៉ាំងវិជ្ជា និងវិមុត្តិឲ្យពេញ បរិបូណ៌បាន ។

(មជ្ឈិម.ឧបរិ. ២៦/៣៥៩)

# គោលបដិបត្តិអានាបានស្សតិ

ព្រះពុទ្ធបរមគ្រូព្រះអង្គទ្រង់ចង្អុលបង្ហាញនូវវិធីបដិបត្តិសមាធិ ជាបឋមដោយព្រះពុទ្ធដីកាត្រាស់សួរថា[១] ៖

កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា?

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើន ដូចម្តេច បានធ្វើឲ្យរឿយៗដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន?

ព្រះពុទ្ធជាម្ចាស់ទ្រង់តបដោយព្រះអង្គឯងវិញថា ៖

ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះដ៏ស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តម្កល់សតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។

ព្រះពុទ្ធជាអម្ចាស់ត្រាស់សម្តែងស្ថានទីបដិបត្តិធម៌ទុក ៣ កន្លែង គឺ ព្រៃ គល់ឈើ ឬផ្ទះស្ងាត់ ដើម្បីសម្តែងស្ថានទីដ៏ស្ងាត់សម្រាប់អ្នកបដិបត្តិ

[១] មជ្ឈិម.ឧបរិ.២៦/៣៥៩ ។

ថ្មី ។ សម្រាប់អ្នកដែលមានសមាធិមាំទាំហើយ អាចបដិបត្តិធម៌បានក្នុងស្ថានទីដែលខ្លួនពេញចិត្តបាន ។

ព្រះពុទ្ធអង្គទ្រង់ចង្អុលបង្ហាញការអង្គុយពែនភ្នែន ក្នុងអានាបានៈនេះ ព្រោះខ្យល់ចូល ខ្យល់ចេញប្រាកដច្បាស់ក្នុងវេលាអង្គុយច្រើនជាងវេលាដើរ ឬឥរិយាបថដទៃ ។ តែសមាធិចាស់ក្លាហើយក៏អាចចម្រើនទូវអានាបានស្សតិការនាបានទាំង ៤ ឥរិយាបថ គឺការឈរ ដើរ អង្គុយ ដេក តាមសមគួរ ។

**ការអង្គុយពែនភ្នែនមាន ៣ បែប**

**១.អង្គុយបែបគូបល្ល័ង្ក** គឺភ្នែនពេជ្រ (full-lotus position) គឺវិធីអង្គុយយកជើងទាំងពីរខ្វាស់គ្នា ទាញយកជើងស្តាំដាក់ពីខាងលើជើងឆ្វេង ។ របៀបអង្គុយនេះ និយមក្នុងប្រទេសឥណ្ឌា ។

**២.អង្គុយបែបត្រួតជើង** (half-lotus position) គឺរបៀបអង្គុយបត់ជង្គង់ចេញក្រៅ ដាក់ចុងជើងទាំងពីរតម្រួតគ្នា ដោយយកជើងស្តាំត្រួតលើជើងឆ្វេង ។ របៀបអង្គុយនេះ និយមក្នុងប្រទេសខ្មែរនិងប្រទេសថៃ ។

**៣.អង្គុយបែបរៀងជើង** (easy-position) គឺវិធីអង្គុយប្រហាក់ប្រហែលគ្នា តែដាក់ជើងរៀងគ្នា គឺមិនត្រួតលើគ្នា ដាក់ជើងឆ្វេងខាងក្រៅ ជើងស្តាំខាងក្នុង ។ របៀបអង្គុយនេះ និយមក្នុងប្រទេសភូមា ។

ក្នុងអដ្ឋកថា សមន្តប្បាសាទិកា តតិយបារាជិកវណ្ណនា អធិប្បាយថា ៖

ត្រង់ពាក្យថា អង្គុយពែនភ្នែន បានដល់ ការអង្គុយបត់ជើងទាំងពីរ ដោយជុំវិញ គឺអង្គុយពែនភ្នែន ។ ត្រង់ពាក្យថា **អាភុជិត្វា** ប្រែថា បត់ចូល។ ត្រង់ពាក្យថា តាំងកាយឲ្យត្រង់ មានសេចក្ដីថា តាំងរាងកាយចំណែក ខាងលើឲ្យត្រង់ គឺឲ្យឆ្អឹងខ្នង ១៨ កំណាត់ទល់ទីបំផុត ចំពោះទីបំផុត ។ ពិតប្រាកដណាស់ កាលអង្គុយបែបអាការៈយ៉ាងនេះ ស្បែក សាច់ និង សរសៃ រមែងមិនកោង ។ ពេលនោះ វេទនាទាំងឡាយ ដែលនឹងកើតមាន ក្នុងខណៈៗ ព្រោះការកោងនៃស្បែក សាច់ និង សរសៃទាំងនោះ ជាបច្ច័យ រមែងមិនកើតឡើងបាន ។ កាលវេទនា ទាំងនោះ មិនកើតឡើង ចិត្តក៏មាន អារម្មណ៍តែមួយ កម្មដ្ឋានតាំងនៅស៊ប់ល្អ រមែងដល់នូវសេចក្ដីចម្រើន ។ ពាក្យថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** មានសេចក្ដីថា តាំងសតិចំពោះមុខឆ្ពោះ ទៅរកកម្មដ្ឋាន ។

ព្រះធម្មសេនាបតីសារីបុត្រ សម្ដែងទុកក្នុងបដិសម្ភិទាមគ្គថា ៖

អធិប្បាយពាក្យថា **តាំងសតិ** ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ត្រង់ ពាក្យថា **បរិ** មានអត្ថថា កំណត់ ពាក្យថា **មុខៈ** មានអត្ថថា ធម៌ជាគ្រឿង ចេញទៅ ពាក្យថា **សតិ** មានអត្ថថា ប្រុងប្រយ័ត្ន ហេតុនោះ លោកពោល ថា តាំងសតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។

(ខុទ្ទក.បដិ. ៧០/១១៩)

ព្រះធម្មសេនាបតីសារីបុត្រ នៅបញ្ជាក់យ៉ាងច្បាស់អំពីទីតាំងនៃ ការតម្កល់សតិថា ៖

ភិក្ខុ នាសិកគ្គេ វា មុខនិមិត្តេ វា សតឹ ឧបដ្ឋបេត្វា និសិន្នោ ហោតិ ។

*ភិក្ខុតម្កល់ទុកនូវសតិត្រង់ចុងច្រមុះ ឬត្រង់រិមបបូរមាត់ខាងលើ ហើយអង្គុយ ។*

*សេចក្តីអធិប្បាយក្នុងអដ្ឋកថា បដិសម្ភិទាមគ្គ ឈ្មោះ សទ្ធម្មប្បកាសិនី បញ្ជាក់ថា ៖*

នាសិកគ្គេ វាតិ ទីឃនាសិកោ នាសិកគ្គេ។ មុខនិមិត្តេ វាតិ រស្សនាសិកោ ឧត្តរោដ្ឋេ។ ឧត្តរោដ្ឋោ ហិ មុខេ សតិយា និមិត្តន្តិ មុខនិមិត្តន្តិ វុត្តោ។

*ត្រង់ពាក្យថា **ត្រង់ចុងច្រមុះ** សេចក្តីថា បុគ្គលដែលមានច្រមុះវែង ត្រូវតម្កល់សតិទុកត្រង់ចុងច្រមុះ ។ ត្រង់ពាក្យថា **ត្រង់រិមបបូរមាត់ខាងលើ** សេចក្តីថា បុគ្គលដែលមានច្រមុះខ្លី ត្រូវតម្កល់សតិទុកត្រង់រិមបបូរមាត់ខាងលើ ។ មែនពិត រិមបបូរមាត់ខាងលើ ព្រះសារីបុត្រហៅថា **មុខនិមិត្ត** ដោយន័យថា និមិត្តនៃសតិត្រង់មាត់ ។*

*កាលតម្កល់សតិត្រឹមត្រូវ តាមពាក្យបង្រៀនរបស់ព្រះពុទ្ធជាម្ចាស់ ហើយ គប្បីជាអ្នកមានសតិ ដកដង្ហើមចូល ដកដង្ហើមចេញ គឺ*

សោ សតោវ អស្សសតិ សតោវ បស្សសតិ ។

*ភិក្ខុនោះ ជាអ្នកមានសតិដកដង្ហើមចូល ជាអ្នកមានសតិដកដង្ហើមចេញ ។*

១.ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ, ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ

*កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង, កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង*

២.រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ, រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ

*កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី, កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី*

៣.សព្វកាយបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, សព្វកាយបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចេញ,*

៤.បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ, បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។

ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់នូវខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។

ចប់កាយានុបស្សនាសតិប្បដ្ឋាន

៥.បីតិបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, បីតិបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចេញ,

៦.សុខបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, សុខបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចេញ,

៧.ចិត្តសង្ខារបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, ចិត្តសង្ខារ-បដិសំវេទី បស្សសិស្សាមី‘តិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចេញ,

៨.បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ, បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

*ចប់វេទនានុបស្សនាសតិប្បដ្ឋាន*

៩.ចិត្តបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, ចិត្តបដិសំវេទី បស្សសិស្សាមី'តិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចេញ*

១០.អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ, អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុង ខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចេញ*

១១.សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ, សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចេញ*

១២.វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ, វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

ចប់ចិត្តានុបស្សនាសតិប្បដ្ឋាន

១៣.អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចេញ*

១៤.វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចេញ*

១៥.និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចេញ

១៦.បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចេញ

ចប់ធម្មានុបស្សនាសតិប្បដ្ឋាន

ពាក្យថា សិក្សា ខាងលើនេះ មានន័យថា ព្យាយាម ។

វិរាគៈ ប្រែថា ធម៌ជាទីប្រាសចាកកិលេស

និរោធៈ ប្រែថា ធម៌ជាទីរលត់កិលេស

បដិនិស្សគ្គៈ ប្រែថា ធម៌ជាទីរួចផុតចាកកិលេស

ពាក្យទាំងបីនេះ ជាឈ្មោះព្រះនិព្វាន ។

ម្យ៉ាងទៀត ពាក្យថា ជាប់តាមមើលនូវសភាពមិនទៀង នេះជាពាក្យប្រែតាមសំនួនភាសាបាលីថា អនិច្ចានុបស្សី, ពាក្យនេះនឹងប្រែថា ពិចារណាឲ្យឃើញនូវសភាពមិនទៀង ដូច្នេះក៏បាន ។

ការចម្រើននូវអានាបានស្សតិនេះ ឈ្មោះថា ចម្រើនសតិប្បដ្ឋាន យ៉ាងពេញបរិបូណ៌ ។

អានាបានស្សតិទាំង ១៦ ខនេះ អដ្ឋកថាសង្ខេបព្រះត្រៃបិដក ឈ្មោះ វិសុទ្ធិមគ្គបានបញ្ជាក់ថា ៖

ឯវំ សោឡសវត្ថុកំ អានាបានស្សតិ កម្មដ្ឋានំ និទ្ទិដ្ឋំ ។

អានាបានស្សតិកម្មដ្ឋាន ដែលមានវត្ថុ ១៦ គឺព្រះមានព្រះភាគ ទ្រង់ប្រកាសសម្ដែងហើយ មានប្រការយ៉ាងនេះ ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គ (បិដកលេខ ៧០ ទំព័រ ៨៣) ព្រះធម្មសេនាបតីសារីបុត្រសម្ដែងថា ៖

សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ កាលភិក្ខុ ចម្រើនអានាបានស្សតិសមាធិ មានវត្ថុ ១៦ ។

តើអានាបានស្សតិ ដែលមានវត្ថុ ១៦ នោះ ដូចម្ដេច?

អានាបានស្សតិ ដែលមានវត្ថុ ១៦ នោះគឺ

| | | |
|---|---|---|
| កាយានុបស្សនា | មាន ៤ | (១-៤) |
| វេទនានុបស្សនា | មាន ៤ | (៥-៨) |
| ចិត្តានុបស្សនា | មាន ៤ | (៩-១២) |
| ធម្មានុបស្សនា | មាន ៤ | (១៣-១៦) |

នៅក្នុងគម្ពីរវិសុទ្ធិមគ្គ មហាដីកាខែថា ៖

អានាបានស្សតីតិ សោឡសវត្ថុកា អានាបានស្សតិសមាធិ-
ភាវនា ។

*ត្រង់ពាក្យថា អានាបានស្សតិ បានដល់ អានាបានស្សតិសមាធិ
ភាវនា ដែលមានវត្ថុ ១៦ ។*

*ព្រោះហេតុនោះ ទើបព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ថា ៖*

អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា ចត្តារោ
សតិប្បដ្ឋានេ បរិបូរេតិ ។

*ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើន បាន
ធ្វើឲ្យច្រើន ៗ ហើយ រមែងញុំាងសតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូណ៌បាន។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ (ភាគទី ២ ទំព័រ ៥៤២) ការចម្រើន អានាបា-
នស្សតិ នេះថា ៖*

យស្មា បនេត្ថ ឥទមេវ ចតុក្កំ អាទិកម្មិកស្ស កម្មដ្ឋានវសេន
វុត្តំ ។ ឥតរានិ បន តីណិ ចតុក្កានិ ឯត្ថ បត្តជ្ឈានស្ស វេទនាចិត្តធម្មា-
នុបស្សនាវសេន វុត្តានិ។ តស្មា ឥទំ កម្មដ្ឋានំ ភាវេត្វា អានាបា-
នចតុត្ថជ្ឈានបទដ្ឋានាយ វិបស្សនាយ សហ បដិសម្ភិទាហិ អរហត្តំ
បាបុណិតុកាមេន អាទិកម្មិកេន កុលបុត្តេន បុព្វេ វុត្តនយេនេវ
សីលបរិសោធនាទីនិ សព្វកិច្ចានិ កត្វា វុត្តប្បការស្ស អាចរិយស្ស
សន្តិកេ បញ្ចសន្ធិកំ កម្មដ្ឋានំ ឧគ្គហេតព្វំ។

ចំពោះចតុក្កៈគឺពួកបួននេះ ព្រះពុទ្ធត្រាស់ទុកនូវចតុក្កៈទី ១ គឺកាយា-នុបស្សនា ដើម្បីជាកម្មដ្ឋានសម្រាប់កុលបុត្រដែលជាអាទិកម្មិកៈ គឺអ្នកបដិបត្តិក្នុងជាន់ខាងដើម ។ ចំណែកចតុក្កៈបីដទៃទៀត គឺវេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនា ព្រះពុទ្ធត្រាស់ទុកសម្រាប់អ្នកបានឈានហើយ ដែលបានបដិបត្តិនូវចតុក្កៈទី ១ រួចហើយ ។ ព្រោះហេតុនោះ កុលបុត្រដែលជាអាទិកម្មិកៈ កាលប្រាថ្នាទម្ងុះនូវអរហត្តផល មួយអន្លើ ដោយបដិសម្ភិទា ដោយវិបស្សនាដែលមានអានាបានចតុត្ថជ្ឈានជាបាទ ក៏គួរនឹងធ្វើកិច្ចទាំងពួង មានការជម្រះនូវសីលជាដើម តាមន័យ ដែលពោលមកហើយនោះឯង ហើយរៀនយកនូវកម្មដ្ឋានដែលមានសន្ធិ ៥ ក្នុងសំណាក់នៃអាចារ្យ ដែលបានពោលរួចហើយ ។

**សន្ធិ ៥**

(វិសុទ្ធិមគ្គ ភាគទី ២ ទំព័រ ៥៤៣)

ពាក្យថា សន្ធិ តាមស័ព្ទប្រែថា ការត មាន ៥ យ៉ាង គឺ ៖

**១.ឧគ្គហំ** ការរៀន

**២.បរិបុច្ឆា** ការសាកសួរ

**៣.ឧបដ្ឋានំ** ការប្រាកដរបស់និមិត្តសមាធិ

**៤.អប្បនា** ការមាំទាំរបស់សមាធិ

**៥.លក្ខណំ** លក្ខណៈរបស់សមាធិ

*ការរៀនយកកម្មដ្ឋានក្នុងសម័យពុទ្ធកាល និងក្រោយពុទ្ធកាល ត្រូវរៀនយកពីគ្រូអាចារ្យ ព្រោះសម័យនោះ រៀនតគ្នាតាមមុខបាឋ ។ តែក្នុងសម័យកាលនេះ ត្រូវសិក្សាឲ្យច្បាស់លាស់ក្នុងគម្ពីរព្រះត្រៃបិដក អដ្ឋកថានិងដីកា ទើបឈ្មោះថា* ***ឧគ្គហ:*** *។*

*ការសាកសួរដេញដោល ឲ្យអស់មន្ទិលសង្ស័យក្នុងខបដិបត្តិក្នុងកម្មដ្ឋាននេះ ឈ្មោះថា* ***បរិបុច្ឆា*** *។*

*ការប្រាកដរបស់និមិត្តសមាធិ ឈ្មោះថា* ***ឧបដ្ឋាន:*** *។*

*អប្បនាគឺឈាន របស់កម្មដ្ឋាន ឈ្មោះថា* ***អប្បនា*** *។*

*លក្ខណ:របស់កម្មដ្ឋាន ឈ្មោះថា* ***លក្ខណ:*** *។*

*កាលបានរៀនច្បាស់លាស់ក្នុងកម្មដ្ឋាននេះ ដែលមានសន្ធិ ៥ យ៉ាងនេះហើយ ឈ្មោះថា មិនលំបាកសូម្បីដល់ខ្លួនឯង សូម្បីអាចារ្យក៏មិនបានរំខាន ហើយចូលទៅក្នុងទីសេនាសនៈដ៏ស្ងាត់ ដូចដែលពោលមកហើយ ធ្វើមនសិការ:កម្មដ្ឋាននេះចុះ ទោះបីស្ថិតនៅក្នុងសំណាក់អាចារ្យក៏ដោយ មិនមានអាចារ្យក៏ដោយ ។*

អាចរិយុគ្គហតោ ឯកបទម្បិ អសម្មុយ្ហន្តេន ឥទំ អានាបានស្សតិកម្មដ្ឋានំ មនសិ កាតព្វំ ។

*អ្នកបដិបត្តិគប្បីធ្វើទុកក្នុងចិត្តនូវអានាបានស្សតិកម្មដ្ឋាននេះ បរិយត្តិដែលរៀនមកពីអាចារ្យ មិនត្រូវភ្លេច សូម្បីត្រឹមមួយបទ ។*

## វិធីចម្រើនអានាបានស្សតិសមាធិ
## តាមន័យរបស់អដ្ឋកថា

ក្នុងគម្ពីរវិសុទ្ធិមគ្គ និងសមន្តប្បាសាទិកាបានពោលទុកតែម្យ៉ាង ថា អ្នកចម្រើនអានាបានស្សតិ មុនដំបូងត្រូវតម្កល់សតិទុកត្រង់ខ្យល់ប៉ះត្រូវ គឺត្រង់ចុងច្រមុះ ឬត្រង់រឹមបបូរមាត់ខាងលើ ដរាបដល់ចិត្តជាអប្បនាសមាធិ ហើយនៅអធិប្បាយ ដល់វិធីបដិបត្តិអានាបានស្សតិសមាធិទុកទាំងអស់ មាន ៨ វិធី ដូចតទៅនេះ ៖

**១.គណនា** ការរាប់

**២.អនុពន្ធនា** ការជាប់តាមខ្យល់

**៣.ផុសនា** ការប៉ះ ដែលមានសេចក្ដីថា ខ្យល់ប៉ះត្រង់ណា ឲ្យតាំងសតិទុកត្រង់នោះ

**៤.ឋបនា** ការឈប់ គឺការធ្វើចិត្តឲ្យជាអប្បនាសមាធិ

**៥.សល្លក្ខណា** ការកំណត់ ក្នុងទីនេះសំដៅដល់ការពិចារណាក្នុងផ្លូវវិបស្សនា

**៦.វិវដ្ដនា** ការវិលត្រឡប់ ក្នុងទីនេះសំដៅ ដល់ការបានមគ្គ

**៧.បារិសុទ្ធិ** សេចក្ដីបរិសុទ្ធ ក្នុងទីនេះ សំដៅដល់ការបានផល

**៨.បដិបស្សនា** ការសំឡឹងមើលខាងក្រោយ ក្នុងទីនេះ សំដៅដល់ការពិចារណាខាងក្រោយអំពីកាលបានមគ្គផលរួច

ហើយ ដូចពិចារណាមើលមគ្គ ផល និព្វាន និង
ពិចារណាមើលថា កិលេសណាខ្លះ ដែលបានលះ
ហើយ កិលេសណាខ្លះ ដែលនៅមិនទាន់លះ ។

## គណនា

អ្នកបដិបត្តិដែលជាអាទិកម្មិកៈ ដែលផ្ដើមបដិបត្តិដំបូង មិនទាន់បានសម្រេចអប្បនាឈាននោះ ដំបូងត្រូវធ្វើ **គណនា** ការរាប់ខ្យល់ចូលក្នុងខណៈកំពុងចូល និងរាប់ខ្យល់ចេញ ក្នុងខណៈកំពុងចេញ ដើម្បីការពារចិត្តដែលរាយមាយ ឲ្យនៅតាំងស៊ប់ក្នុងទីតាំងតម្កល់សតិ ។

ការរាប់ខ្យល់នេះ នៅក្នុងសមន្តប្បាសាទិកា អដ្ឋកថាតតិយបារាជិក បានបញ្ជាក់ថា ៖

បណ្ដាមនសិការវិធី មានរាប់ខ្យល់ជាដើមនោះ កុលបុត្រអ្នកផ្ដើមបដិបត្តិអានាបានស្សតិនេះ គួរមនសិការៈនូវកម្មដ្ឋាននេះ ដោយការរាប់ខ្យល់ជាដំបូងសិន ។ កាលរាប់ខ្យល់ទៀតសោត មិនត្រូវរាប់ឲ្យតិចជាង ៥ មិនត្រូវរាប់ឲ្យលើសជាង ១០ មិនគួររាប់ឲ្យរំលងក្នុងចន្លោះឡើយ ។ ព្រោះការរាប់តិចជាង ៥ ចិត្តុប្បាទរមែងរើបម្រះក្នុងទីដែលចង្អៀត ដូចហ្វូងគោដែលឃាំងទុកក្នុងក្រោល ដែលចង្អៀត ដូច្នោះ ។ កាលរាប់លើសជាង១០ ចិត្តុប្បាទក៏រវល់ដោយការរាប់ប៉ុណ្ណោះ ។ ការរាប់រំលង ចិត្តរមែងញាប់ញ័រថា កម្មដ្ឋានរបស់យើងដល់ទីបំផុត ឬមិនដល់ហ្ន៎ ! ។

ការរាប់ខ្យល់នេះ មាន ២ វិធី គឺរាប់យឺត និងរាប់រហ័ស ។

**ការរាប់យឺត** គឺរាប់ក្នុងខណៈខ្យល់ចូលថា ១ ក្នុងខណៈខ្យល់ចេញថា ១ ទៀត (១-១) (២-២) (៣-៣) ជាដើម ។

រាប់ពួកទី ១ រាប់ ១-១,២-២, ៣-៣,៤-៤, ៥-៥,

រាប់ពួកទី ២ រាប់ ១-១,២-២, ៣-៣,៤-៤, ៥-៥, ៦-៦,

រាប់ពួកទី ៣ រាប់ ១-១,២-២, ៣-៣,៤-៤, ៥-៥, ៦-៦, ៧-៧,

រាប់ពួកទី ៤ រាប់ ១-១,២-២, ៣-៣,៤-៤, ៥-៥, ៦-៦, ៧-៧, ៨-៨,

រាប់ពួកទី ៥ រាប់ ១-១,២-២, ៣-៣,៤-៤, ៥-៥, ៦-៦, ៧-៧, ៨-៨, ៩-៩,

រាប់ពួកទី ៦ រាប់ ១-១,២-២, ៣-៣,៤-៤, ៥-៥, ៦-៦, ៧-៧, ៨-៨, ៩-៩, ១០-១០ ។

កាលបើរាប់ចប់ទាំង ៦ ពួកនេះហើយ ត្រូវរាប់សាថ្មីម្តងទៀត ចុះឡើង ៗ រហូតខ្យល់អស្សាសៈ និងបស្សាសៈ ដែលកំពុងចេញនិងចូល រមែងប្រាកដ ។ ពេលនោះ គប្បីលះបង់ការរាប់យឺត ហើយផ្តើមការរាប់លឿនៗ ម្តង ។

**ការរាប់លឿន** ខណៈខ្យល់កំពុងចូល រាប់ថា ១ ខណៈខ្យល់កំពុងចេញ រាប់ថា ២ (១-២-៣-៤-៥) ជាដើម ។

រាប់ពួកទី ១ រាប់ ១-២-៣-៤-៥,

រាប់ពួកទី ២ រាប់ ១-២-៣-៤-៥-៦,

រាប់ពួកទី ៣ រាប់ ១-២-៣-៤-៥-៦-៧,

រាប់ពួកទី ៤ រាប់ ១-២-៣-៤-៥-៦-៧-៨,

រាប់ពួកទី ៥ រាប់ ១-២-៣-៤-៥-៦-៧-៨-៩,

រាប់ពួកទី ៦ រាប់ ១-២-៣-៤-៥-៦-៧-៨-៩-១០ ។

នៅក្នុងសមន្តប្បាសាទិកា មានការសាកសួរពីវិធីរាប់ខ្យល់នេះថា សួរថា គប្បីរាប់ខ្យល់អស្សាសៈ និងបស្សាសៈនោះយូរប៉ុណ្ណា ?

ឆ្លើយថា គប្បីរាប់រហូតទាល់តែសតិវៀរចាកការរាប់ តាំងមាំនៅក្នុងអារម្មណ៍ គឺខ្យល់អស្សាសៈ និងបស្សាសៈ ។ ព្រោះថា ការរាប់ ក៏ដើម្បីកាត់វិតក្កៈ ដែលផ្សាយទៅខាងក្រៅ ហើយតាំងសតិទុកក្នុងអារម្មណ៍ គឺខ្យល់អស្សាសៈ និងបស្សាសៈប៉ុណ្ណោះ ។

អ្នកបដិបត្តិ កាលមនសិការៈនូវការរាប់យ៉ាងនេះហើយ គប្បីផ្ដើមមនសិការៈនូវ **អនុពន្ធនា** ដោយការតាមចង ។ ការឈប់រាប់ខ្យល់ ហើយតម្កល់សតិតាមខ្យល់ចូល និងខ្យល់ចេញ ជាប់តគ្នាទៅ ឈ្មោះថា **ការតាមចង** ។ ក៏ឯការតម្កល់សតិតាមនោះ មិនមែនដោយអំណាចការទៅតាមខ្យល់ខាងដើម កណ្ដាល និងទីបំផុតនៃខ្យល់នោះទេ ។ មែនពិត ផ្ចិតជាខាងដើម នៃខ្យល់ចេញខាងក្រៅ បេះដូងជាកណ្ដាល ច្រមុះជាទីបំផុត, ចុងច្រមុះជាខាងដើមនៃខ្យល់ចូលខាងក្នុង បេះដូងជាកណ្ដាល ផ្ចិតជាទីបំផុត ។ កាលអ្នកបដិបត្តិបញ្ជូនសតិទៅតាមខ្យល់ខាងដើមកណ្ដាល និងខាងចុងចិត្តរមែងរាយមាយ ក្រវល់ក្រវាយ និងញាប់ញ័រ ។ ដូចព្រះធម្ម-

សេនាបតីសារីបុត្រពោលទុកបដិសម្ភិទាមគ្គ (បិដកលេខ ៧០ ទំព័រ ៩១ ) ថា ៖

កាលភិក្ខុបញ្ជូនសតិទៅកាន់ខ្យល់ដកដង្ហើមចូល ខាងដើមកណ្ដាល និងខាងចុង កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅក្នុងខ្យល់ ដង្ហើមខាងក្នុង, កាលភិក្ខុបញ្ជូនសតិទៅកាន់ខ្យល់ដកដង្ហើមចេញ ខាងដើមកណ្ដាល និងខាងចុង កាយនិងចិត្ត រមែងជាសភាវៈ រញ្ជួយផង រំកើបផង ញាប់ញ័រផង ដោយសារចិត្ត ដែលបោះទៅក្នុង ខ្យល់ដង្ហើមខាងក្រៅ ។

តាមន័យដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងព្រះធម្មសេនាបតីបានសម្ដែង ហាមឃាត់ការបង្ខិតសតិទៅក្នុងទីដទៃជាដាច់ខាត ក្រៅពីតម្កល់សតិទុកត្រង់ចុងច្រមុះ ឬរិមបបូរមាត់ខាងលើ ។

**មានសំណាក់បដិបត្តិខ្លះ** បានបដិបត្តិដោយការបញ្ជូនសតិទៅតាំងទុកពេញសព្វាងកាយបន្តិចម្ដង ៗ ឬបង្ខិតសតិទៅទីដទៃ ចាប់តាំងពីក្បាលរហូតដល់ចុងជើង ពីចុងជើងទៅក្បាលវិញ ។ បច្ចេកទេសទាំងនេះគ្មានក្នុងព្រះពុទ្ធសាសនាឡើយ ។ ព្រះធម្មសេនាបតីសារីបុត្រ បានសម្ដែងហើយ ប្រសិនបើបង្ខិតសតិនោះ ចិត្តប្រាកដជារាយមាយ មិនតាំងនៅស៊ប់ក្នុងអារម្មណ៍តែមួយ មិនអាចទម្លុះដល់អប្បនាបានឡើយ ។

ចុះពាក្យថា **អនុពន្ធនា គឺការជាប់តាមខ្យល់** ក្នុងទីនេះ សំដៅសេចក្ដីដូចម្ដេច?

*ក្នុងទីនេះ សំដៅដល់* ***ការកំណត់ខ្យល់ឲ្យបានគ្រប់ខណៈចិត្តត្រង់ទីដែលខ្យល់ប៉ះនោះឯង*** *។*

*ក្នុងន័យនេះ បាលីពោលទុកជាគោលស្ពាន បង្ហាញឲ្យឃើញថា ឲ្យតាំងសតិទុកត្រង់ទីខ្យល់ប៉ះត្រូវប៉ុណ្ណោះ មានពាក្យដូច្នេះ ៖*

គណនានុពន្ធនាវសេន វិយ ហិ ផុសនាឋបនាវសេន វិសុំ មនសិការោ នត្ថិ។ ផុដ្ឋផុដ្ឋដ្ឋានេយេវ បន គណេន្តោ គណនាយ ច ផុសនាយ ច មនសិ ករោតិ ។ តត្ថេវ គណនំ បដិសំហរិត្វា តេ សតិយា អនុពន្ធន្តោ, អប្បនាវសេន ច ចិត្តំ ឋបេន្តោ អនុពន្ធនាយ ច ផុសនាយ ច ឋបនាយ ច មនសិ ករោតីតិ វុច្ចតិ។

*ការបដិបត្តិដោយវិធីគណនា និងអនុពន្ធនា មានវិធីផ្សេងគ្នា តែការបដិបត្តិដោយវិធីផុសនានិងឋបនា មិនផ្សេងគ្នាទេ ។ ការអ្នកបដិបត្តិកំណត់ រាប់ក្នុងទីខ្យល់ប៉ះត្រូវ ក៏រាប់ថា មនសិការៈដោយវិធីគណនា និងផុសនា និងកាលឈប់រាប់ ប្រើសតិជាប់តាមខ្យល់ចូល ខ្យល់ចេញចំពោះត្រង់ទីដែលខ្យល់ប៉ះត្រូវប៉ុណ្ណោះ រហូតតម្កល់ចិត្តទុកដោយអំណាចអប្បនា ក៏ហៅថា មនសិការវិធីដោយអនុពន្ធនា ផុសនា និង ឋបនា ។*

*(វិសុទ្ធិមគ្គ ភាគ ២ ទំព័រ ៥៤៨)*

តស្មា អនុពន្ធនាយ មនសិករោន្តេន អាទិមជ្ឈបរិយោសាន-វសេន ន មនសិ កាតព្វំ។ អបិច ខោ ផុសនាវសេន ច ឋបនាវសេន ច មនសិ កាតព្វំ។

ព្រោះហេតុនោះ អ្នកបដិបត្តិកាលធ្វើមនសិការៈ ដោយអនុពន្ធនា មិនត្រូវធ្វើមនសិការៈ ដោយអំណាចតាមខ្យល់ខាងដើម កណ្តាល និង ខាងចុងឡើយ ។ ម្យ៉ាងទៀត គប្បីធ្វើមនសិការៈដោយអំណាចផុសនា និង ឋបនា ។

(វិសុទ្ធិមគ្គ ភាគទី ២ ទំព័រ ៥៤៨)

## អនុពន្ធនាន័យ

អនុពន្ធនាន័យ គឺការតាំងចិត្តចំពោះទីប៉ះខ្យល់ ហើយជាប់តាមដឹង ខ្យល់ចូល ខ្យល់ចេញរឿយៗ ដោយមិនត្រូវរាប់ដោយ **គណនាន័យ** ។

ការតាមកំណត់ដោយអនុពន្ធនាន័យនេះ គប្បីបដិបត្តិរហូតដល់ ប្រាកដបដិភាគនិមិត្ត ដែលជាសភាវៈពិសេស ផ្សេងពីខ្យល់ចូល ខ្យល់ ចេញតាមប្រក្រតី មានលក្ខណៈដូចជា ពន្លឺ ប៉ុយសំឡី ដួងផ្កាយ ដួង កែវមណី ត្បូងរតនៈ ។ល។ កាលប្រាកដបដិភាគនិមិត្តដូច្នេះហើយ អ្នក បដិបត្តិគប្បីបញ្ឈប់អនុពន្ធនាន័យ ហើយកំណត់ខ្យល់ដោយឋបនាន័យ ត ទៅ ។

ម្យ៉ាងទៀត គណនាន័យ និងអនុពន្ធនាន័យទាំងពីរយ៉ាងនេះ នៅមិន ផុតពីស្ថានទីដែលខ្យល់ប៉ះត្រូវត្រង់ចុងច្រមុះ ឬរិមបបូរមាត់ខាងលើ ។

## ឋបនាន័យ

ឋបនាន័យ មានសេចក្តីថា បដិភាគនិមិត្តនោះ ជាបញ្ញត្តិពិសេស ប្រាកដឡើង ដូចជាអារម្មណ៍ថ្មី មិនមែនជាសភាវធម៌ ដែលមានប្រាកដ

ទើបរលត់ទៅឆាយ កាលរលត់ហើយក៏កើតថ្មីដោយលំបាក ។ អ្នកបដិបត្តិទើកគួរតាំងចិត្តទុកមាំក្នុងខ្យល់ ដែលជាបដិភាគនិមិត្ត មិនឲ្យរលត់ទៅ និងធ្វើឲ្យប្រាកដច្បាស់ក្រៃលែងឡើងតាមលំដាប់ ។

កាលទម្រុះបថបនានយហេយ អ្នកបដិបត្តិគួរចៀសចេញអសប្បាយៈ (សេចក្ដីមិនសប្បាយ) ៧ យ៉ាង និងសេពសប្បាយៈ (សេចក្ដីសប្បាយ) ៧ យ៉ាង និងចម្រើន **អប្បនាកោសល** (សេចក្ដីឈ្លាសក្នុងអប្បនា) ១០ យ៉ាង

**អសប្បាយៈ ៧ យ៉ាងគឺ**

១.ទីនៅដែលធ្វើឲ្យអ្នកបដិបត្តិវិនាស

២.ស្រុកបិណ្ឌបាតឆ្ងាយពេក

៣.ការជជែកគ្នាឥតប្រយោជន៍

៤.ការសមាគម

៥.អាហារ

៦.រដូវកាល

៧.ឥរិយាបថ

ចំណែកសប្បាយៈ ៧ យ៉ាង ដែលធ្វើឲ្យអ្នកបដិបត្តិចម្រើននោះ ផ្ទុយពីអសប្បាយៈនេះឯង ។

**អប្បនាកោសល ១០ យ៉ាង គឺ**

១.សេចក្ដីស្អាតរាងកាយ គ្រឿងប្រើប្រាស់ និងគ្រឿងស្លៀកដណ្ដប់

២.ការទទួលឥន្ទ្រិយ ៥ ឲ្យស្មើ

៣.សេចក្តីឈ្លាសក្នុងនិមិត្តគឺខ្យល់ចូល ខ្យល់ចេញ

៤.ការសង្កត់ចិត្តដែលព្យាយាមលើសពេក

៥.ផ្គងចិត្តដែលរួញរា

៦.ការគ្រប់សង្កត់ចិត្តដែលព្យាយាមលើសពេក

៧.ការដាក់ចិត្តកណ្តាលស្មើ

៨.ការគេចចេញពីអ្នកមិនមានសមាធិ

៩.ការគប់រកអ្នកមានសមាធិ

១០.ការមានចិត្តបង្អោនចូលទៅស្មើ ដើម្បីទម្មុះអប្បនាឈាន ។

អ្នកបដិបត្តិគប្បីប្រព្រឹត្តយ៉ាងនេះហើយ តាំងចិត្តទុកក្នុងបដិភាគនិមិត្តយ៉ាងមាំទាំ ដើម្បីចម្រើនភាវនាជាវេលាយូរ ដោយឋបនានយ័នេះ រហូតដល់ទម្មុះរូបាវចរចតុត្ថជ្ឈាន ។

## និមិត្ត ៣ សមាធិ ៣

ក្នុងការបដិបត្តិតាមវិធីទាំង ៣ គណនានយ័ អនុពន្ធនានយ័ និង ឋបនានយ័ អាចចំណែកជានិមិត្ត ៣ យ៉ាង និងភាវនាសមាធិ ៣ យ៉ាង ដូច្នេះ

*និមិត្ត ៣ យ៉ាង គឺ*

**១.បរិកម្មនិមិត្ត** (*អារម្មណ៍ដែលកើតក្នុងខណៈបរិកម្ម*) *គឺខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញ ដែលប្រាកដក្នុងវយៈគណនានយ*

**២.ឧគ្គហនិមិត្ត** (*អារម្មណ៍ជាប់ភ្នែក*) *គឺខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញ ក្នុងវយៈអនុពន្ធនានយ*

**៣.បដិភាគនិមិត្ត** (*អារម្មណ៍បញ្ញត្តិថ្មីដែលដូចអារម្មណ៍ដើម*) *គឺខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញ ដែលប្រាកដជាពន្លឺជាដើម ក្នុងវយៈឋបនានយ ។*

*សមាធិ ៣ យ៉ាង គឺ*

**១.បរិកម្មសមាធិ** (*សមាធិដែលកើតដោយការចម្រើនញយ ៗ*) *គឺសមាធិ ក្នុងខណៈកើតបរិកម្មនិមិត្ត និងឧគ្គហនិមិត្ត*

**២.ឧបចារសមាធិ** (*សមាធិដែលជិតនឹងប្រាកដ*) *គឺសមាធិក្នុងខណៈកើតបដិភាគនិមិត្តមុននឹងទម្ទុះអប្បនាឈានក្នុងវយៈឋបនា*

**៣.អប្បនាសមាធិ** (*សមាធិដែលមាំទាំ*) *គឺសមាធិក្នុងខណៈកើតបដិភាគនិមិត្ត កាលទម្ទុះរូបាវចរជ្ឈាន ៤ បានដល់ បឋមជ្ឈាន (ឈានទី ១) ទុតិយជ្ឈាន (ឈានទី ២) តតិយជ្ឈាន (ឈានទី ៣) និងចតុត្ថជ្ឈាន (ឈានទី ៤) តាមចតុក្កនយ (នយដែលពោលដល់ឈាន ៤) ។*

ក្នុងខណៈចម្រើនអានាបានស្សតិភាវនា អារម្មណ៍របស់កម្មដ្ឋានគឺខ្យល់ចូល និងខ្យល់ចេញ ដោយមានសតិដឹងរឿយៗ រហូតដល់ខ្យល់ល្អិតក្រៃលែងឡើង ហាក់បីដូចជាមិនមានខ្យល់ ក្នុងរយៈគណនា និងអនុពន្ធនា ។ ខណៈនោះ អ្នកបដិបត្តិគប្បីទ្រទ្រង់ចិត្តទុក ក្នុងទីដែលខ្យល់ប៉ះខ្ទប់ តាមដើម ហើយកំណត់ដឹងអារម្មណ៍ដ៏ល្អិតសុខុមនោះ ឲ្យច្បាស់ ។ កាលកំណត់ដឹងហើយ អារម្មណ៍នឹងប្រាកដច្បាស់ឡើង ៗ តមកមិនយូរបដិភាគនិមិត្តក៏នឹងប្រាកដ ។ អ្នកបដិបត្តិនឹងទម្លុះឧបចារជ្ឈាន ពោលគឺឧបចារសមាធិ ដែលជាកាមាវចរភាវនា ដែលគ្របសង្កត់ នីវរណៈ ៥ បាន ។

សភាពល្អិតរបស់អារម្មណ៍ដែលប្រាកដនៅហើយ បាត់ទៅវិញរបស់កម្មដ្ឋានប្រភេទនេះ តាមន័យអដ្ឋកថា មិនបានសំដៅដល់ផលអំពីការតាំងចិត្តបដិបត្តិ ដើម្បីឲ្យខ្យល់ល្អិត ។ តែសំដៅដល់សេចក្តីល្អិតដែលប្រព្រឹត្តទៅខ្លួនឯងតាមលំដាប់ ។ ចំណែកក្នុងព្រះបាលីវារៈចុងបំផុតពោលទុកថា ៖

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ, បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។

ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់នូវខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់នូវខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។

ព្រះបាលីនេះ សំដៅដល់ ការតាំងចិត្តក្នុងការរម្ងាប់ខ្យល់ឲ្យល្អិតក្នុងរយៈអនុពន្ធនាប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងរយៈដែលអារម្មណ៍ល្អិត អ្នកបដិបត្តិមិនឈ្លាសក្នុងកម្មដ្ឋាន អាចសម្គាល់ថា មិនមានខ្យល់ចូល ខ្យល់ចេញ ហើយក៏ឈប់ចម្រើនកម្មដ្ឋាន គប្បីប្រយ័ត្នបំផុតត្រង់ខនេះ ។

## ការប្រៀបធៀបព្រះបាលី និងអដ្ឋកថា

(អានាបានទីបនី រចនាដោយព្រះលេឌីស្យាដោ)

វិធីចម្រើនអានាបានស្សតិកម្មដ្ឋាន ៤ន័យ ដែលបានត្រាស់ទុកក្នុងព្រះបាលី អាចប្រៀបធៀបជាមួយគណនាន័យជាដើម ក្នុងគម្ពីរអដ្ឋកថា ។ ការតាំងចិត្តចំពោះក្នុងទីដែលខ្យល់ប៉ះត្រូវហើយ រាប់គណនាន័យ ចាត់ថាបានចម្រើនសតិរលឹកដឹងខ្យល់ចូល ខ្យល់ចេញ រាប់ជាការបដិបត្តិដើម្បីបញ្ឈប់សេចក្តីរាយមាយរបស់ចិត្ត ក្នុងខណៈបដិបត្តិធម៌ និងជារយៈដែលមិនបានតាមដឹងសភាវៈវែងខ្លីរបស់ខ្យល់ ទើបស្របជាមួយព្រះបាលីថា

សោ សតោវ អស្សសតិ សតោវ បស្សសតិ ។

ភិក្ខុនោះ ជាអ្នកមានសតិដកដង្ហើមចូល ជាអ្នកមានសតិដកដង្ហើមចេញ ។

និងគម្ពីរអដ្ឋកថា ក៏អធិប្បាយថា

ពហិ វិសដវិតក្កវិច្ឆេទំ កត្វា អស្សាសបស្សាសារម្មណោ សតិសណ្ឋាបនត្ថំយេវ ហិ គណនា ។

ពិតមែនហើយ គណនានាន័យ រមែងមានដើម្បីធ្វើការកាត់សេចក្តីត្រិះរិះ ដែលស្ទុះទៅខាងក្រៅ ហើយទ្រទ្រង់សតិទុកមាំក្នុងអារម្មណ៍ គឺខ្យល់ចូល និងខ្យល់ចេញតែម្យ៉ាង ។

ការជាប់តាមខ្យល់ តាមអនុពន្ធនាន័យ ចាត់ជាការតាំងចិត្តចំពោះរឿយៗ ព្រមទាំងទទួលដឹងសភាវៈវែងខ្លី របស់ខ្យល់ ទើបស្របជាមួយព្រះបាលីក្នុងវារៈទី ២ ថា

ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ, ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ

កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង, កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង

រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ, រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ

កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី , កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី ។

ការទទួលដឹងសភាវៈវែងខ្លីរបស់ខ្យល់នោះ មិនមែនជាការតាមដឹងខាងដើម កណ្តាល និងខាងចុង របស់ខ្យល់ ។ តែជាការតាំងចិត្តទទួលដឹងសភាពវែងខ្លី របស់ខ្យល់ដែលប៉ះខ្ទប់នៅត្រង់ចុងច្រមុះ ឬត្រង់រឹមបបូរមាត់ប៉ុណ្ណោះ ។ កាលដកដង្ហើមចូលវែង ខ្យល់ក៏វែង កាលដកដង្ហើមខ្លី ការប៉ះ

ខ្ទប់របស់ខ្យល់ក៏ខ្ទី ដូច្នោះ សភាវៈវែងខ្ទីរបស់ខ្យល់ ក្នុងទីប៉ះខ្ទប់ ទើបជាសភាពវែងខ្ទីរបស់ខ្យល់ដកដង្ហើមក្នុងរឿងនេះ ។

សភាពរបស់ចិត្តដោយទូទៅនោះ មានលក្ខណៈផ្សាយទៅទទួលដឹងស្ថានទីផ្សេងៗ បាន អ្នកបដិបត្តិអាចដឹងក្នុងពេលខ្លះថា ចិត្តដែលទទួលដឹងសភាវៈប៉ះខ្ទប់បានចូលទៅជ្រៅ ឬផុតចេញឋានៈដែលខ្យល់ប៉ះខ្ទប់នោះ ។

ម្យ៉ាងទៀត ក្នុងការចម្រើនសតិរលឹកដឹងសភាវៈវែងខ្ទីនេះ អ្នកបដិបត្តិគប្បីទ្រទ្រង់ចិត្តទុកក្នុងទីប៉ះខ្ទប់ និងទទួលដឹងសភាវៈវែងខ្ទីរបស់ខ្យល់ដកដង្ហើមរហូតទាំងខាងដើម កណ្ដាល និងខាងចុង ពោលគឺ កាលដកដង្ហើមចូល ឲ្យទទួលដឹងខ្យល់ត្រង់ចុងច្រមុះជាដើម រហូតដល់ខ្យល់ខាងក្នុងផ្ទៃពោះ ។ កាលដកដង្ហើមចេញ ឲ្យទទួលដឹងខ្យល់ក្នុងផ្ទៃពោះជាដើមទៅរហូតដល់ខ្យល់ត្រង់ចុងច្រមុះ សមពិតដូចសាធកៈថា

៣.សព្វកាយបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, សព្វកាយបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្ដាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្ដាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចេញ ។

*អ្នកបដិបត្តិដែលទទួលដឹងកងខ្យល់តាំងតែខាងដើម កណ្តាល និង ខាងចុងហើយ គប្បីចម្រើនសតិបន្តទៅ ដោយត្រិះរិះថា យើងនឹងរម្ងាប់កង ខ្យល់ឲ្យល្អិត រហូតដូចរលត់ទៅ ដោយស្រេបតាមព្រះបាលីថា*

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ, បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។

*ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់នូវខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់នូវខ្យល់ដ៏ គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

*ក្នុងគម្ពីរអដ្ឋកថាបានពោលដល់សេចក្តីល្អិត និងការរលត់ទៅឯង របស់កងខ្យល់តាំងតែផ្តើមចម្រើនគណនានយ ។ អ្នកបដិបត្តិខ្លះ លោក កើតសភាវៈដូចដែលពោលមកនេះ និងមានអ្នកខ្លះ អន្ទុយសមាធិ ស្រាប់ តែកាយអណ្តែតឡើងអំពីទីអន្ទុយ ៤ ធ្នាប់ ដោយអំណាចឧព្វេង្គាបីតិ តាម ពាក្យអធិប្បាយក្នុងគម្ពីរអដ្ឋកថាថា*

កស្សចិ បន គណនាវសេនេវ មនសិការកាលតោ បភុតិ អនុក្កមតោ ឱឡារិកអស្សាសបស្សាសនិរោធវសេន កាយទរថេ វូបសន្តេ កាយោបិ ចិត្តម្បិ លហុកំ ហោតិ ។ សរីរំ អាកាសេ លង្ឃនាការប្បត្តំ វិយ ហោតិ ។

*ម្យ៉ាងទៀត កាលសេចក្តីក្តៅរោលរាល ក្នុងរាងកាយស្ងប់ហើយ ទាំងកាយ និងចិត្តក៏មានសភាវៈស្រាល រាងកាយដូចជាអណ្តែតឡើងទៅ*

*ក្នុងអាកាស ដោយអំណាចរបស់ការរលត់ទៅនៃខ្យល់ចូល និងខ្យល់ចេញ ដែលគ្រោតគ្រាតតាមលំដាប់តាំងតែវេលា ដែលអ្នកខ្វះផ្តើមចម្រើនសតិ កំណត់ដឹងតាមគណនានយ័ ។*

*កាលអ្នកបដិបត្តិតម្កល់សតិទុកក្នុងស្ថានទីប៉ះយ៉ាងប្រាកដ រហូតដល់ខ្យល់ដង្ហើមរលត់ទៅយ៉ាងនេះ ក៏នឹងទទួលដឹងខ្យល់ដង្ហើមដែលប្រចក្សមក ។ម្យ៉ាងទៀត ក្នុងខណៈនោះ ចាត់ថា បដិភាគនិមិត្តបានប្រាកដឡើងហើយ អ្នកបដិបត្តិបានទម្លុះឧបចារសមាធិ ដែលគ្របសង្កត់នីវរណៈ។*

## ឧបកិលេស មាន ១៨ យ៉ាង

*(ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧០ ទំព័រ ៨៨)*

*ឧបកិលេសនៃការចម្រើនអានាបានស្សតិ មាន ១៨ យ៉ាង ចែកចេញជា ៣ ឆក្កៈ ក្នុងឆក្កៈនីមួយៗ មាន ៦ យ៉ាង ដូចតទៅ ៖*

### ឆក្កៈទី ១

១.អស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ អជ្ឈត្ត-វិក្ខេបគតំ ចិត្តំ សមាធិស្ស បរិបន្ថោ *កាលបញ្ជូនសតិទៅតាមខាងដើម កណ្តាល និងខាងចុងនៃខ្យល់ដកដង្ហើមចូល ចិត្តដែលបោះទៅខាងក្នុង ជាអន្តរាយដល់សមាធិ ។*

២.បស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ ពហិទ្ធា-វិក្ខេបគតំ ចិត្តំ សមាធិស្ស បរិបន្ថោ *កាលបញ្ជូនសតិទៅតាមខាងដើម*

កណ្តាល និងខាងចុងនៃខ្យល់ដកដង្ហើមចេញ ចិត្តដែលបោះទៅខាងក្រៅ ជាអន្តរាយដល់សមាធិ ។

៣.អស្សាសបដិកង្ខនា និកន្តិ តណ្ហាចរិយា សមាធិស្ស បរិបន្ថោ សេចក្តីប្រាថ្នាចំពោះខ្យល់ដកដង្ហើមចូល សេចក្តីត្រេកត្រអាល សេចក្តីប្រព្រឹត្តិនៃចំណង់ ជាអន្តរាយដល់សមាធិ ។

៤.បស្សាសបដិកង្ខនា និកន្តិ តណ្ហាចរិយា សមាធិស្ស បរិបន្ថោ សេចក្តីប្រាថ្នាចំពោះខ្យល់ដកដង្ហើមចេញ សេចក្តីត្រេកត្រអាល សេចក្តីប្រព្រឹត្តិនៃចំណង់ ជាអន្តរាយដល់សមាធិ ។

៥.អស្សាសេនាភិតុន្នស្ស បស្សាសបដិលាភេ មុច្ឆនា សមាធិស្ស បរិបន្ថោ កាលដកដង្ហើមចូលវែង ឬដកដង្ហើមចូលខ្លីលើសពេក ចិត្តនឹងស្រវឹងជាប់នៅជាមួយខ្យល់ចូល ដូច្នោះ ក្នុងវេលាដកដង្ហើមចេញ ក៏ភ្លេចសតិ មិនអាចកំណត់ខ្យល់ចេញបានគ្រប់ខណៈចិត្ត ជាអន្តរាយដល់សមាធិ ។

៦.បស្សាសេនាភិតុន្នស្ស អស្សាសបដិលាភេ មុច្ឆនា សមាធិស្ស បរិបន្ថោ កាលដកដង្ហើមចេញវែង ឬដកដង្ហើមចេញខ្លីលើសពេក ចិត្តនឹងស្រវឹងជាប់នៅជាមួយខ្យល់ចេញ ដូច្នោះ ក្នុងវេលាដកដង្ហើមចូល ក៏ភ្លេចសតិ មិនអាចកំណត់ខ្យល់ចូលបានគ្រប់ខណៈចិត្ត ជាអន្តរាយដល់សមាធិ ។

**ឆក្កៈទី ២**

១.និមិត្តំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ *កាលនឹកដល់និមិត្ត ចិត្តរមែងញាប់ញ័រគឺមិនតាំងនៅ ក្នុងខ្យល់ដកដង្ហើមចូល ជាអន្តរាយដល់សមាធិ ។*

២.អស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ *កាលនឹកដល់ខ្យល់ចូល ចិត្តរមែងញាប់ញ័រគឺមិនតាំងនៅក្នុងនិមិត្ត ជាអន្តរាយដល់សមាធិ ។*

៣.និមិត្តំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ *កាលនឹកដល់និមិត្ត ចិត្តរមែងញាប់ញ័រគឺមិនតាំងនៅ ក្នុងខ្យល់ដកដង្ហើមចេញ ជាអន្តរាយដល់សមាធិ ។*

៤.បស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ *កាលនឹកដល់ខ្យល់ចេញ ចិត្តរមែងញាប់ញ័រគឺមិនតាំងនៅក្នុងនិមិត្ត ជាអន្តរាយដល់សមាធិ ។*

៥.អស្សាសំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ *កាលនឹកដល់ខ្យល់ចូល ចិត្តរមែងញាប់ញ័រ គឺមិនតាំងនៅក្នុងខ្យល់ចេញ ជាអន្តរាយដល់សមាធិ ។*

៦.បស្សាសំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ *កាលនឹកដល់ខ្យល់ចេញ ចិត្តរមែងញាប់ញ័រ គឺមិនតាំងនៅក្នុងខ្យល់ចូល ជាអន្តរាយដល់សមាធិ ។*

## **ឆក្កៈទី ៣**

១.អតីតានុធាវនំ ចិត្តំ វិក្ខេបានុបតិតំ សមាធិស្ស បរិបន្ថោ ចិត្ត *ដែលស្ទុះទៅរកអារម្មណ៍ជាអតីតៈ នឹងធ្លាក់ទៅក្នុងសេចក្តីរាយមាយ ជាអន្តរាយដល់សមាធិ ។*

២.អនាគតបដិកង្ខនំ ចិត្តំ វិកម្បិតំ សមាធិស្ស បរិបន្ថោ ចិត្ត *ដែលប្រាថ្នារកអារម្មណ៍ ជាអនាគត ដែលញាប់ញ័រ ជាអន្តរាយដល់សមាធិ ។*

៣.លីនំ ចិត្តំ កោសជ្ជានុបតិតំ សមាធិស្ស បរិបន្ថោ ចិត្តដែលរួញរា *ធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស ជាអន្តរាយដល់សមាធិ ។*

៤.អតិបគ្គហិតំ ចិត្តំ ឧទ្ធច្ចានុបតិតំ សមាធិស្ស បរិបន្ថោ ចិត្តដែល *ផ្គងហួសពេក ធ្លាក់ទៅក្នុងឧទ្ធច្ចៈ ជាអន្តរាយដល់សមាធិ ។*

៥.អភិនតំ ចិត្តំ រាគានុបតិតំ សមាធិស្ស បរិបន្ថោ ចិត្តដែលបង្អោន *ទៅកាន់ឥដ្ឋារម្មណ៍ ក៏នឹងធ្លាក់ទៅក្នុងរាគៈ ជាអន្តរាយដល់សមាធិ ។*

៦.អបនតំ ចិត្តំ ព្យាបាទានុបតិតំ សមាធិស្ស បរិបន្ថោ ចិត្តដែល *បង្អោនទៅកាន់អនិដ្ឋារម្មណ៍ ក៏នឹងធ្លាក់ទៅក្នុងព្យាបាទ ជាអន្តរាយដល់សមាធិ ។*

# និមិត្ត អស្សាសៈ និងបស្សាសៈមិនប្រាកដជាអន្តរាយដល់សមាធិ

(*ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ៧០ ទំព័រ ១០៤*)

*ព្រះធម្មសេនាបតីសារីបុត្របានសម្តែងថា ៖*

និមិត្តំ អស្សាសបស្សាសា   អនារម្មណាមេកចិត្តស្ស
អជានតោ ច តយោ ធម្មេ   ភាវនា នុបលព្ភតិ ។

និមិត្តំ អស្សាសបស្សាសា   អនារម្មណាមេកចិត្តស្ស
ជានតោ ច តយោ ធម្មេ   ភាវនា ឧបលព្ភតិ ។

*និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ ធម៌ បីយ៉ាងនេះ មិនមែនអារម្មណ៍នៃចិត្តតែមួយដួងទេ បើអ្នកណា* ***មិនដឹងធម៌បី*** *យ៉ាងនេះ ភាវនារបស់បុគ្គលនោះ* ***រមែងមិនសម្រេច*** *។*

*និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ ធម៌បីយ៉ាងនេះ មិនមែនអារម្មណ៍នៃចិត្តតែមួយដួងទេ បើអ្នកណាដឹងធម៌បីយ៉ាងនេះ ភាវនារបស់បុគ្គលនោះ* ***រមែងសម្រេច*** *។*

*ក្នុងរឿងអានាបានស្សតិនេះ ចិត្តមានអស្សាសៈ ជាអារម្មណ៍មួយដួង ចិត្តមានបស្សាសៈជាអារម្មណ៍មួយដួង ចិត្តមាននិមិត្តជាអារម្មណ៍មួយដួង ។ ប្រសិនបើ ធម៌បីយ៉ាងនេះ មិនមានដល់អ្នកណា កម្មដ្ឋានរបស់*

អ្នកនោះ រមែងមិនដល់អប្បនា សូម្បីតែត្រឹមឧបចារៈក៏មិនដល់ ។ តែបើធម៌បីយ៉ាងនេះ មានដល់អ្នកណា កម្មដ្ឋានរបស់អ្នកនោះ រមែងដល់ឧបចារៈ និងអប្បនា ។

តើនិមិត្តក្នុងទីនេះ បានដល់អ្វី?

**និមិត្តក្នុងទីនេះ** បានដល់ ចុងច្រមុះ ឬរីមបបូរមាត់ ដែលជាទីតាំងនៃខ្យល់ប៉ះ ក្នុងខណៈដកដង្ហើមចូល និងដកដង្ហើមចេញ ដូចអដ្ឋកថាបដិសម្ភិទាមគ្គ ឈ្មោះ សទ្ធម្មប្បកាសិនីបញ្ជាក់ថា ៖

និមិត្តន្តិ អស្សាសបស្សាសានំ ផុសនដ្ឋានំ។ អស្សាសបស្សាសា ហិ ទីឃនាសិកស្ស នាសាបុដំ ឃដ្ដេន្តា បវត្តន្តិ, រស្សនាសិកស្ស ឧត្តរោដ្ឋំ។ យទិ ហិ អយំ យោគី តំ និមិត្តមេវ អាវជ្ជតិ, តស្ស និមិត្តមេវ អាវជ្ជមានស្ស អស្សាសេ ចិត្តំ វិកម្បតិ, ន បតិដ្ឋាតីតិ អត្ថោ។ តស្ស តស្មិំ ចិត្តេ អប្បតិដ្ឋិតេ សមាធិស្ស អភាវតោ តំ វិកម្បនំ សមាធិស្ស បរិបន្ថោ។ យទិ អស្សាសមេវ អាវជ្ជតិ, តស្ស ចិត្តំ អព្ភន្តរបវេសនវសេន វិក្ខេបំ អាវហតិ, និមិត្តេ ន បតិដ្ឋាតិ, តស្មា និមិត្តេ វិកម្បតិ។ ឥមិនា នយេន សេសេសុបិ យោជនា កាតព្វា។

ពាក្យថា **និមិត្ត** សំដៅដល់ស្ថានទី ដែលប៉ះត្រូវរបស់អស្សាសៈនិងបស្សាសៈ ។ ពិតមែន សម្រាប់មនុស្សដែលមានច្រមុះវែង អស្សាសៈនិងបស្សាសៈ ដែលចូលនិងចេញ រមែងប៉ះខ្ទប់ខាងក្នុងប្រហោងច្រមុះ, សម្រាប់មនុស្សដែលមានច្រមុះខ្លី អស្សាសៈនិងបស្សាសៈ រមែងប៉ះត្រង់រីមបបូរមាត់

ខាងលើ ។ បើយោគីនេះ ដល់និមិត្តនោះតែម្យ៉ាង គឺស្ថានទីដែល ខ្យល់ប៉ះ ចិត្តយោគីអ្នកដល់និមិត្តតែម្យ៉ាងនោះ រមែងញាប់ញ័រក្នុងអស្សាសៈ គឺមិន តាំងនៅក្នុងអស្សាសៈ ។ កាលចិត្តរបស់យោគីនោះ មិនតាំងនៅក្នុង អស្សាសៈ ក៏រមែងមានសេចក្តីញាប់ញ័រ ព្រោះមិនមានសមាធិ ទើបជា អន្តរាយដល់សមាធិ ។ ប្រសិនបើ យោគីនឹកដល់អស្សាសៈតែម្យ៉ាង ចិត្ត របស់យោគីនោះ ក៏នាំសេចក្តីរវើរវាយមកទៀត ដោយអំណាចរបស់ អស្សាសៈដែលចូលទៅខាងក្នុងចិត្តមិនតាំងនៅ ក្នុងនិមិត្ត, ព្រោះហេតុ នោះ ទើបឈ្មោះថា រមែងញាប់ញ័រក្នុងនិមិត្ត សូម្បីន័យដ៏សេស គប្បីប្រកប សេចក្តីតាមន័យនេះ ។

ព្រះធម្មសេនាបតីសារីបុត្រធ្វើសេចក្តីអធិប្បាយ (ខុទ្ទកនិកាយ បដិ- សម្ភិទាមគ្គ ៧០ ទំព័រ ១០៥) ថា ៖

ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាអារម្មណ៍នៃចិត្តមួយផង ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាមិនប្រាកដផង តើដូចម្តេច ចិត្តមិនដល់នូវសេចក្តី រាយមាយ ១ ព្យាយាមប្រាកដ ១ កិច្ចញ៉ាំងព្យាយាមឲ្យសម្រេចបាននូវ គុណវិសេស ១ ។ ប្រៀបដូច ដើមឈើដែលគេដាំលើភូមិភាគរាបស្មើ បុរសអារដើមឈើនោះ ដោយរណារ សតិរបស់បុរសរមែងតាំងឡើង ចំពោះដើមឈើ ដោយអំណាចនៃធ្មេញរណារ ដែលពាល់ត្រូវ បុរសមិន ធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារ ដែលទាញមកទាញទៅ ធ្មេញរណារ ដែល ទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង បុរសរមែងញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ឯការចូល

ទៅជិតចងនិមិត្ត ទុកដូចដើមឈើដែលគេដាំលើភូមិភាគ ដរាបស្មើខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញ ទុកដូចធ្មេញរណារ ភិក្ខុតម្កល់ទុកនូវសតិត្រង់ចុងច្រមុះឬរិមបបូរមាត់ ហើយអង្គុយមិនធ្វើទុកក្នុងចិត្តនូវខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ទាំងដែលមក ទាំងដែលទៅ ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ដែលមកក្តី ដែលទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង ភិក្ខុញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ប្រៀបដូចជាសតិ របស់បុរសតាំងឡើងចំពោះដើមឈើ ដោយអំណាចនៃធ្មេញរណារ ដែលពាល់ត្រូវបុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារ ដែលទាញមក ទាញទៅ ធ្មេញរណារដែលទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមប្រាកដផង បុរសញ៉ាំងព្យាយាមឲ្យសម្រេចផង បាននូវគុណវិសេសផង ។

អានាបានស្សតិ យស្ស  បរិបុណ្ណា សុភាវិតា
អនុបុព្វំ បរិចិតា  យថា ពុទ្ធេន ទេសិតា
សោ ឥមំ លោកំ បភាសេតិ  អព្ភា មុត្តោវ ចន្ទិមា

អានាបានស្សតិ បុគ្គលណាបានបំពេញហើយ ចម្រើនហើយ
ដោយប្រពៃ សន្សំហើយដោយលំដាប់ ឲ្យដូចព្រះពុទ្ធទ្រង់
សម្តែងទុកហើយ បុគ្គលនោះឯង រមែងញ៉ាំងលោកនេះ
ឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទ ដែលផុតស្រឡះចាកពពក ។

# ញាណក្នុងវោទាន ១៣
# វិធីកែឧបកិលេស១៨

*(បដិសម្ភិទាមគ្គ លេខ ៧០ ទំព័រ ៩៤)*

*ព្រះធម្មសេនាបតីសារីបុត្របានអធិប្បាយអំពីឧបកិលេស ១៨ យ៉ាង ដែលកើតឡើងហើយ នឹងគប្បីកែខៃយ៉ាងណា ?*

*វិធីកែខៃនោះ ព្រះធម្មសេនាបតីសារីបុត្រហៅថា* **វោទាន** *ដែលតាមស័ព្ទប្រែថា ការធ្វើឲ្យបរិសុទ្ធឬការធ្វើឲ្យផូរផង់ ការធ្វើឲ្យស្អាត ។*

**វោទាន** *មាន ៣ ឯកត្តៈ ។ ឯកត្តៈទី ១ មាន ៦, ឯកត្តៈទី ២ មាន ៤, ឯកត្តៈទី ៣ មាន ៣ ។*

### ឯកត្តៈទី ១ មាន ៦

១.អតីតានុធាវនំ ចិត្តំ វិក្ខេបានុបតិតំ; តំ វិវជ្ជយិត្វា ឯកដ្ឋានេ សមាទហតិ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ *ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីតៈ ដែលធ្លាក់ទៅក្នុងសេចក្តីរាយមាយ គប្បីព្យាយាមលះ ហើយតាំងចិត្តទុកឲ្យមាំក្នុងទីដែលខ្យល់ប៉ះត្រូវ ។*

២.អនាគតបដិកង្ខនំ ចិត្តំ វិកម្បិតំ; តំ វិវជ្ជយិត្វា តត្ថេវ អធិមោចេតិ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ *កាលចិត្តនឹកដល់អារម្មណ៍ដែលជាអនាគត កើតការញាប់ញ័រ គឺមិនស្ងប់ឬមិនស្ងៀម ក៏ឲ្យលះ ហើយព្យាយាមតាំងចិត្តទុកឲ្យមាំនៅក្នុងទីដែលខ្យល់ប៉ះត្រូវ ។*

៣.លីនំ ចិត្តំ កោសជ្ជានុបតិតំ; តំ បគ្គណ្ហិត្វា កោសជ្ជំ បជហាតិ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ *ចិត្តដែលរួញរា ដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស ក៏ឲ្យលើកចិត្តឡើងដោយចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈ ។*

៤.អតិបគ្គហិតំ ចិត្តំ ឧទ្ធច្ចានុបតិតំ; តំ វិនិគ្គណ្ហិត្វា ឧទ្ធច្ចំ បជហាតិ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ *ចិត្តផ្គងហួសពេក ដែលធ្លាក់ទៅក្នុងឧទ្ធច្ចៈ ក៏ឲ្យសង្កត់ចិត្តនោះ ដោយចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ ហើយក៏លះសេចក្តីរាយមាយនោះបាន ។*

៥.អភិនតំ ចិត្តំ រាគានុបតិតំ; តំ សម្បជានោ ហុត្វា រាគំ បជហាតិ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ *កាលចិត្តបង្អោនទៅក្នុងឥដ្ឋារម្មណ៍ ធ្លាក់ទៅកាន់អំណាចរាគៈ ក៏ឲ្យមានសម្បជញ្ញៈ ហើយក៏ឲ្យលះនូវរាគៈនោះ បាន។*

៦.អបនតំ ចិត្តំ ព្យាចាទានុបតិតំ; តំ សម្បជានោ ហុត្វា ព្យាចាទំ បជហាតិ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ *កាលចិត្តដែលបង្អោនទៅកាន់អនិដ្ឋារម្មណ៍ ដែលមិនជាទីពេញចិត្ត ធ្លាក់ទៅកាន់អំណាចព្យាបាទ ក៏ឲ្យមានសម្បជញ្ញៈ ហើយក៏លះព្យាបាទនោះបាន ។*

## ឯកត្តៈទី ២ មាន ៤

១.នានត្តុបដ្ឋានេកត្តំ សេចក្តីប្រាកដនៃការបរិច្ចាគទាន

២.សមថនិមិត្តុបដ្ឋានេកត្តំ សេចក្តីប្រាកដនៃនិមិត្ត

៣.វយលក្ខណុបដ្ឋានេកត្តំ សេចក្តីប្រាកដនៃវយលក្ខណៈ

៤.និរោធុបដ្ឋានេកត្តំ សេចក្តីប្រាកដនៃនិរោធ ។

ព្រះធម្មសេនាបតីសារីបុត្រនៅធ្វើសេចក្តីអធិប្បាយថា ឯកត្តៈគឺ សេចក្តីប្រាកដនៃការបរិច្ចាគទាន រមែងកើតមាន ដល់បុគ្គលអ្នកមាន អធ្យាស្រ័យក្នុងការលះវត្ថុទាន, ឯកត្តៈ គឺសេចក្តីប្រាកដនៃសមថនិមិត្ត រមែងកើតមានដល់អ្នកមាំក្នុងអធិចិត្ត (គឺសមាធិចិត្ត), ឯកត្តៈគឺសេចក្តី ប្រាកដនៃវយលក្ខណៈ រមែងកើតដល់អ្នកចម្រើនវិបស្សនា, ឯកត្តៈគឺសេចក្តី ប្រាកដនៃនិរោធ រមែងកើតដល់ព្រះអរិយបុគ្គលទាំងឡាយ ចិត្តដែលដល់ នូវឯកត្តៈ ដោយស្ថានទាំង ៤ នេះ ឈ្មោះថា ជាធម្មជាតជ្រះថ្លា ដោយ បដិបទាវិសុទ្ធិផង ឈ្មោះថា ការចម្រើនរឿយៗ នៃការសំឡឹងពិនិត្យផង ឈ្មោះថា រីករាយដោយញាណផង ។

## ឯកត្តៈទី ៣ មាន ៣

១.បដិបទាវិសុទ្ធិ ចិត្តបរិសុទ្ធផូរផង់ដោយបដិបទាវិសុទ្ធិ

២.ឧបេក្ខានុព្រូហនា ចិត្តច្រើនដោយឧបេក្ខា

៣.សម្បហំសនា ចិត្តរីករាយដោយញាណ ។

ព្រះធម្មសេនាបតីសារីបុត្រលើកឡើងសួរក្នុងចំណុចឯកត្តៈទី ៣ ថា
-បឋមជ្ឈាន មានអ្វីជាខាងដើម ?

-បឋមជ្ឈាន មានអ្វីជាកណ្តាល ?

-បឋមជ្ឈាន មានអ្វីជាខាងចុង ?

ព្រះធម្មសេនាបតីសារីបុត្រឆ្លើយក្នុងចំណុចឯកត្តៈទី ៣ ថា

-បឋមជ្ឈាន មានបដិបទាវិសុទ្ធិ ជាខាងដើម

-បឋមជ្ឈាន មានការចម្រើនរឿយៗនៃការសំឡឹងពិនិត្យ ជាកណ្តាល

-បឋមជ្ឈាន មានការរីករាយព្រម ជាខាងចុង ។

សូមពិនិត្យមើលសេចក្តីពិស្តារដោយខ្លួនឯង ក្នុងបិដកលេខ ៧០ ចាប់ពីទំព័រ ៩៥ ដល់ទំព័រ ១០៤ ។

## ឧបសគ្គដោយឆ្ងនៅនិងឧបការៈរបស់សមាធិ ១៦

(បដិសម្ភិទាមគ្គ លេខ ៧០ ទំព័រ ៨៣)

ក្នុងគម្ពីរបដិសម្ភិទាមគ្គ ព្រះធម្មសេនាបតីសារីបុត្របានពោលទុកថា អ្នកដែលចម្រើនអានាបានស្សតិបានផល ត្រូវឲ្យបានដឹងច្បាស់ដោយបញ្ញាថា អ្វីជាអន្តរាយដល់សមាធិ ? អ្វីជាឧបការៈដល់សមាធិ ? ទើបប្រកាសសម្តែងដូចតទៅ ៖

## ឧបសគ្គដោយឆ្ងល់របស់សមាធិ ៨ យ៉ាង

១.កាមច្ឆន្ទោ សមាធិស្ស បរិបន្ថោ *កាមច្ឆន្ទៈជាអន្តរាយដល់សមាធិ*

២.ព្យាបាទោ សមាធិស្ស បរិបន្ថោ *ព្យាបាទៈជាអន្តរាយដល់សមាធិ*

៣.ថិនមិទ្ធំ សមាធិស្ស បរិបន្ថោ *ថិនមិទ្ធៈជាអន្តរាយដល់សមាធិ*

៤.ឧទ្ធច្ចំ សមាធិស្ស បរិបន្ថោ *ឧទ្ធច្ចៈជាអន្តរាយដល់សមាធិ*

៥.វិចិកិច្ឆា សមាធិស្ស បរិបន្ថោ *វិចិកិច្ឆាជាអន្តរាយដល់សមាធិ*

៦.អវិជ្ជា សមាធិស្ស បរិបន្ថោ *អវិជ្ជាជាអន្តរាយដល់សមាធិ*

៧.អរតិ សមាធិស្ស បរិបន្ថោ *អរតិ គឺសេចក្តីនឿយណាយចំពោះការបដិបត្តិ ជាអន្តរាយដល់សមាធិ*

៨.សព្វេបិ អកុសលា ធម្មា សមាធិស្ស បរិបន្ថា *អកុសលធម៌ទាំងអស់ សុទ្ធតែជាអន្តរាយដល់សមាធិ ។*

## ធម៌ឧបការៈដល់សមាធិ ៨ យ៉ាង

១.នេក្ខម្មំ សមាធិស្ស ឧបការំ *នេក្ខម្មៈ ជាឧបការៈដល់សមាធិ*

២.អព្យាបាទោ សមាធិស្ស ឧបការំ *អព្យាបាទៈ ជាឧបការៈដល់សមាធិ*

៣.អាលោកសញ្ញា សមាធិស្ស ឧបការំ អាលោកសញ្ញា ជាឧបការៈដល់សមាធិ

៤.អវិក្ខេបោ សមាធិស្ស ឧបការំ អវិក្ខេបៈ ជាឧបការៈដល់សមាធិ

៥.ធម្មវវត្ថានំ សមាធិស្ស ឧបការំ ធម្មវវត្ថានៈ ជាឧបការៈដល់សមាធិ

៦.ញាណំ សមាធិស្ស ឧបការំ ញាណ ជាឧបការៈដល់សមាធិ

៧.បាមោជ្ជំ សមាធិស្ស ឧបការំ បាមោជ្ជៈ ជាឧបការៈដល់សមាធិ

៨.សព្វេបិ កុសលា ធម្មា សមាធិស្ស ឧបការា កុសលធម៌សូម្បីទាំងអស់ សុទ្ធតែជាឧបការៈដល់សមាធិ ។

សរុបសេចក្តីមក នីវរណៈទាំង ៥ **អរតិ** គឺសេចក្តីមិនត្រេកអរក្នុងការបដិបត្តិ **អវិជ្ជា** និងអកុសលទាំងអស់ ជាអន្តរាយដល់សមាធិ គឺមិនអាចនាំឲ្យបានទម្ងុះដល់ឧបចារសមាធិ និងអប្បនាសមាធិ ។

សូមមើលសេចក្តីពិស្តារ ក្នុងបិដកលេខ ៧០ តាំងពីទំព័រ ៨៤ ដល់ ៨៨ ។

## អកុសលធម៌សូម្បីទាំងអស់ ជាអន្តរាយដល់សមាធិ

តើអ្វីជាអកុសលធម៌ទាំងអស់ ?

បើធ្វើយដោយងាយ បានដល់ ធម៌ដែលជាឧបកិលេស ១៦ ។ ព្រោះឧបកិលេសនីមួយៗ សុទ្ធតែជាអកុសលធម៌ ដូចព្រះពុទ្ធទ្រង់ត្រាស់ជាមួយព្រះអនុរុទ្ធ ព្រះនន្ទិយៈ និងព្រះកិម្ពិលៈថា ៖

(មជ្ឈិម.ឧបរិ. លេខ ២៧ ទំព័រ ១៤៤-១៦០)

ព្រះពុទ្ធត្រាស់សួរថា តើអ្នកទាំងឡាយ ត្រាស់ដឹងនូវផាសុវិហារធម៌ដ៏វិសេស គឺញាណទស្សនៈដ៏ប្រសើរ ដែលអាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែង ជាឧមនុស្សធម៌ មានឬទេ?

ព្រះអនុរុទ្ធ : សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ យើងខ្ញុំព្រះអង្គ មិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ប៉ុន្តែឯពន្លឺនឹងការឃើញរូបទាំងឡាយនោះ របស់ខ្ញុំព្រះអង្គ មិនយូរប៉ុន្មាន ក៏បាត់ទៅវិញ ឯយើងខ្ញុំព្រះអង្គ ក៏មិនបានត្រាស់ដឹងនូវនិមិត្តនោះទេ ។

ព្រះពុទ្ធ : ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយ គប្បីត្រាស់ដឹងនូវនិមិត្តនោះជាប្រាកដ ម្នាលអនុរុទ្ធទាំងឡាយ ក្នុងកាលមុន អំពីការត្រាស់ដឹង តថាគតមិនទាន់បានត្រាស់ដឹង នៅជាពោធិសត្វនៅឡើយ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ។ ប៉ុន្តែឯពន្លឺ និងការឃើញរូបទាំងឡាយនោះ របស់តថាគតមិននៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា

*វិចិកិច្ឆា សេចក្តីសង្ស័យ*

*អមនសិការៈ ការធ្វើទុកក្នុងចិត្តមិនល្អ*

*ថីនមិទ្ធៈ សេចក្តីងងុយ និងងោកងក់*

*ឆម្ភិតត្តៈ សេចក្តីរន្ធត់ខ្លាច*

*ឧព្វិលៈ សេចក្តីថ្មើងថ្មៃ*

*ទុដ្ឋុល្លៈ សេចក្តីក្រវល់ក្រវាយ*

*អច្ចារទ្ធវិរិយៈ សេចក្តីព្យាយាមតឹងហួសពេក*

*អតិលីនវិរិយៈ សេចក្តីព្យាយាមធូរពេក*

*អភិជប្បា សេចក្តីប្រាថ្នាហួសពេក*

*នានត្តសញ្ញា កំណត់អារម្មណ៍ច្រើនយ៉ាងផ្សេងៗគ្នា*

*អតិនិជ្ឈាយិតត្តៈ ការសំឡឹងមើលនូវរូបដែលឃើញក្រៃពេក*

*កាលកើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែសេចក្តីសង្ស័យ ការធ្វើទុកក្នុងចិត្តមិនល្អ សេចក្តីងងុយ និងងោកងក់ សេចក្តីរន្ធត់ខ្លាច សេចក្តីថ្មើងថ្មៃ សេចក្តីក្រវល់ក្រវាយ សេចក្តីព្យាយាមតឹងហួសពេក សេចក្តីព្យាយាមធូរពេក សេចក្តីប្រាថ្នាហួសពេក កំណត់អារម្មណ៍ច្រើនយ៉ាងផ្សេងៗគ្នា ការសំឡឹងមើលនូវរូបដែលឃើញក្រៃពេក ជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយក៏បាត់ទៅដែរ ។ សេចក្តីសង្ស័យ ការធ្វើទុក*

ក្នុងចិត្តមិនល្អ សេចក្តីងងុយ និងងោកងក់ សេចក្តីរន្ធត់ខ្លាច សេចក្តីឆ្ងើងឆ្ងៃ សេចក្តីក្រវល់ក្រវាយ សេចក្តីព្យាយាមតឹងហួសពេក សេចក្តីព្យាយាមធូរពេក សេចក្តីប្រាថ្នាហួសពេក កំណត់អារម្មណ៍ច្រើនយ៉ាងផ្សេងៗគ្នា ការសំឡឹងមើលនូវរូបដែលឃើញក្រៃពេក កើតឡើងមិនបានដល់អាត្មាអញ យ៉ាងណា អាត្មាអញនឹងធ្វើ យ៉ាងនោះ ។

ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ជាមួយព្រះអនុរុទ្ធថា ធម៌ទាំង ១១ នេះជាឧបកិលេសរបស់ចិត្ត (គ្រឿងសៅហ្មងរបស់ចិត្ត) ។

**ឧបកិលេសនៃចិត្តដទៃទៀត ១៦ យ៉ាង**

១.អភិជ្ឈាវិសមលោភៈ សេចក្តីចង់បានក្នុងផ្លូវទុច្ចរិត

២.ទោសៈ សេចក្តីគិតប្រទូស្តរ៉ាយ

៣.កោធៈ សេចក្តីក្រោធ

៤.ឧបនាហៈ ការចងក្រោធ

៥.មក្ខៈ លុបគុណ

៦.បលាសៈ ការវាយឫកស្មើ

៧.ឥស្សា ប្រណែន

៨.មច្ឆរិយៈ កំណាញ់

៩.មាយា លាក់ពុត

១០. សាថេយ្យៈ អំនួត

១១ .ថម្ភ: រឹងរូស

១២.សារម្ភ: ការប្រណាំងប្រជែង (គឺមិនដឹងប្រមាណខ្លួន)

១៣.មាន: ការប្រកាន់ខ្លួន

១៤.អតិមាន: ការមើលងាយអ្នកដទៃ

១៥.មទ: សេចក្តីស្រវឹង

១៦.បមាទ: សេចក្តីប្រមាទ (គឺការមិនមានសតិ)

## សមាធិ

កាលអ្នកបដិបត្តិបានចម្រើនទូវអានាបានស្សតិតាមដែលពោលមក ហើយខាងដើម ដរាបដល់ **ចិត្តវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធនៃចិត្ត បានដល់ **ឧបចារសមាធិ ឬអប្បនាសមាធិ ។**

មុនទម្ងុះដល់ឧបចារសមាធិ អ្នកបដិបត្តិដែលឆ្លងកាត់អនុពន្ធនានយ័ ហើយ អាចជួបលក្ខណៈពិសេសណាមួយអាចកើតឡើងបាន ដូចក្នុង វិសុទ្ធិមគ្គបញ្ជាក់ថា ៖

កស្សចិ បន គណនាវសេនេវ មនសិការកាលតោ បភុតិ អនុក្កមតោ ឱឡារិកអស្សាសបស្សាសនិរោធវសេន កាយទរថេ វូបសន្តេ កាយោបិ ចិត្តម្បិ លហុកំ ហោតិ, សរីរំ អាកាសេ លង្ឃនាការប្បត្តំ វិយ ហោតិ។ កាលសេចក្តីក្រវល់ក្រវាយផ្លូវកាយ ស្ងប់ហើយ ដោយអំណាចរលត់ខ្យល់ចូល និងខ្យល់ចេញ ដែលគ្រោត

គ្រៀតដោយលំដាប់ ចាប់ផ្តើមតាំងពីមនសិការៈដោយអំណាចនៃ គណនានយ័ជាដើមមក ទាំងកាយ ទាំងចិត្តរមែងជាធម្មជាតិស្រាល រាងកាយមានអាការៈអណ្តែតឡើង ដូចជាប៉ើងឡើងទៅកាន់អាកាស តែងមានដល់អ្នកបដិបត្តិខ្លះ ។

កាលអ្នកបដិបត្តិបានទម្លុះដល់ឧបចារសមាធិ ឬអប្បនាសមាធិ ទើបឈ្មោះថា **បានសមាធិ** គឺបានដល់ចិត្តវិសុទ្ធិ។

ដូចម្តេចទៅ ហៅថា **ចិត្តវិសុទ្ធិ** ?

ចិត្តវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃចិត្ត សំដៅដល់ សមាធិដែលកើតរួមជាមួយចិត្ត ព្រោះសមថសមាធិ មានកម្លាំងខ្លាំងក្លា គ្របសង្កត់នីវរណៈ ៥ ដែលបៀតបៀនរុកគួន មិនឲ្យកើតឡើងបាន ហើយមានតែសមថារម្មណ៍កើតឡើងបន្តគ្នា ។ សមាធិនេះ ជាចិត្តវិសុទ្ធិ យ៉ាងពិតប្រាកដ ចិត្តដែលមានសមាធិកើតរួមនោះ រមែងបរិសុទ្ធ មិនមាននីវរណៈកើតឡើងបានដោយកម្លាំងសមាធិ ។

ក្នុងអភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៩ ទំព័រ ៩៨ បញ្ជាក់ថា ៖

ឧបចារសមាធិ អប្បនាសមាធិ ចេតិ ទុវិធោបិ សមាធិ ចិត្តវិសុទ្ធិ នាម ។ សមាធិសូម្បីមានពីរប្រការគឺ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ឈ្មោះថា ចិត្តវិសុទ្ធិ ។

ឧបចារសមាធិ ឬអប្បនាសមាធិ ជាគោលបដិបត្តិខាងដើមរបស់បុគ្គលជាសមថយានិក (អ្នកចម្រើនសមថៈ) ជាអ្នកមានសមថៈជាបាទ

*ចម្រើនវិបស្សនា ។ សមាធិពួកនេះ មានក្នុងវិសុទ្ធិមគ្គ ភាគទី ១ ទំព័រ ២៤៧ ថា ៖*

ទុវិធោ ហិ សមាធិ ឧបចារសមាធិ ច អប្បនាសមាធិ ច។ ទ្វីហាការេហិ ចិត្តំ សមាធិយតិ ឧបចារភូមិយំ វា បដិលាភភូមិយំ វា។ តត្ត ឧបចារភូមិយំ នីវរណប្បហានេន ចិត្តំ សមាហិតំ ហោតិ។ បដិលាភភូមិយំ អង្គបាតុភាវេន។

*ពិតប្រាកដណាស់ សមាធិ ២ ប្រភេទ គឺ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ចិត្តរមែងតាំងមាំដោយអាការៈ ២ យ៉ាង ក្នុងទីនៃឧបចារសមាធិ ឬក្នុងពេលដែលសម្រេចអប្បនាសមាធិ ។ បណ្ដាសមាធិទាំងពីរនេះ ចិត្តរមែងតាំងមាំដោយការលះនីវរណៈក្នុងទីនៃឧបចារសមាធិ ចិត្តរមែងតាំងមាំដោយការប្រាកដនៃអង្គឈាន ក្នុងពេលដែលសម្រេចអប្បនាសមាធិ ។*

*ក្នុងវិសុទ្ធិមគ្គ មហាដីកាពោលដល់សមាធិប្រភេទនេះថា ៖*

សមថយានិកស្ស ហិ ឧបចារប្បនាភេទំ សមាធឹ ឥតរស្ស ខណិកសមាធឹ ឧភយេសម្បិ វិនា ន កទាចិបិ លោកុត្តរាធិគមោ សម្ភវតិ ។ តេនាហ សមាធិញ្ចេវ វិបស្សនញ្ច ភាវយមានោ ។

*ពិតមែនហើយ ការសម្រេចលោកុត្តរធម៌ រមែងមិនមានដល់បុគ្គលសមថយានិក ដែលប្រាសចាកឧបចារសមាធិ និងអប្បនាសមាធិ, ការសម្រេចលោកុត្តរធម៌ រមែងមិនមានដល់វិបស្សនាយានិក ដែលប្រាស*

ចាកខណិកសមាធិ និងការសម្រេចលោកុត្តរធម៌ រមែងមិនមានដល់បុគ្គលទាំងពីរ ដែលប្រាសចាកផ្លូវកាន់វិមោក្ខ ៣ ( អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ) ដូច្នោះ អដ្ឋកថាចារ្យទើបពោលថា ***សមាធិញ្ចេវ វិបស្សនញ្ច ភាវយមានោ*** ដូច្នេះ។

## សមាធិក្នុងគម្ពីរនេត្តិប្បករណ៍

សញ្ញោ សមាធិ ញាណមូលកោ ញាណបុព្វង្គមោ ញាណានុបរិវត្តិ ។ សមាធិទាំងពួង មានញាណជាហេតុ មានញាណជាប្រធាន បណ្តោយតាមញាណ ។

ពាក្យថា ញាណមូលកោ (មានញាណជាហេតុ) សំដៅដល់បញ្ញាដែលមានមកតាំងតែបដិសន្ធិ ដែលប្រកបដោយហេតុ ៣ ។

ពាក្យថា ញាណបុព្វង្គមោ (មានញាណជាប្រធាន) គឺបញ្ញាក្នុងឧបចារសមាធិ ។

ពាក្យថា ញាណានុបរិវត្តិ (បណ្តោយតាមញាណ) គឺបញ្ញាក្នុងអប្បនាសមាធិ ។

ម្យ៉ាងទៀត ពាក្យថា ញាណមូលកោ សំដៅដល់ បញ្ញាក្នុងឧបចារសមាធិ ។ ពាក្យថា ញាណបុព្វង្គមោ គឺបញ្ញាក្នុងអប្បនាសមាធិ។ ចំណែកពាក្យថា ញាណានុបរិវត្តិ គឺបញ្ញាក្នុងអភិញ្ញា ។

## អប្បនាសមាធិ

ការបម្រើនសមថភាវនា គឺចម្រើនរូបជ្ឈាន ប្រកបដោយអង្គឈាន ៥ មានវិតក្កៈជាដើមនោះ អាចញាំញីនូវនីវរណៈ ៥ មិនឲ្យកើតឡើង

ព្រោះចិត្តមូល នៅក្នុងអារម្មណ៍តែមួយ ដរាបដល់ឈានចិត្តកើតឡើង កាលឈានចិត្តកើតហើយ អង្គឈានទោះឯង រមែងប្រហារនីវរណធម៌ ៥ ដោយវិក្ខម្ភនប្បហាន ។

មួយទៀត កាលឈានចិត្តនឹងកើតឡើង សមាធិរមែងកើតឡើង តាមលំដាប់ គឺឧបចារសមាធិ និងអប្បនាសមាធិ ឈានចិត្តកើតឡើង គ្រាដំបូង ត្រឹមខណៈចិត្តមួយប៉ុណ្ណោះ ហើយក៏ជាភវង្គ បើនឹងមិនឲ្យចិត្ត ជាភវង្គ ត្រូវហ្វឹកហាត់ដរាបដល់ជំនាញ (ដែលហៅថា វសី ៥ យ៉ាង) ។ ឈាន គឺរូបាវចរកុសល ចិត្តនឹងកើតនោះ វិថីចិត្តត្រូវកើតឡើង ដោយលំដាប់ ។

វិថីរបស់រូបាវចរកុសលចិត្ត គឺ ៖

១. ភវង្គចលនៈ

២. ភវង្គុបច្ឆេទៈ

៣. មនោទ្វារាវជ្ជនៈ

៤. បរិកម្ម
៥.ឧបចារៈ
៦. អនុលោម
៧. គោត្រភូ
(៤–៧) មហាកុសលញាណសម្បយុត្ត

៨. ឈាន គឺរូបាវចរកុសលចិត្ត

ភវង្គបាត ចិត្តជាភវង្គ ។

អធិប្បាយ អប្បនាវិថី

*កាលភវង្គចលនៈ គឺការញ័ររបស់ភវង្គរលត់ទៅ ភវង្គុបច្ឆេទៈ ក៏កើតនិងរលត់ទៅ តពីនោះ មនោទ្វារាវជ្ជនៈ គឺអហេតុកកិរិយាចិត្ត ក៏កើតឡើងធ្វើកិច្ច ពិចារណាអារម្មណ៍តាមមនោទ្វារ កាលមនោទ្វារាវជ្ជនចិត្តរលត់ហើយ មហាកុសលញាណសម្បយុត្ត ៤ ណាមួយ ក៏ធ្វើបរិកម្ម ឧបចារៈ អនុលោម គោត្រភូ កាលគោត្រភូចិត្តរលត់ហើយ ឈានចិត្តក៏កើតមួយខណៈចិត្តប៉ុណ្ណោះ ហើយចិត្តក៏ជាភវង្គតទៅ ។*

**ទុតិយជ្ឈាន**

*កាលព្រះយោគាវចរ ហ្វឹកហាត់ព្យាយាមចូលបឋមជ្ឈាន ដរាបដល់ជំនាញល្អ ព្រមដោយវសី ៥ គឺ ៖*

**១. អាវជ្ជនវសី** *ជំនាញក្នុងការនឹក*

**២. សមាបជ្ជនវសី** *ជំនាញក្នុងការចូលឈាន*

**៣. អធិដ្ឋានវសី** *ជំនាញក្នុងការតាំងមាំ*

**៤. វុដ្ឋានវសី** *ជំនាញក្នុងការចេញចាកឈាន*

**៥. បច្ចវេក្ខណវសី** *ជំនាញក្នុងការពិចារណាអង្គឈាន ។*

*ព្រះយោគាវចរចូលឈាន ចេញចាកឈានដរាបជំនាញហើយ ហ្វឹកហាត់ដោយពិចារណាថា នឹកយ៉ាងណា ឈានទើបនឹងកើតបានរហ័ស ហ្វឹកហាត់ដោយវិធីនោះរឿយ ៗ រហូតដល់ជំនាញល្អ ហៅថា* **អាវជ្ជនវសី** (*ជំនាញក្នុងការនឹក*) ។

**សមាបជ្ជនវិធី** (*ជំនាញក្នុងការចូលឈាន*) *គឺចូលឈានរឿយ ៗ ដែលជំនាញដូចការលេងកីឡា ឬលោកហៅថា កីឡាឈាន ។*

**អធិដ្ឋានវសី** ជំនាញក្នុងការឲ្យឈានកើតរលត់បន្ត ដោយមិនជាភវង្គ គឺ នឹងឲ្យឈានតាំងនៅតាមតម្រូវការ ។

**វុដ្ឋានវសី** ជំនាញក្នុងការចេញចាកឈាន ដោយតាំងចិត្តនឹងចេញចាកឈានវេលាណា ក៏ចេញបានមិនយឺតយូរ ។

**បច្ចវេក្ខណវសី** ជំនាញក្នុងការពិចារណាអង្គឈាន គឺកាលចេញចាកឈានហើយ ពិចារណាដើម្បីលះអង្គឈានដែលគ្រោតគ្រាតចេញ ដើម្បីធ្វើឲ្យអប្បនាសមាធិរឹងមាំក្រៃលែងឡើង រមែងពិចារណា ឃើញថាវិតក្កៈ នេះជាអង្គឈានដែលគ្រោតគ្រាតជាងវិចារៈ ព្រោះជិតនឹងកាមារម្មណ៍ ដូច្នោះ កាលនឹងឈានឡើងកាន់ទុតិយជ្ឈាន ទើបលោកសម្លឹងបដិភាគនិមិត្ត ដើម្បីឲ្យចិត្តជាអប្បនាសមាធិ ដោយមិនមានវិតក្កៈតទៅ ព្យាយាមរហូតដល់ឈានចិត្ត មិនមានវិតក្កៈកើតឡើង មានត្រឹមតែវិចារៈ បីតិ សុខៈ ឯកគ្គតា ប៉ុណ្ណោះ ។ កាលទុតិយជ្ឈាននឹងកើតនោះ ក៏នឹងមានវិថីចិត្ត ដែលកើតមុនទុតិយជ្ឈាន គឺមហាកុសលញាណ-សម្បយុត្តចិត្ត ដែលជាបរិកម្ម ឧបចារៈ អនុលោម និង គោត្រភូ ដូចគ្នានឹងបឋមជ្ឈានដែលបានពោលហើយ ។

## តតិយជ្ឈាន

កាលព្រះយោគាវចរ ជំនាញក្នុងទុតិយជ្ឈាន ប្រកបដោយវសី ៥ ហើយ ក៏នឹងសម្លឹងបដិភាគនិមិត្តឡើងកាន់ឈានទី ៣ ដោយពិចារណាឃើញវិចារៈ ជាអង្គឈានគ្រោតគ្រាតជិតនឹងវិតក្កៈ ដែលធ្វើឲ្យសាបសូន្យបានងាយ កាលឃើញទោសរបស់វិចារៈហើយ ក៏ចូលឈានសម្លឹង

បដិភាគនិមិត្ត ដើម្បីឲ្យអប្បនាសមាធិកើតឡើង ដោយមិនមានវិចារៈ ដរាបដល់តតិយជ្ឈានកើតឡើង ដោយទំនងដូចនឹងឈានដែលពោលហើយ ។

## ចតុត្ថជ្ឈាន

កាលចម្រើនតតិយជ្ឈានជំនាញល្អ ព្រមទាំងវសី ៥ ហើយ ក៏នឹងព្យាយាមឡើងកាន់ឈានទី ៤ ដោយពិចារណាឃើញបីតិ ដែលកើតក្នុងតតិយជ្ឈាននោះ ជាសេចក្ដីត្រេកអរ រីករាយ ពោរពេញទូទាំងកាយ ចិត្តមានអាការៈបង្អោនទៅក្នុងការកម្រើកឡើងនៃចិត្ត ដែលរាប់ថា ជាសភាពដែលនៅគ្រោតគ្រាត ដើម្បីឲ្យចិត្តប្រណីតក្រៃលែងឡើង ទើបសម្លឹងបដិភាគនិមិត្ត ដើម្បីចម្រើនអប្បនាសមាធិ ដរាបដល់មិនមានបីតិ កើតរួមផង វិថីចិត្តដែលកើតមុនចតុត្ថជ្ឈាន មានទំនងដូចនឹងឈាន ដែលពោលហើយ ។

## ចតុក្កៈទី ២ វេទនានុបស្សនា

ក្នុងអានាបានស្សតិសូត្រ ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ថា ៖

១.បីតិបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, បីតិបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹង ច្បាស់ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចេញ,

២.សុខបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, សុខបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចេញ,*

៣.ចិត្តសង្ខារបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, ចិត្តសង្ខារ-បដិសំវេទី បស្សសិស្សាមី៎តិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចេញ,*

៤.បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ, បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

សេចក្តីអធិប្បាយ

*១.ការដឹងច្បាស់បីតិ គឺការញ៉ាំងបឋមជ្ឈាន និងទុតិយជ្ឈាន ដែលមានបីតិ បាមោជ្ជៈ ដែលប្រាកដច្បាស់ក្នុងបដិភាគនិមិត្តឲ្យកើតឡើង ។*

២.ការដឹងច្បាស់សុខ គឺការញ៉ាំងតតិយជ្ឈាន ដែលមានសុខវេទនា ដែលប្រាកដច្បាស់ក្នុងបដិភាគនិមិត្តឲ្យកើតឡើង ។

៣.ការទទួលដឹងច្បាស់ចិត្តសង្ខារ បានដល់ ឧបេក្ខាវេទនាគឺការញ៉ាំងចតុត្ថជ្ឈាន ដែលមានឧបេក្ខាវេទនា ដែលប្រាកដច្បាស់ក្នុងបដិភាគនិមិត្តឲ្យកើតឡើង ។

៤.ការរម្ងាប់ចិត្តសង្ខារ បានដល់ វេទនា និងសញ្ញាដ៏គ្រោតគ្រាត គឺសេចក្តីព្យាយាមតាំងចិត្តនឹងរម្ងាប់វេទនា និងសញ្ញាដែលគ្រោតគ្រាត ឲ្យស្ងប់ចុះតាមលំដាប់ ។

ក្នុងគម្ពីរអដ្ឋកថា បានពោលដល់ពួកនេះ ទុកក្នុងអប្បនាសមាធិ ដូច្នេះ ការដឹងច្បាស់បីតិ ទើបកើតឡើងក្នុងខណៈទម្ងុះឈាន ។ តែអ្នកបដិបត្តិដែលទម្ងុះបដិភាគនិមិត្តក្នុងខណៈកើតឧបចារសមាធិហើយ ក៏គួរបង្អោនទៅដើម្បីដឹងច្បាស់នូវបីតិ និងសុខ ដូចគ្នា ។

## ចតុក្កៈទី ៣ ចិត្តានុបស្សនា

១.ចិត្តបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, ចិត្តបដិសំវេទី បស្សសិស្សាមី’តិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចេញ

២.អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ, អភិប្ប-មោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចេញ*

៣.សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ, សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចេញ*

៤.វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ, វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្ត ឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

**សេចក្តីអធិប្បាយ**

*១.ការញ៉ាំងចិត្តឲ្យរីករាយ គឺការចូលឈានសមាបត្តិទាំង ៤ ក្នុងអារម្មណ៍នោះ ម្តងហើយ ម្តងទៀត*

*២.ការញ៉ាំងចិត្តឲ្យរីករាយ ក្រោយអំពីញ៉ាំងចិត្តឲ្យប្រេចក្យហើយ គឺចូលបឋមជ្ឈាន និងទុតិយជ្ឈាន ដែលប្រកបដោយបីតិ*

*៣.ការញ៉ាំងចិត្តឲ្យតាំងមាំក្រោយពីញ៉ាំងចិត្តឲ្យរីករាយហើយ គឺការចូលតតិយជ្ឈាន*

*៤.ការញ៉ាំងចិត្តឲ្យរួចផុត គឺការចូលឈានសមាបត្តិទាំង ៤ ម្តងហើយម្តងទៀត ដើម្បីផាកចិត្តអំពីនីវរណៈ ដែលធ្វើឲ្យចិត្តសៅហ្មង ។*

*ក្នុងអដ្ឋកថាបានពោលដល់ពួកនេះទុកក្នុងអប្បនាសមាធិ ។ តែកើតឡើងបានក្នុងឧបចារសមាធិទៀតផង ។*

**ចតុក្កៈទី ៤ ធម្មានុបស្សនា**

១.អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចេញ*

២.វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចេញ*

៣.និរោធានុបស្សី អស្សសិស្សាមី'តិ សិក្ខតិ, និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចេញ*

៤.បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, បដិ-និស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចេញ ។*

*ក្នុងចតុក្កៈទី ៤ គឺ ធម្មានុបស្សនានេះ បានដល់ ការតាមដឹងសភាវធម៌ កំណត់ដឹងសេចក្តីមិនទៀងរបស់អភិជ្ឈា និងទោមនស្ស ជាប់ទាក់ទងអំពីការកម្ចាត់អភិជ្ឈា និងទោមនស្ស ដែលប្រាកដច្បាស់ក្នុងខណៈនោះ ។*

## ចម្រើនអានាបានស្សតិភាវនាតាមវិបស្សនាន័យ

*ក្នុងអានាបានស្សតិសូត្រ និងអដ្ឋកថាបានសម្តែងដល់ការចម្រើនវិបស្សនា ក្រោយពីឈានទី ៤ ដោយចេញពីឈានហើយ កំណត់ដឹងខ្យល់ចូល និងខ្យល់ចេញ វេទនា ឬចិត្តក្នុងបច្ចុប្បន្នខណៈ ឬតាមដឹងអង្គឈាន*

ដែលប្រាកដច្បាស់ក្នុងឈាន ដែលខ្ជួនទម្ទុះហើយ ការបដិបត្តិដូច្នេះ ជាខ បដិបត្តិដ៏កំពូលបំផុត ។

បើអ្នកបដិបត្តិមិនអាចធ្វើយ៉ាងនោះបានទេ ក៏អាចធ្វើតាមជាន់ណាមួយក៏បាន ដូចតទៅនេះ ៖

១.ចម្រើនវិបស្សនាកាលចេញពីតតិយជ្ឈាន

២.ចម្រើនវិបស្សនាកាលចេញពីទុតិយជ្ឈាន

៣.ចម្រើនវិបស្សនាកាលចេញពីបឋមជ្ឈាន

៤.ចម្រើនវិបស្សនាកាលទម្ទុះឧបចារសមាធិ

៥.ចម្រើនវិបស្សនាតាំងតែអនុពន្ធនានយ

៦.ចម្រើនវិបស្សនាតាំងតែគណនានយដែលរម្ងាប់សេចក្តីកាយមាយហើយ ។

**ការចម្រើនវិបស្សនាតាមនយកំណត់ដឹងខ្យល់មាន ២ វិធីគឺ**

១.ការកំណត់ដឹងខ្យល់ចូល ខ្យល់ចេញជាអារម្មណ៍កម្មដ្ឋាន

២.កំណត់ដឹងខន្ធ ៥ យ៉ាងណាមួយ ក្រោយពីឧបចារសមាធិ ឬអប្បនាសមាធិហើយ ។

នយដំបូងពោលទុកក្នុងអានាបានស្សតិសូត្រ ដោយអាងមកហើយថា ៖

អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ, អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ

*ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចេញ ។*

*ខនេះមានសេចក្តីថា កាលដកដង្ហើមចូល គប្បីធ្វើទុកក្នុងចិត្តចំពោះសេចក្តីមិនទៀងរបស់ខ្យល់ដង្ហើម ហើយដកដង្ហើមចូល សូម្បីក្នុងការដកដង្ហើមចេញក៏មានន័យដូចគ្នា មិនគប្បីដកដង្ហើមចូល ដកដង្ហើមចេញដូចក្នុងវេលាធម្មតា ដោយមិនបានតាមដឹងសេចក្តីមិនទៀងនោះទេ ។*

*ម្យ៉ាងទៀត ការចម្រើនវិបស្សនាមានអារម្មណ៍គោលក្នុងការតាមដឹង ២ ប្រការ គឺ*

*១.ការតាមដឹងរូបជាគោល គឺការកំណត់ខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញ ដែលប្រាកដច្បាស់តាមគណនាន័យ និងអនុពន្ធនាន័យ ។*

*២.ការតាមដឹងនាមជាគោល គឺការកំណត់វេទនា (វេទនានុបស្សនា) ឬការកំណត់ចិត្ត (ចិត្តានុបស្សនា) តាមឋបនាន័យ ក្រោយពីអ្នកបដិបត្តិទម្លុះឧបចារសមាធិហើយ ដូចព្រះពុទ្ធវចនៈអាងមកហើយថា ៖*

១.បីតិបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, បីតិបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចេញ,

២.សុខបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, សុខបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចេញ,

៣.ចិត្តសង្ខារបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ, ចិត្តសង្ខារ-បដិសំវេទី បស្សសិស្សាមី៎តិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចេញ ។

សម្រាប់អ្នកបដិបត្តិជាវិបស្សនាសុទ្ធដោយត្រង់ កាលសាងសមាធិបានដោយការតាមដឹងខ្យល់ដង្ហើមតាមគណានាន័យហើយ មិនចាំបាច់បដិបត្តិអនុពន្ធនាន័យនោះទេ ។ តែគប្បីចម្រើនន័យពួកទី ៤ តាមដឹងសេចក្តីមិនទៀងរបស់ខ្យល់តែម្តង ដូចន័យក្នុងអដ្ឋកថា សុមង្គលវិលាសិនីបញ្ជាក់ថា ៖

សោ ឈានា វុដ្ឋហិត្វា អស្សាសបស្សាសេ វា បរិគ្គណ្ហាតិ ឈានង្គានិ វា ភិក្ខុនោះចេញពីឈានហើយ រមែងកំណត់ដឹងខ្យល់ចូល ខ្យល់ចេញ ឬអង្គឈាន ។

សេចក្តីពិត ខនេះពោលបញ្ជាក់ដល់អ្នកទម្លុះឈានដោយការចម្រើនអានាបានស្សតិហើយ ចម្រើនវិបស្សនាដោយកំណត់ដឹងខ្យល់ចូល ខ្យល់ចេញ ឬអង្គឈាន មិនបានសម្តែងថា មិនទម្លុះឈាន ក៏ចម្រើនវិបស្សនាមិនបាន ព្រោះធម៌ដែលជាកាមាវចរៈគួរជាអារម្មណ៍របស់សមថយានិក និងវិបស្សនាយានិកទាំងពីរពួក ។ តែបុគ្គលទាំងពីរនេះ មានវិធីបដិបត្តិផ្សេងគ្នា ពោលគឺសមថយានិកកំណត់ដឹងសណ្ឋានវែងខ្លីរបស់ខ្យល់ចូល ខ្យល់ចេញ ដែលចាត់ជាបញ្ញត្តិ (សណ្ឋានជាបញ្ញត្តិ) ។ ចំណែក វិបស្សនាកំណត់ដឹងសភាវៈកម្រើករបស់ខ្យល់ដែលប៉ះខ្ទប់ត្រង់ច្រមុះ ដែលចាត់ជាផោដ្ឋព្វារម្មណ៍ ដែលប៉ះខ្ទប់រវាងវាយោធាតុ ជាមួយនឹងចុងច្រមុះឬរឹមបបូរមាត់ខាងលើ ដោយផោដ្ឋព្វារម្មណ៍នោះ រាប់ចូលក្នុងធម្មានុបស្សនា (ផោដ្ឋព្វារម្មណ៍ជាបរមត្ថ) ។

## ចម្រើនវិបស្សនារបស់បុគ្គលសុទ្ធវិបស្សនាយានិក

*បុគ្គលអ្នកចម្រើនវិបស្សនាសុទ្ធ ដោយមិនចាំបាច់ចម្រើនសមថៈជាបាទ ត្រូវមានខណិកសមាធិ ជាបាទ ទើបចម្រើនវិបស្សនាបាន ដូចជួបក្នុងគម្ពីរវិសុទ្ធិមគ្គ បានសម្ដែងសមាធិទាំង ៣ ប្រភេទថា*

សុខំ គម្ភំ គណ្ឋាន្តំ បរិចាកំ គច្ចន្តំ តិវិធំ សមាធិំ បរិបូរេតិ ខណិកសមាធិំ ឧបចារសមាធិំ អប្បនាសមាធិំ ។

*សេចក្ដីសុខដែលចម្រើនចាស់ក្លា រមែងញ៉ាំងសមាធិ ៣ ឲ្យបរិបូរ គឺ ខណិកសមាធិ ១ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ។*

*សូម្បីគម្ពីរមូលបណ្ណាសដីកា ក៏បញ្ជាក់ដល់ខណិកសមាធិ ដែលកើតឡើងដល់អ្នកចម្រើនវិបស្សនាជាគោលថា*

សមថំ អនុប្បាទេត្វាតិ អវធារណេន ឧបចារសមាធិំ និវត្តេតិ ន ខណិកសមាធិំ ន ហិ ខណិកសមាធិំ វិនា វិបស្សនា សម្ភវតិ ។

*អដ្ឋកថាចារ្យ ហាមឧបចារសមាធិ ដោយពាក្យបដិសេធថា* សមថំ អនុប្បាទេត្វា *(មិនញ៉ាំងសមថៈឲ្យកើតឡើង) តែមិនហាម ខណិកសមាធិ ព្រោះវិបស្សនា រមែងមិនកើតឡើង ដោយប្រាសចាក ខណិកសមាធិ ឡើយ។*

*ខណិកសមាធិ ជាសមាធិដែលកើតមួយខណៈៗ កាលកំពុងកំណត់ដឹងសភាវធម៌ រមែងប្រាកដឡើង ។ កាលចិត្តតាំងមាំក្នុងអារម្មណ៍បច្ចុប្បន្ន ដែលជារូបធម៌ នាមធម៌ ជាបន្តបន្ទាប់ ដោយប្រាសចាកនីវរណៈ*

ក្នុងខណៈដែលឥន្ទ្រិយ ៥ គឺ សទ្ធា វិរិយៈ សតិ សមាធិ និងបញ្ញា មានកម្លាំងស្មើគ្នា ដល់អ្នកចម្រើនវិបស្សនា ។

អ្នកដែលចម្រើនវិបស្សនាតែម្យ៉ាង ដោយមិនអាស្រ័យសមថៈទាំង ២ គឺ ឧបចារសមាធិ ឬអប្បនាសមាធិ ឈ្មោះថា សុទ្ធវិបស្សនាយានិក គឺអ្នកធ្វើដំណើរទៅកាន់មគ្គ ផល និងនិព្វាន ដោយវិបស្សនាសុទ្ធៗ **បុគ្គលប្រភេទនេះ មានខណិកសមាធិ តែម្យ៉ាង ជាចិត្តវិសុទ្ធិ** ។

ម្យ៉ាងទៀត ខណិកសមាធិ រមែងកើតឡើងក្នុងវិបស្សនាចិត្ត ប៉ុណ្ណោះ មិនកើតឡើងក្នុងខាងដើមនៃការបដិបត្តិ ។ តែរាប់បញ្ចូលខណិកសមាធិនេះ ទុកក្នុងឧបចារសមាធិ ព្រោះដូចជាមួយនឹងឧបចារសមាធិ ដែលប្រាសចាកនីវរណៈ ដូចគ្នានឹងកម្មដ្ឋាន ១២ យ៉ាង មានអនុស្សតិកម្មដ្ឋាន ជាដើម ដែលរាប់បញ្ចូលជាឧបចារសមាធិដូចគ្នា ដូចក្នុងអដ្ឋកថា មហាសតិប្បដ្ឋានសូត្រថា

សេសានិ ទ្វាទសាបិ ឧបចារកម្មដ្ឋានេវ ។

កម្មដ្ឋាន ១២ យ៉ាងដ៏សេស ឈ្មោះថា កម្មដ្ឋានដែលបណ្ដាលឲ្យកើតឧបចារសមាធិនោះឯង ។

ដូចសេចក្ដីបញ្ជាក់ទុកក្នុងវិសុទ្ធិមគ្គ មហាដីកាត្រង់ទិដ្ឋិវិសុទ្ធិថា

សមថោវ យានំ សមថយានំ, តំ ឯតស្ស អត្ថីតិ សមថយានិកោ ។ ឈានេ, ឈានូបចារេ វា បតិដ្ឋាយ វិបស្សនំ អនុយុញ្ជន្តស្សេតំ នាមំ, តេន **សមថយានិកោន** ។

*សមថៈតែម្យ៉ាងជាយាន ឈ្មោះថា **សមថយាន** ។ សមថយាន នោះ មានដល់បុគ្គលណា បុគ្គលនោះ ឈ្មោះថា **សមថយានិក** ។ នេះជា ពាក្យហៅ បុគ្គលអ្នកចម្រើនវិបស្សនា ដែលតាំងនៅក្នុងឈាន (អប្បនា) ឬសមាធិជិតឈាន (ឧបចារៈ) **ដោយសមថយានិកនោះ** ។*

សមថយានិកស្ស សមថមុខេន វិបស្សនាភិនិវេសោ, វិបស្សនា-យានិកស្ស បន សមថំ អនិស្សាយាតិ អាហ "**សុទ្ធវិបស្សនា-យានិកោ**"តិ, សមថភាវនាយ អមិស្សិតវិបស្សនាយានវាតិ អត្ថោ។

*ការចម្រើនវិបស្សនា ដោយមានសមថៈជាបាទ រមែងមានដល់ សមថយានិក, តែវិបស្សនាយានិក មិនចាំបាច់អាស្រ័យសមថៈទេ ដូច្នេះ អដ្ឋកថាចារ្យទើបពោលថា សុទ្ធវិបស្សនាយានិក ជាអ្នកមានវិបស្សនាជា យាន ដោយមិនចាំបាច់អាស្រ័យសមថភាវនា ។*

*ខនេះមានសេចក្ដីថា អ្នកចម្រើនវិបស្សនាដោយអាស្រ័យសមាធិ បន្ទាប់ពីឧបចារៈ ឬអប្បនា ឈ្មោះថា **សមថយានិក** ។ ចំណែកអ្នកចម្រើន វិបស្សនា ដោយមិនចាំបាច់មានឧបចារៈឬអប្បនា ឈ្មោះថា **សុទ្ធវិបស្សនា យានិក** ។*

*តាមសេចក្ដីក្នុងគម្ពីរមហាដីកានេះសម្ដែងថា វិបស្សនាយានិក មិនចាំបាច់ត្រូវចំរើនឧបចារសមាធិ ចំរើនត្រឹមតែខណិកសមាធិប៉ុណ្ណោះ និងខណិកសមាធិ ក៏អាចធ្វើឲ្យកើតចិត្តវិសុទ្ធិរហូតចូលសម្រេចមគ្គ ផល*

*បាន ។ សូមនាំសាធកៈអំពីអដ្ឋកថា របស់មូលបណ្ណាសកៈ ធម្មទាយាទសូត្រមកសម្ដែងទុកក្នុងទីនេះ*

ភាវនានយោតិ កោចិ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ ។ កោចិ វិបស្សនាបុព្វង្គមំ សមថំ ។ កថំ ។ ឥធេកច្ចោ បឋមំ ឧបចារសមាធឹ វា អប្បនាសមាធឹ វា ឧប្បាទេតិ ។ អយំ សមថោ ។ សោតញ្ច តំសម្បយុត្តេ ច ធម្មេ អនិច្ចាទីហិ វិបស្សតិ ។ អយំ វិបស្សនា ។ ឥតិ បឋមំ បច្ឆា វិបស្សនា ។ តេន វុច្ចតិ សមថបុព្វង្គមំ ភាវតីតិ ។ តស្ស សមថបុព្វង្គមំ វិបស្សនំ ភាវយតោ មគ្គោ សញ្ជាយតិ ។

*"ពាក្យថា **ភាវនានយោ** ( វិធីចំរើនភាវនា ) សេចក្ដីថា ព្រះយោគីពួកខ្លះ ចំរើនវិបស្សនា ដោយមានសមថៈជាបាទ អ្នកខ្លះចំរើនសមថៈ ដោយមានវិបស្សនាជាបាទ" ។*

*សួរថា : ចំរើនយ៉ាងណា ?*

*ឆ្លើយថា : បុគ្គលពួកខ្លះ ក្នុងព្រះសាសនានេះ រមែងបដិបត្តិឲ្យកើតឧបចារសមាធិឬអប្បនាសមាធិជាមុនសិន សមាធិទាំងពីរនេះឈ្មោះថា សមថៈ រមែងកំណត់ដឹងសមាធិឬធម៌ (គឺចិត និងចេតសិក) ដែលកើតព្រមគ្នាជាមួយសមាធិនោះ ដោយសភាពមិនទៀងជាដើម បញ្ញាដែលកំណត់ដឹងនេះ ឈ្មោះថា វិបស្សនាដោយមានសមថៈជាបាទ កាលចំរើនវិបស្សនា ដោយមានសមថៈជាបាទ មគ្គរមែងកើតឡើង ។*

វិធីចំរើនភាវនា ដែលពោលទុកខាងដើម ជាន័យដំបូង ដែលពោលដល់សមថយានិក ដូចគម្ពីរដីកាអធិប្បាយថា ៖

បឋមោ សមថយានិកស្ស វសេន វុត្តោ។

ន័យដំបូងពោលទុកដោយជាប់ទាក់ទិនដោយសមថយានិក ។

ពាក្យពោលដែលថា "រមែងកំណត់សមាធិឬធម៌ (គឺចិត្ត និងចេតសិក) ដែលកើតព្រមគ្នាជាមួយនឹងសមាធិនោះ ដោយសភាពមិនទៀងជាដើម " សម្តែងវិធីការចំរើនវិបស្សនារបស់សមថយានិកថា គួរកំណត់ដឹងសមថៈ ឬចិត្តចេតសិក មានបីតិចេតសិកជាដើម ដែលកើតព្រមគ្នាជាមួយសមាធិ ។

សូម្បីពាក្យពោលថា " ដោយសភាពមិនទៀងជាដើម " នឹងបញ្ជាក់ដល់វិបស្សនាញាណតាំងអំពីសម្មសនញ្ញាណជាដើមទៅ ដោយភាពជាត្រៃលក្ខណ៍ ចំណែកវិបស្សនាញាណពីរយ៉ាងដំបូងគឺនាមរូបបរិច្ឆេទញ្ញាណ (បញ្ញាដែលកំណត់ដឹងការបែករូបនិងនាម) និងបច្ចយបរិគ្គហញ្ញាណ (បញ្ញាដែលកំណត់ដឹងហេតុបច្ច័យរបស់នាម ) ក៏បានទទួលការពោលទុកដោយបរិយាយ។ ពិតមែនហើយញាណទាំងពីរនេះ មិនបានកើតមុនពេលដែលចំរើនភាវនា សូម្បីអនិច្ចានុបស្សនាជាដើម ក៏កើតឡើងមិនបាន ដោយប្រាសចាកញាណខាងដើម សេចក្តីថា សមថយានិកបានចំរើនសមថៈ ហើយកំណត់ដឹងរូបនាមដោយញាណទាំងពីរនេះ បន្ទាប់អំពីនោះទើបកំណត់ដឹង រូបនាមដោយញាណទាំងពីរនេះ បន្ទាប់អំពីនោះ ទើបកំណត់ដឹងដោយ

ភាពមិនទៀងជាដើម ។ ដូច្នេះ ពាក្យនេះទើបជាសំនួន ភាសាម្យ៉ាងដែលហៅថា **បធានន័យ** គឺសំនួនដែលពោលដល់វត្ថុដែលជាប្រធាន តែបំណងឲ្យដល់វត្ថុដទៃៗ ដែលមិនមែនជាប្រធាននៅក្នុងទីនេះ ជាការពោលដល់វត្ថុដែលជាប្រធានគឺ អនិច្ចានុបស្សនាជាដើម តែចេតនាបំណងរួបរួមដល់ញាណ ទាំងពីរខាងដើមទៀតផង ។ ដូចពាក្យថា **រាជា អាគច្ឆតិ** ( ព្រះរាជាស្ដេច យាងមក ) ដែលសំដៅដល់ការស្ដេចយាងមកនៃព្រះរាជា និងរាជបរិវារដទៃៗ បើកាន់យកថា អនិច្ចានុបស្សនា ជាដើម កើតបានមុនវិបស្សនាញាណ ពីរយ៉ាងដំបូង ក៏នឹងជំទាស់ជាមួយ គម្ពីរបដិសម្ភិទាមគ្គ និងគម្ពីរដទៃៗ ដែលបានពោលដល់វិបស្សនាញាណ ពួកនោះជាលំដាប់ដំបូង ។

ចំណែកវិបស្សនាយានិកមានវិធីបដិបត្តិដូចតទៅនេះ ៖

ឥធ បនេកច្ចោ វុត្តប្បការំ សមថំ អនុប្បាទេត្វាវ បញ្ចុបាទានក្ខន្ធេ អនិច្ចាទីហិ វិបស្សតិ ។ អយំ វិបស្សនា ។ តស្ស វិបស្សនាបរិបូរិយា តត្ថ ជាតានំ ធម្មានំ វោសគ្គារម្មណតោ ឧប្បជ្ជតិ ចិត្តស្ស ឯកគ្គតា ។ អយំ សមថោ ។ ឥតិ បឋមំ វិបស្សនា, បច្ឆា សមថោ ។ តេន វុច្ចតិ **វិបស្សនាបុព្វង្គមំ សមថំ ភាវេតីតិ** ។ តស្ស វិបស្សនាបុព្វង្គមំ សមថំ ភាវយតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ ភាវេតិ ពហុលីករោតិ ។ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ បហីយន្តិ ។ អនុសយា ព្យន្តីតិ ហោន្តិ ។

ចំណែកអ្នកបដិបត្តិពួកខ្លះ ក្នុងសាសនានេះ មិនបានចម្រើនសមថៈ តាមប្រភេទដែលពោលទុកហើយ រមែងកំណត់ដឹងឧបាទានក្ខន្ធ ៥ ដោយសភាពមិនទៀងជាដើម ។ បញ្ញានេះ ឈ្មោះថា វិបស្សនា ។ កាលមានសេចក្តីបរិបូណ៌នៃវិបស្សនាសមាធិ ដែលធ្វើចិត្តឲ្យជាអារម្មណ៍តែមួយ (សម្មាសមាធិមគ្គ) រមែងកើតឡើងដល់អ្នកបដិបត្តិ ព្រោះធម៌ (គឺចិត្តនិងចេតសិក) ដែលកើតឡើងក្នុងវិបស្សនាចិត្តនោះ លះបង់អារម្មណ៍ខាងក្រៅចេញបាន ។ សមាធិនេះ ឈ្មោះថា សមថៈ ។ វិបស្សនារមែងកើតមុន សមថៈរមែងកើតក្នុងពេលខាងក្រោយ ។ ព្រោះហេតុនោះទើបពោលថា **ចម្រើនសមថៈ ដែលមានវិបស្សនាជាបាទ** ដូច្នេះ ។ កាលចម្រើនសមថៈ ដែលមានវិបស្សនាជាបាទ មគ្គរមែងកើតឡើង អ្នកបដិបត្តិសេពចម្រើន អប់រំមគ្គនោះ កាលកំពុងសេពចម្រើនអប់រំមគ្គនោះ រមែងលះបង់ សំយោជនៈបាន អនុស័យក៏រមែងអស់ទៅ ។

ព្រះដីកាចារ្យ អធិប្បាយទុកក្នុងមជ្ឈិមបណ្ណាសដីកាថា វិបស្សនាយានិកមិនបានចម្រើនសមថកម្មដ្ឋាន បានទម្លុះឧបចារសមាធិ ឬអប្បនាសមាធិមកមុន ។ តែចាប់ផ្តើមចម្រើនខណិកសមាធិជាលំដាប់ដំបូង នឹងញុំាងឲ្យកើតនាមរូបបរិច្ឆេទញ្ញាណ និងបច្ចយបរិគ្គហញ្ញាណ ដែលសម្តែងទុកដោយបធានន័យ ហើយទើបកំណត់ដឹងរូបធម៌ នាមធម៌ ដោយសភាពមិនទៀង ។ល។ តាំងតែអំពីសម្មសនញ្ញាណជាដើមទៅ ។

ក្រៅអំពីនេះ លោកបានអធិប្បាយបំពេញសេចក្តីថា កាលវិបស្សនាចាស់ក្លាហើយ សមថៈ គឺសមាធិទើបកើតឡើងបាន វិបស្សនាដែលចាស់

ក្ខា គឺវុដ្ឋានគាមិវិបស្សនា ចំណែកសមថៈ ក្នុងទីនេះគឺមគ្គសមាធិ តែក្នុង សមថបុព្វង្គមន័យ ( ន័យដែលមានសមថៈកើតមុន ) សមថៈ ដែលកើត មុន និងវិបស្សនាដែលកើតខាងក្រោយជាលោកិយធម៌ដូចគ្នា យ៉ាងណា សម្បីក្នុងវិបស្សនាបុព្វង្គមន័យ (ន័យដែលមានវិបស្សនាកើតមុន) វិបស្សនា ដែលកើតមុន និងសមថៈដែលកើតក្នុងពេលខាងក្រោយ ក៏គួរជាលោកិយ ធម៌ ដូចគ្នា ដូច្នោះ ដោយហេតុនេះ សមថៈក្នុងទីនេះ ទើបគួរជា ខណិក សមាធិ ដែលប្រកបជាមួយវិបស្សនាញាណ សម្បីគម្ពីរអដ្ឋកថា អង្គុត្តរ-និកាយក៏ពោលថា ៖

វិបស្សនំ បុព្វង្គមំ បុរេចារិកំ កត្វា សមថំ ភាវេតិ ។ បកតិយា វិបស្សនាលាភី វិបស្សនាយ ឋត្វា សមាធឹ ឧប្បាទេតីតិ អត្ថោ ។

អ្នកបំពេញព្យាយាម ធ្វើវិបស្សនាឲ្យជាខាងដើម គឺ ធ្វើឲ្យកើត ឡើងមុនហើយចម្រើនសមាធិ បានសេចក្តីថា អ្នកសម្រេចវិបស្សនា ញាណដោយប្រក្រតី និងតាំងនៅក្នុងវិបស្សនាហើយទើបកើតសមាធិ ។

## វិបស្សនាញាណ ៣ លំដាប់

ម្យ៉ាងទៀត វិបស្សនាញាណបែងចេញជា ៣ លំដាប់គឺ

១. **ញាណថ្នាក់ខ្ពស់** សំដៅដល់កង្ខញ្ញាណជាដើមទៅ ខណិកសមាធិ ដែល ប្រកបដោយញាណ នេះជាសមាធិចាស់ក្លា ដូចសេចក្តីក្នុងគម្ពីរ បដិ-សម្ភិទាមគ្គថា **វយលក្ខណោបត្ថានេកគ្គ** ( ការតាំងមាំដែលប្រាកដ

ដោយលក្ខណៈរលត់ទៅ ) និងសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គដែលសម្តែងរឿងកន្តញ្ញាណ ។

**២. ញាណថ្នាក់កណ្តាល** សំដៅដល់ឧទយព្វយញ្ញាណ ខណិកសមាធិដែលប្រកបដោយញាណនេះ ជាសមាធិ ថ្នាក់កណ្តាល ដូចគម្ពីរវិសុទ្ធិមគ្គពោលដល់ញាណនេះថា **តរុណវិបស្សនា** ( វិបស្សនាដែលនៅមិនទាន់ចាស់ក្លា ) នឹងពោលដល់អ្នកដែលចូលដល់ព្រមដោយ ញាណនេះថា **អារទ្ធវិបស្សកៈ** (អ្នកប្រារព្ធវិបស្សនា) ទាំងស្របជាមួយព្រះបាលី ដែលពោលដល់អង្គគុណរបស់អ្នកបដិបត្តិ ( បធានិយង្គៈ ) ៥ ប្រការ ក្នុងសេចក្តីទីបំផុតថា ជាអ្នកតាមឃើញ ការកើតឡើងនិងរលត់ទៅ ជាការពិតហើយញាណនេះជាវិបស្សនាញាណជាន់ដំបូងក្នុងញាណ ដែលចាស់ក្លាបរិបូណ៌ ។

**៣. ញាណថ្នាក់ក្រោម** សំដៅដល់ នាមរូបបរិច្ឆេទញ្ញាណ និងបច្ចយបរិគ្គហញ្ញាណ ខណិកសមាធិដែលប្រកបដោយញាណនេះជាសមាធិជាន់ទាបតែយ៉ាងណាក៏ដោយ នីវរណៈ ៥ យ៉ាង រមែងមិនកើតឡើងក្នុងខណៈដែលកំណត់ដឹងសភាវធម៌ ក្នុងខណៈនោះ វិបស្សនាចិត្តនឹងបរិសុទ្ធប្រាសចាកនីវរណៈ ។ ញាណទាំងពីរនេះ ទើបកើតឡើងឃើញច្បាស់សភាវលក្ខណៈ គឺលក្ខណៈចំពោះនៃរូបនាមបាន សូម្បីខណិកសមាធិក្នុងញាណលំដាប់នេះ ក៏មានកម្លាំង ប្រៀបដូចជាមួយឧបចារសមាធិដូចគ្នា បើមិនដូច្នោះ ក៏មិនអាចឃើញច្បាស់រូបនាមតាម សេចក្តីពិត សមាធិនេះទើបចាត់ជាចិត្តវិសុទ្ធិ ដែលជាឧបការៈ ដល់ញាណទាំងពីរនោះ ដូចសេចក្តីថា យោ តត្ថ អវិក្ខេបង្គោ, អយំ អធិចិត្តសិក្ខា ។ "សភាព

*ដែលមិនឆាករេក្នុង វិបស្សនាចិត្ត ដែលប្រកបជាមួយនាមរូបបរិច្ឆេទញ្ញាណ និងបច្ចយបរិគ្គហញ្ញាណ នោះឈ្មោះថា អធិចិត្តសិក្ខា ។*

យំ នាមរូបបរិច្ឆេទាទីសុ វិបស្សនាញាណេសុ បដិបក្ខភាវតោ ទីបាលោកេនេវ តមស្ស តេន តេន វិបស្សនាញាណេន តស្ស តស្ស អនត្ថស្ស បហានំ ។ សេយ្យថីទំ ។ នាមរូបវវត្ថានេន សក្កាយទិដ្ឋិយា បច្ចយបរិគ្គហេន អហេតុវិសមហេតុទិដ្ឋីនំ ។បេ។ គោត្រភុនា សង្ខារ-និមិត្តគ្គាហស្ស បហានំ ។ ឯតំ តទង្គប្បហានំ នាម ។

*បណ្តាវិបស្សនាញាណ មាននាមរូបបរិច្ឆេទញ្ញាណជាដើមនោះ ការលះបង់ទោសនោះៗ រមែងមានដោយវិបស្សនាញាណនោះៗ ព្រោះជាបដិបក្ខនឹងគ្នា ដូចការកំចាត់ភាពងងឹតដោយពន្លឺប្រទីបពោលគឺ ការលះសក្កាយ-ទិដ្ឋិ ដោយការកំណត់ដឹងរូបនាម ការលះទិដ្ឋិដែលយល់ថា មិនមានហេតុដែលមិនសមគួរ ដោយការកំណត់ដឹងបច្ច័យ ។ ល ។ ការលះសេចក្តីប្រកាន់មាំក្នុងអារម្មណ៍ ដែលជាសង្ខារធម៌ដោយគោត្រភូទាំងអស់នេះ ឈ្មោះថា តទង្គប្បហាន (ការលះដោយហេតុ គឺ វិបស្សនានោះៗ) ” ។*

*កាលខណិកសមាធិចាស់ក្លាឡើងៗ ការតាំងមាំនៃចិត្ត ដូចជាឈានក្នុងសមថភាវនា រមែងកើតឡើង សូម្បីអារម្មណ៍ដែលជារូបនាមនឹងផ្លាស់ប្តូរទៅតាមសភាវៈប្រាកដច្បាស់ ការតាំងមាំក៏ស្ថិតនៅយ៉ាងនេះលំដាប់ចិត្តដែលកើតមុន និងលំដាប់ចិត្ត ដែលកើតក្នុងពេលខាងក្រោយមានកម្លាំងស្មើគ្នា សមាធិដូចពោលមកនេះ ផ្សេងគ្នាអំពីឈានក្នុងសមថភាវនា គឺឈានក្នុងសមថភាវនា ទទួលដឹងអារម្មណ៍បញ្ញត្តិតែ*

ម្យ៉ាង មិនប្រាកដសភាពជារូបនាម ទាំងប្រាសចាកសភាវៈរបស់ត្រៃលក្ខណ៍ តែសមាធិរបស់វិបស្សនាទទួលដឹងអារម្មណ៍បច្ចុប្បន្ន ដែលផ្លាស់ប្ដូរទៅខ្លះ ទាំងប្រាកដសភាពជារូបនាម កាលញាណចាស់ក្លាឡើងក៏នឹងប្រចក្សព្រះត្រៃលក្ខណ៍ ដែលឃើញច្បាស់នូវសភាវៈកើតរលត់ជាដើម ។ ដូចសេចក្ដីក្នុងគម្ពីរមហាដីកាថា ៖

ខណិកចិត្តេកគ្គតាតិ ខណមត្តដ្ឋិតិកោ សមាធិ ។ សោបិ ហិ អារម្មណេ និរន្តរំ ឯកាការេន បវត្តមានោ បដិបក្ខេន អនភិភូតោ អប្បិតោ វិយ ចិត្តំ និច្ចលំ ឋបេតិ ។

"ពាក្យថា **ខណិកចិត្តេកគ្គតា** ( ការតាំងនៅនៃចិត្តមួយខណៈ ) មានសេចក្ដីថា សមាធិដែលតាំងនៅមួយខណៈដោយពិតហើយ សមាធិនោះ ត្រាច់ទៅក្នុងអារម្មណ៍ដោយអាការៈតែម្យ៉ាង ជាប់បន្តគ្នា ដោយមិនត្រូវនីវរណៈ ដែលជាបដិបក្ខគ្របសង្កត់ រមែងតាំងចិត្តទុកមាំដូចឈានសមាធិ ដែលឈានចុះហើយ " ។

សេចក្ដីខាងដើម ជាពាក្យអធិប្បាយ ដែលព្រះដីកាចារ្យគាំទ្រសេចក្ដីគម្ពីរអដ្ឋកថារបស់មហាសតិប្បដ្ឋានសូត្រ ដែលពោលថា វិបស្សនាចិត្ត តាំងមាំបានដោយខណិកសមាធិ ក្នុងកាលចម្រើនអានាបានៈថា **ចិត្តំ សមាទហតោ** ( អ្នកតាំងចិត្តទុកមាំ ) ដោយបង្ហាញឲ្យឃើញថា ក្រៅអំពីសមាធិដែលជាឧបចារៈ និងអប្បនាហើយ សូម្បីវិបស្សនាខណិកសមាធិក៏អាចតាំងចិត្តទុកមាំបានដូចគ្នា ។

ពាក្យថា **អារម្មណេ និរន្តរំ ឯកាការេន បវត្តមានោ** ( ត្រាច់ទៅក្នុងអារម្មណ៍ដោយអាការៈតែម្យ៉ាងជាប់តគ្នា ) សម្តែងថា កាលខណិកសមាធិ មានកម្លាំងស្មើគ្នាជាមួយឧបចារសមាធិ នីវរណៈ ៥ នោះ មិនអាចកើតឡើងទេ ការកំណត់ដឹង រមែងប្រព្រឹត្តទៅយ៉ាងបន្តបន្ទាប់ជានិច្ច ។

ពាក្យថា **បដិបក្ខេន អនភិភូតោ អប្បិតោ វិយ ចិត្តំ និច្ចលំ ឋបេតិ** (មិនត្រូវនីវរណៈ ដែលជាបដិបក្ខគ្របសង្កត់ រមែងតម្កល់ចិត្តតាំងទុកមាំដូចឈានសមាធិដែលឈានចុះហើយ) សេចក្តីថា ខណិកសមាធិដែលកើត ព្រមជាមួយឧទយព្វយញ្ញាណ និងកង្គញ្ញាណជាដើមទៅមានកម្លាំងច្រើន ជាងខណិកសមាធិក្នុងញាណដើម ៗ ដោយមានកម្លាំងស្មើនឹងអប្បនាសមាធិ ក្នុងសមថភាវនា ខណិកសមាធិនេះមិនត្រូវនីវរណៈរុកគួន នឹងអាចឲ្យចិត្តតាំងមាំ ដូចជាអប្បនាសមាធិដែរ ។

សរុបសេចក្តីមក វិបស្សនាយានិក មិនចម្រើនឧបចារសមាធិ ឬអប្បនាសមាធិចាប់ផ្តើមចម្រើនវិបស្សនា ដោយកំណត់ដឹងសភាវធម៌ដែលជារូបនាមបានទាន់ពេល តមកវិបស្សនាញាណរមែងកើតឡើង កាលវិបស្សនាញាណចាស់ក្លាឡើង តាំងតែអំពីឧទយព្វយញ្ញាណជាដើមទៅហើយសមាធិក៏នឹងតាំងនៅមាំជាងខាងដើម ។ សេចក្តីដែលសម្តែងដល់សមថបុព្វង្គមន័យ និងវិបស្សនាបុព្វង្គមន័យដែលឃើញក្នុងគម្ពីរអដ្ឋកថាដូចដែលពោលមកនេះ ស្របគ្នាជាមួយសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គថា៖

រូបំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ។ រូបំ ទុក្ខតោ អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា ។ តត្ថ ជាតានំ ធម្មានំ ច វោសគ្គារម្មណតា ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ។ ឥតិ បឋមំ វិបស្សនា, បច្ឆា សមថោ ។ តេន វុច្ចតិ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ ។

ឈ្មោះថា វិបស្សនា ព្រោះជាសភាវៈឃើញរូបថា ជារបស់មិនទៀង ព្រោះជាសភាពឃើញរូបថា ជាទុក្ខ មិនមែនតួខ្លួន ការលះអារម្មណ៍ខាងក្រៅ ការមានអារម្មណ៍តែមួយនៃចិត្ត ការមិនរាយរាយនៃធម៌ [ គឺចិត្តនិង ចេតសិក ] ដែលកើតក្នុងវិបស្សនាចិត្តនោះ ឈ្មោះថា សមថៈដោយប្រការដូច្នេះ វិបស្សនារមែងកើតមុន ឯសមថៈរមែងកើតក្នុងពេលខាងក្រោយ ទើបពោលថា ( ចម្រើនសមថៈ ដោយមានវិបស្សនា ជាបាទ ) ។

ក្រៅអំពីសមថបុព្វង្គមន័យ និងវិបស្សនាបុព្វង្គមន័យហើយក្នុង គម្ពីរបដិសម្ភិទាមគ្គនៅពោលដល់យុគនទ្ធន័យ គឺន័យប្រកបចូលគ្នាជាគូនិងធម្មុទ្ធច្ចវិហានន័យ គឺន័យដែលលះបង់សេចក្ដីរវើរវាយក្នុងសភាវធម៌ ន័យទាំងពីរនេះ រាប់ក្នុងសមថបុព្វង្គមន័យនិងវិបស្សនាបុព្វង្គមន័យដូចគ្នា ក្នុងគម្ពីរអដ្ឋកថា ទើបសម្ដែងទុកត្រឹមតែពីរន័យប៉ុណ្ណោះ ។

យុគនទ្ធន័យ ប្រែថា " ន័យប្រកបចូលគ្នាជាគូ " សំដៅដល់អ្នកបដិបត្តិ អ្នកបន្ទុះឈានបានចម្រើនសមថៈ និងវិបស្សនាផ្គួបចូលគ្នាទៅ តាមលំដាប់ឈាន ដោយចូលបឋមជ្ឈាន ហើយចម្រើនវិបស្សនាកំណត់ដឹងឈានចិត្ត ក្រោយអំពីនោះទើបចូលទុតិយជ្ឈាន ហើយកំណត់ដឹងឈានចិត្តទៀត គេចូលឈានតាមលំដាប់ព្រមជាមួយការចម្រើនវិបស្សនា

កាលចេញអំពីឈាននោះ ៗ រហូតបន្ទុះមគ្គ ន័យនេះរាប់ចូលក្នុងសមថ-បុព្វង្គមន័យ ព្រោះចម្រើនវិបស្សនាដោយមានសមថៈជាបាទ ។

ធម្មុទ្ធច្ចបហានន័យ ប្រែតាមស័ព្ទថា " ន័យលះសេចក្ដីសង្ស័យក្នុងសភាវធម៌ " សំដៅដល់កាលវិបស្សនាទូបកិលេស គឺឱភាស ( ពន្លឺ ) ជាដើម កើតឡើងក្នុងខណៈទម្ទុះឧទយព្វយញ្ញាណដល់សមថយានិក ឬវិបស្សនាយានិក ខណៈនោះ អ្នកបដិបត្តិអាចយល់ខុសថា ឱភាសជាដើមនោះជាគុណធម៌វិសេស គឺមគ្គផលនិងសំគាល់ថា ខ្លួននោះបានសម្រេចមគ្គផល ហើយការសំគាល់ដូច្នេះជាសេចក្ដីរវើរវាយក្នុងសភាវធម៌ កាលកើតសេចក្ដីរវើរវាយយ៉ាងនេះ រូបនាមដែលធ្លាប់ប្រាកដច្បាស់ក៏មិនប្រាកដច្បាស់ ការកំណត់ដឹង រមែងដាច់មិនជាប់បន្តគ្នាក្នុងខណៈនោះ អ្នកបដិបត្តិមិនគួរធ្វើទុកក្នុងចិត្តចំពោះឱភាសជាដើម តែគួរកំណត់ដឹងរូបនាមដូចដើមវិញ កាលកំណត់ដូច្នេះ សេចក្ដីរវើរវាយក្នុងសភាវធម៌ នឹងអន្តរធានទៅ ។ រូបនាមប្រាកដច្បាស់ដូចគ្រាមុន ការកំណត់ដឹងនិងតាំងនៅមាំ ក្នុងរូបនាមដែលជាអារម្មណ៍ខាងក្នុងប៉ុណ្ណោះ ក្រៅអំពីនោះវិបស្សនាញាណ រមែងចាស់ក្លាតាមលំដាប់រហូតដល់សម្រេចមគ្គញ្ញាណ ន័យដូចដែលពោលនេះ រាប់ចូលក្នុងសមថបុព្វង្គមន័យ និងវិបស្សនា-បុព្វង្គមន័យពីរយ៉ាង ព្រោះជាប់ទាក់ទងដោយសមថយានិក និងវិបស្សនាយានិក ព្រះអដ្ឋកថា ទើបពោលដល់ភាវនាន័យទុក ពីរប្រការប៉ុណ្ណោះ ។

ដោយហេតុនេះ វិបស្សនាយានិក ទើបមិនចាំបាច់ត្រូវចម្រើនសមថភាវនា ដើម្បីឲ្យកើតចិត្តបរិសុទ្ធិ តែគួរចម្រើនវិបស្សនាបានគ្រប់

ពេល និងខណិកសមាធិដែលកើតឡើងកាលវិបស្សនាញាណចាស់ក្លា ក៏ជាចិត្តវិសុទ្ធិរបស់បុគ្គលនោះ ។

## វិសុទ្ធិ ៧

វិសុទ្ធិ មានន័យថា សេចក្តីបរិសុទ្ធដ៏វិសេស បានដល់ សីល សមាធិ និងបញ្ញា មាន ៧ យ៉ាងគឺ ៖

| | |
|---|---|
| ១.សីលវិសុទ្ធិ | ជា សីលសិក្ខា |
| ២.ចិត្តវិសុទ្ធិ | ជា ចិត្តសិក្ខា |
| ៣.ទិដ្ឋិវិសុទ្ធិ | ជា បញ្ញាសិក្ខា លោកិយៈ |
| ៤.កង្ខាវិតរណវិសុទ្ធិ | ជា បញ្ញាសិក្ខា លោកិយៈ |
| ៥.មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ | ជា បញ្ញាសិក្ខា លោកិយៈ |
| ៦.បដិបទាញាណទស្សនវិសុទ្ធិ | ជា បញ្ញាសិក្ខា លោកិយៈ |
| ៧.ញាណទស្សនវិសុទ្ធិ | ជា បញ្ញាសិក្ខា លោកុត្តរៈ |

## ១.សីលវិសុទ្ធិ

**សីលវិសុទ្ធិ** សម្រាប់ព្រះភិក្ខុ មានចតុប្បារិសុទ្ធិសីល និងសីលដែលជាពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាតទាំងអស់ ដែលបានបដិបត្តិជាប់ត្រឹមត្រូវហើយ ឬបានសម្តែងទោសទាំងអស់ចេញហើយ ឈ្មោះថា **សីលវិសុទ្ធិ**។ សម្រាប់គ្រហស្ថ មានសីល ៥ ឬសីល ៨ ឬក៏អតិរេកសីល ហើយបានរក្សាមាំទាំហើយ ឈ្មោះថា **សីលវិសុទ្ធិ** ។

## ២.ចិត្តវិសុទ្ធិ

ចិត្តវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃចិត្ត បានដល់ ខណិកសមាធិ ឧបចារសមាធិ ឬក៏អប្បនាសមាធិ ។

ខណិកសមាធិ ជាចិត្តវិសុទ្ធិរបស់សុទ្ធវិបស្សនាយានិក ។

ឧបចារសមាធិ ឬអប្បនាសមាធិ ជាចិត្តវិសុទ្ធិរបស់បុគ្គលដែលសមថយានិក។

## ៣.ទិដ្ឋិវិសុទ្ធិ

ទិដ្ឋិវិសុទ្ធិ កាលបែកបទហើយ មាន ២ បទ គឺ ទិដ្ឋិ ១ បទ វិសុទ្ធិ ១ បទ ។ ទិដ្ឋិ មានន័យ ការយល់ឃើញ, វិសុទ្ធិ សេចក្តីបរិសុទ្ធ សរុបចូលគ្នាសម្រេចរូបជា ទិដ្ឋិវិសុទ្ធិ មានន័យថា សេចក្តីបរិសុទ្ធនៃការឃើញ ដូចមានវចនត្ថៈថា ទិដ្ឋិយេវ វិសុទ្ធិ ទិដ្ឋិវិសុទ្ធិ ជាញាណដែលអាចដឹងរូបធម៌ នាមធម៌ដោយ ៖

**១.លក្ខណៈ** គឺដឹងលក្ខណៈចំពោះខ្លួន (បច្ចត្តលក្ខណៈ) របស់រូបធម៌ នាមធម៌

**២.រស** គឺដឹងនាទីឬកិច្ចរបស់រូបធម៌ នាមធម៌

**៣.បច្ចុបដ្ឋាន:** គឺដឹងផលឬអាការៈប្រាកដរបស់រូបធម៌ នាមធម៌

**៤.បទដ្ឋាន** គឺដឹងហេតុជិតរបស់រូបធម៌ នាមធម៌ ។

ការដឹងរូបធម៌ នាមធម៌យ៉ាងនេះ ទើបហៅថា **ទិដ្ឋិវិសុទ្ធិ** អង្គធម៌បានដល់ បញ្ញាចេតសិក ក្នុងមហាកុសលញាណសម្បយុត្តចិត្ត ៤ ដែលមានរូបធម៌ នាមធម៌ ជាអារម្មណ៍ (ការសម្តែងលក្ខណៈ រស បច្ចុបដ្ឋានបទដ្ឋានរបស់ចិត្ត ចេតសិក រូប ដែលមានក្នុងបដិច្ចសមុប្បាទ) ។

ការដឹងរូបធម៌ នាមធម៌ដោយអំណាចនៃ លក្ខណៈ រស បច្ចុបដ្ឋាន និងបទដ្ឋានដូចពោលមកនេះ ។ សូម្បីមិនដឹងទាំង ៤ ក៏ដោយ ត្រឹមតែដឹងយ៉ាងណាមួយ ក្នុងបួននេះ ក៏បានឈ្មោះថា ទិដ្ឋិវិសុទ្ធិ ។ ទិដ្ឋិវិសុទ្ធិនេះ បើពោលក្នុងញាណ ១៦ ចាត់ជានាមរូបបរិច្ឆេទញាណ ។

នាមរូបបរិច្ឆេទញាណ បញ្ញាកំណត់ដឹងឃើញរូបធម៌ នាមធម៌តាមសភាវៈដ៏ពិត ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ព្រោះជម្រះចិត្តឲ្យប្រាសចាកសក្កាយទិដ្ឋិ ។

## ទិដ្ឋិវិសុទ្ធិក្នុងខណៈកំណត់ដឹងរូបនិងនាម

ខ្យល់ប្រកបដោយរូបកលាបៈ ៨ យ៉ាង គឺធាតុដី (បឋវីធាតុ) ធាតុទឹក (អាបោធាតុ) ធាតុភ្លើង (តេជោធាតុ) ធាតុខ្យល់ (វាយោធាតុ) ពណ៌ (វណ្ណធាតុ) ក្លិន (គន្ធធាតុ) រស (រសធាតុ) និងឱជា (រសអាហារ) ។ ចំណែកក្នុងវេលាមានសំឡេងកើតឡើង ព្រមជាមួយខ្យល់ដង្ហើមក៏មានរូបកលាប ៩ យ៉ាង បន្ថែមសំឡេង (សទ្ទធាតុ) យ៉ាងណាក៏ដោយ ធាតុទាំង ៤ គឺ ធាតុដី ធាតុទឹក ធាតុភ្លើង និងធាតុខ្យល់ ជាគោលសំខាន់ក្នុងការចម្រើនសតិរលឹកដឹង ។

## ៤.កង្ខាវិតរណវិសុទ្ធិ

*សេចក្តីបរិសុទ្ធិ គឺញាណដែលឆ្លងផុតសេចក្តីសង្ស័យ*

*កង្ខាវិតរណវិសុទ្ធិ មានវចនត្ថៈថា កង្ខាវិតរណា ឯវ វិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ ប្រែថា បញ្ញាដែលអាចដឹងហេតុនៃរូបធម៌ នាមធម៌ទាំង ២ គឺ* **រូបសមុទយៈ** *ហេតុរបស់រូប* **នាមសមុទយៈ** *ហេតុរបស់នាម ។ កាលដឹងហេតុរបស់រូបធម៌ នាមធម៌ទាំង ២ យ៉ាងនេះ ក៏ឈានកន្លងសេចក្តីសង្ស័យបាន ដូច្នោះ ញាណនោះ ទើបឈ្មោះថា* **កង្ខាវិតរណវិសុទ្ធិ** *អង្គធម៌ បានដល់ បញ្ញាចេតសិក ក្នុងមហាកុសលញាណសម្បយុត្តចិត្ត ដែលមានបច្ច័យរបស់រូបធម៌ នាមធម៌ជាអារម្មណ៍ ។*

*បច្ច័យរបស់រូបធម៌ នាមធម៌គឺ*

***១.បច្ច័យឲ្យកើតរូប និងនាម*** *(ចិត្ត ចេតសិក និងកម្មជរូប) ក្នុងបដិសន្ធិកាល បានដល់ អវិជ្ជា តណ្ហា ឧបាទាន កម្ម ។*

***២.បច្ច័យឲ្យកើតនាម*** *(ចិត្ត ចេតសិក) ក្នុងបវត្តិកាល បានដល់ វត្ថុរូប ៦ មានចក្ខុវត្ថុរូបជាដើម ដែលជាវត្ថុបុរេជាតនិស្សយប្បច្ច័យ និងអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ដែលជាអារម្មណប្បច្ច័យ ។*

***៣.បច្ច័យឲ្យកើតរូប*** *(ចតុសមុដ្ឋានិករូប) ក្នុងបវត្តិកាល បានដល់ កម្ម ចិត្ត ឧតុ អាហារ (កពឡីការាហារ) ។*

***៤.បច្ច័យឲ្យកើតនាម*** *(វិបាកចិត្ត ចេតសិក) បានដល់ កុសល អកុសល ។*

***៥.បច្ច័យឲ្យកើតនាម*** *(អាវជ្ជនចិត្ត ចេតសិក) បានដល់ ករង្គបច្ចេទៈ ដែលកើតឡើង ដោយអំណាចអនន្តរប្បច្ច័យជាដើម ។*

*កង្ខាវិតរណាវិសុទ្ធិនេះ បើពោលក្នុងញាណ ១៦ ចាត់ជាបច្ច័យ-បរិគ្គហញ្ញាណ បញ្ញាដែលកំណត់ដឹង ឃើញហេតុបច្ច័យរបស់រូបនិង នាម ដែលកើតខាងក្នុងខ្លួន ព្រោះឈានកន្លងផុតសេចក្តីសង្ស័យ ៨ យ៉ាង ដែលមកក្នុងព្រះអភិធម្ម និងសេចក្តីសង្ស័យ ១៦ យ៉ាង ដែលជាប់ទាក់ទងកាល ៣ ដែលមកក្នុងព្រះសូត្រ ។*

*សេចក្តីសង្ស័យ ៨ យ៉ាង ក្នុងព្រះអភិធម្ម*

**១.ពុទ្ធេ កង្ខតិ** *សង្ស័យក្នុងព្រះពុទ្ធ គឺគុណទាំង ៩ មាន* **អរហំ** *ជាដើម ថា មានពិត ដូចពោលមកហើយ ឬអត់មានទេហ្ន៎ ?*

**២.ធម្មេ កង្ខតិ** *សង្ស័យក្នុងព្រះធម៌ គឺគុណទាំង ៦ មាន* **ស្វាក្ខាតោ** *ជាដើម ថា មានពិត ដូចពោលមកហើយ ឬអត់មានទេហ្ន៎ ?*

**៣.សង្ឃេ កង្ខតិ** *សង្ស័យក្នុងព្រះសង្ឃ គឺគុណទាំង ៩ មាន* **សុបដិបន្នោ** *ជាដើម ថា មានពិត ដូចពោលមកហើយ ឬអត់មានទេហ្ន៎ ?*

**៤.សិក្ខាយ កង្ខតិ** *សង្ស័យក្នុងសិក្ខាបទ គឺ ខបដិបត្តិជាប់ទាក់ទង ជាមួយ សីល សមាធិ បញ្ញា តើខបដិបត្តិ ដែលព្រះពុទ្ធត្រាស់បង្រៀនទុកមក ខុសត្រូវប្រការណាទៅហ្ន៎ នឹងបានទទួលប្រយោជន៍ពិត ឬទេហ្ន៎?*

**៥.បុព្វន្តេ កង្ខតិ** *សង្ស័យក្នុងខន្ធ ៥ ដែលជាអតីតៈ គឺសង្ស័យថា សត្វទាំងឡាយធ្លាប់កើតមកហើយ ក្នុងអតីតៈ នឹងមានពិត ឬអត់ទេហ្ន៎?*

**៦.អបរន្តេ កង្ខតិ** *សង្ស័យក្នុងខន្ធ ៥ ដែលជាអនាគត គឺ សង្ស័យថា សត្វទាំងឡាយស្លាប់ហើយ នឹងកើតតទៅខាងមុខ នឹងមានពិត ឬអត់ទេ?*

**៧.បុព្វន្តាបរន្តេ កង្ខតិ** *សង្ស័យក្នុងខន្ធ ៥ ទាំងអតីតៈ ទាំង អនាគត គឺ សត្វទាំងឡាយកំពុងប្រាកដក្នុងបច្ចុប្បន្ននេះ ធ្លាប់កើតមក ហើយឬអត់ទេហ្ន៎ តើនឹងកើតតទៅទៀតទេហ្ន៎?*

**៨.ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ កង្ខតិ** *សង្ស័យក្នុងបដិច្ចសមុប្បន្នធម៌ មានសង្ខារជាដើម ក្នុងបដិច្ចសមុប្បាទធម៌ មានអវិជ្ជាជាដើម ជាបច្ច័យ ក្នុងរឿងបុណ្យ បាប និងការបន្តក្នុងភពថ្មី ការឃើញ ការបានឮរបស់សត្វទាំងឡាយជាដើម ដែលជាប់ទាក់ទងជាមួយសេចក្តីវង្វេង និងការតាក់តែងចាត់ចែងនៃ កាយ វាចា ចិត្ត ជាដើម ដោយហេតុនោះតែងមានពិត ឬអត់ទេហ្ន៎ ?*

## សេចក្តីសង្ស័យ ១៦ យ៉ាង ដែលមកក្នុងព្រះសូត្រ

*សង្ស័យក្នុង ខន្ធ ៥ ដែលជាចំណែកអតីតៈ, អនាគត ៥,*

*បច្ចុប្បន្ន ៦ មានដូចតទៅ ៖*

**១.អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** *យើងធ្លាប់កើតមកហើយក្នុងអតីតកាល ពិតឬអត់ទេហ្ន៎?*

**២.ន នុ ខោ អហោសឹ អតីតមទ្ធានំ** *យើងមិនធ្លាប់កើតមកហើយក្នុងអតីតកាល ពិតឬអត់ទេហ្ន៎?*

**៣.កឹ នុ ខោ អហំ អតីតមទ្ធានំ** *បើធ្លាប់កើតហើយ តើកើតជាជនប្រភេទជាន់ណាក្នុងអតីតកាលហ្ន៎?*

**៤.កថំ នុ ខោ អហោសឹ អតីតមទ្ធានំ** *យើងមានរូបរាងសណ្ឋានជាយ៉ាងណាក្នុងអតីតកាលហ្ន៎?*

**៥.កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** *យើងធ្លាប់កើតជាអ្វីមកហើយនិងធ្លាប់កើតជាអ្វីតអ្វីខ្លះហ្ន៎ក្នុងអតីតកាល?*

*សង្ស័យក្នុងខន្ធ ៥ ដែលជាចំណែកអនាគត ៥ គឺ*

**១.ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** *យើងនឹងកើតក្នុងកាលខាងមុខឬអត់ទេហ្ន៎?*

**២.ន នុ ខោ ភវិស្សាមិ អហំ អនាគតមទ្ធានំ** *យើងនឹងមិនកើតក្នុងកាលខាងមុខឬអត់ទេហ្ន៎?*

**៣.កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** *បើនឹងកើត តើនឹងកើតជាជនជាន់ណាក្នុងកាលខាងមុខហ្ន៎?*

**៤.កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** *យើងនឹងមានរូបរាងសណ្ឋាន ជាយ៉ាងណា ក្នុងកាលអនាគតហ្ន៎?*

**៥.កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** *យើងនឹងកើតជាអ្វីហើយ តើនឹងកើតជាអ្វីទៀតៗ ក្នុងខាងមុខហ្ន៎?*

**សង្ស័យក្នុងខន្ធ ៥ ដែលជាចំណែកបច្ចុប្បន្ន ៦ គឺ**

**១.អហំ នុ ខោស្មិ** *ឥឡូវនេះជាយើងឬទេហ្ន៎?*

**២.នោ នុ ខោស្មិ** *ឥឡូវនេះមិនជាយើងឬហ្ន៎?*

**៣.កឹំ នុ ខោស្មិ** *ឥឡូវនេះ យើងជាជាតិអ្វីហ្ន៎?*

**៤.កថំ នុ ខោស្មិ** *ឥឡូវនេះ យើងមានរូបរាងសណ្ឋានយ៉ាងណាហ្ន៎?*

**៥.អយំ នុ ខោ សត្តោ កុតោ អាគតោ** *សត្វនេះមកពីណាហ្ន៎?*

**៦.សោ កុហឹំ គាមី ភវិស្សាមិ** *សត្វនោះ នឹងទៅកើតទីណាហ្ន៎?*

## ៥.មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ

*សេចក្តីបរិសុទ្ធិគឺការដឹងនូវមគ្គនិងមិនមែនមគ្គ*

**មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** *មានន័យថា សេចក្តីបរិសុទ្ធិក្នុងការឃើញច្បាស់របស់ញាណថា ជាមគ្គបដិបទា និងមិនមែនជាមគ្គបដិបទា ។ អង្គធម៌ បានដល់បញ្ញាចេតសិក ។*

**មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** *នេះបើពោលទុកក្នុងញាណ ១៦ បានដល់* **សម្មសនញ្ញាណ** *គឺបញ្ញាដែលពិចារណាក្នុងលក្ខណៈទាំង ៣ របស់រូបនិងនាម និងឧទយព្វយញ្ញាណ គឺបញ្ញាដែលឃើញសេចក្តីកើតឡើងនិងរលត់ទៅរបស់រូបនិងនាម ។ ព្រោះវិបស្សនាញាណទាំងពីរនេះ ជម្រះចិត្ត ឲ្យផុតចាកគាហៈ (សេចក្តីប្រកាន់) ទាំង ៣ គឺសេចក្តីប្រកាន់មាំដោយ តណ្ហា មានៈ ទិដ្ឋិ ក្នុងឧបកិលេស ១០ យ៉ាង ណាមួយកើត*

*ឡើង។ បញ្ញា ដែលកំណត់វិនិច្ឆ័យលក្ខណៈមគ្គថា ឱភាសជាដើមនេះ មិនមែនមគ្គ ព្រោះជាហេតុ ជាទីតាំងនៃ តណ្ហា មានៈ ទិដ្ឋិ ដោយពិត ។ តែវិបស្សនាញាណដែលដំណើរ ទៅតាមវិថី ផុតពីវិបស្សនូបកិលេសមាន ឱភាសជាដើមនោះ ជាមគ្គ ឈ្មោះថា* **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** *ព្រោះឃើញផ្លូវនិងមិនមែនផ្លូវ និងជម្រះនូវសេចក្ដីសម្គាល់ខុសក្នុង វិបស្សនូបកិលេស ដែលមិនមែនផ្លូវថា មិនមែនជាផ្លូវ ។*

**វិបស្សនូបកិលេស មាន ១០ យ៉ាងគឺ**

**១.ឱភាស** *ពន្លឺ*

**២.ញាណ** *ញាណ*

**៣.បីតិ** *បីតិ*

**៤.បស្សទ្ធិ** *សេចក្ដីស្ងប់*

**៥.សុខ** *សេចក្ដីសុខ*

**៦.អធិមោក្ខ** *ការជឿស៊ប់*

**៧.បគ្គាហៈ** *សេចក្ដីព្យាយាម*

**៨.ឧបដ្ឋានៈ** *សតិ*

**៩.ឧបេក្ខា** *ឧបេក្ខា*

**១០.និកន្តិ** *សេចក្ដីត្រេកអរ ។*

## វិបស្សនូបកិលេស មិនកើតដល់បុគ្គល ៣ ជំពូក

១.ព្រះអរិយបុគ្គល អ្នកដល់បដិវេធហើយ

២.យោគីអ្នកបដិបត្តិខុសផ្លូវវិបស្សនា

៣.យោគីអ្នកខ្ជិលច្រអូសលះបង់កម្មដ្ឋាន ។

អ្នកមានសេចក្តីព្យាយាមខ្លាំងក្លាប៉ុណ្ណោះ ទើបវិបស្សនូបកិលេសកើតមាន ។ វិបស្សនូបកិលេសកើតត្រង់ តរុណឧទយព្វយញ្ញាណ គឺឧទយព្វយញ្ញាណទន់ខ្ចី និងវិបស្សនាញាណដែលសង្គ្រោះចូលក្នុង មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ មាន ២ គឺសម្មសនញ្ញាណ និងតរុណឧទយព្វយញ្ញាណ គឺឧទយព្វយញ្ញាណយ៉ាងទន់ ។

## ៦.បដិបទាញាណទស្សនវិសុទ្ធិ

**បដិបទាញាណទស្សនវិសុទ្ធិ** ប្រែថា សេចក្តីបរិសុទ្ធក្នុងការឃើញច្បាស់របស់ញាណ ដែលជាដំណើរទៅកាន់មគ្គបដិបទា ។

**បដិបទាញាណទស្សនវិសុទ្ធិ**
មានវិបស្សនាញាណដែលសង្គ្រោះចូល មាន ៩ គឺ

១.ពលវឧទយព្វយញ្ញាណ ២.ភង្គញ្ញាណ

៣.ភយញ្ញាណ ៤.អាទីនវញ្ញាណ

៥.និព្វិទាញាណ ៦.មុញ្ចិតុកម្យតាញាណ

៧.បដិសង្ខាញាណ ៨សង្ខារុបេក្ខាញាណ

*៩.អនុលោមញ្ញាណ ។*

*វិបស្សនាញាណទាំង ៩ នេះ ចាត់ជាបដិបទាញាណវិសុទ្ធិ ព្រោះធ្វេង ផុតពីវិបស្សនូបកិលេស ១០ យ៉ាងជាដើម និងជម្រះចិត្តឲ្យផុតចាក សេចក្តីចាំខុសទាំង ៣ និច្ចសញ្ញា ១ សុខសញ្ញា ១ អត្តសញ្ញា ១ ។*

## ៧.ញាណទស្សនវិសុទ្ធិ

*សេចក្តីបរិសុទ្ធ គឺឃើញច្បាស់ក្នុងអរិយសច្ចៈ*

**ញាណទស្សនវិសុទ្ធិ** *ប្រែថា សេចក្តីបរិសុទ្ធនៃការដឹងនិងការ ឃើញ ដូចមានវចនត្ថៈថា*

**១.ចតុសច្ចំ ជានាតីតិ ញាណំ** *ដឹងអរិយសច្ចៈបាន ដូច្នោះ ហៅថា ញាណ*

**២.បច្ចក្ខតោ បស្សតីតិ ទស្សនំ** *ឃើញព្រះនិព្វានដោយប្រចក្ស ដូច្នោះ ហៅថា ទស្សនៈ*

**៣.កិលេសមលតោ វិសុជ្ឈតីតិ វិសុទ្ធិ** *សេចក្តីបរិសុទ្ធិពីកិលេស ដែលជាមន្ទិល ដូច្នោះ ទើបហៅថា វិសុទ្ធិ ។*

**ញាណទស្សនវិសុទ្ធិ** *នេះ អង្គធម៌ បានដល់ បញ្ញាចេតសិក ក្នុងមគ្គ ចិត្ត។*

# សោឡសញ្ញាណ

ញាណ ១៦

**១.នាមរូបបរិច្ឆេទញ្ញាណ** បញ្ញាដែលកំណត់ដឹងរូបនិងនាមតាមសភាវៈពិត

**២.បច្ចយបរិគ្គហញ្ញាណ** បញ្ញាកំណត់ដឹងហេតុបច្ច័យរបស់រូប និងនាមតាមសភាវៈពិត

**៣.សម្មសនញ្ញាណ** បញ្ញាដែលឃើញរូបនិងនាមជាត្រៃលក្ខណ៍

**៤.ឧទយព្វយញ្ញាណ** បញ្ញាដែលឃើញការកើតឡើង និងការប្រែប្រួលទៅរបស់រូបនិងនាម

**៥.ភង្គញ្ញាណ** បញ្ញាដែលពិចារណាឃើញការរលត់ទៅរបស់រូបនិងនាមដោយចំណែកមួយ

**៦.ភយញ្ញាណ** បញ្ញាដែលកំណត់ដឹងរូប និងនាមដោយសភាពគួរឲ្យខ្លាច

**៧.អាទីនវញ្ញាណ** បញ្ញាដែលឃើញសង្ខារ រូប និងនាម ជាទោស

**៨.និព្វិទាញ្ញាណ** បញ្ញាដែលឃើញរូប និងនាមដោយអាការៈគួរឲ្យនឿយណាយ

**៩.មុញ្ចិតុកម្យតាញ្ញាណ** បញ្ញាដែលមានសេចក្តីប្រាថ្នានឹងឲ្យរួចផុតពីរូប និងនាម

**១០.បដិសង្ខាញ្ញាណ** *បញ្ញាដែលថយត្រឡប់ទៅពិចារណាសង្ខារលើកឡើងកាន់ត្រៃលក្ខណ៍*

**១១.សង្ខារុបេក្ខាញ្ញាណ** *បញ្ញាដែលឃើញរូប និងនាមដោយអាការៈប្រងើយក្នុងសង្ខារនិមិត្តអារម្មណ៍*

**១២.អនុលោមញ្ញាណ** *បញ្ញាដែលអនុលោមទៅតាមលំដាប់ដើម្បីសម្រេចកិច្ច*

**១៣.គោត្រភូញ្ញាណ** *បញ្ញាដែលទម្លាយគោត្រ*

**១៤.មគ្គញ្ញាណ** *បញ្ញាក្នុងមគ្គ*

**១៥.ផលញ្ញាណ** *បញ្ញាក្នុងផល*

**១៦.បច្ចវេក្ខណញ្ញាណ** *បញ្ញាពិចារណាកិលេសដែលបានប្រហាររួចហើយ ។*

## បរិញ្ញា ៣

**១.ញាតបរិញ្ញា** *ការដឹងច្បាស់ ដោយកំណត់ដឹងសភាវលក្ខណៈ គឺលក្ខណៈពិសេសរបស់រូប និងនាម សំដៅដល់ នាមរូបបរិច្ឆេទញ្ញាណ និងបច្ចយបរិគ្គហញ្ញាណ ។*

**២.តីរណបរិញ្ញា** *ការដឹងច្បាស់ដោយការពិចារណា សាមញ្ញលក្ខណៈ គឺលក្ខណៈទូទៅ ដែលជាសភាពមិនទៀង ជាទុក្ខ មិនមែនតួខ្លួន សំដៅដល់ សម្មសនញ្ញាណ និងឧទយព្វយញ្ញាណ ។*

**៣.បហានបរិញ្ញា** *ការដឹងច្បាស់ដោយការលះនិច្ចសញ្ញាជាដើម សំដៅដល់ វិបស្សនាញាណតាំងតែភង្គញ្ញាណជាដើមទៅ ។*

**បហានៈ ៥ យ៉ាង**

*(ស្រង់ពីនេត្តិប្បករណ៍ ត្រង់សមារោបនហារៈ)*

**១.តទង្គប្បហានៈ** *លះកិលេសដោយហេតុនោះៗ ដោយទាន សីល និងវិបស្សនាដែលចាត់ជាកាមកុសល*

**២.វិក្ខម្ភនប្បហានៈ** *លះនីវរណៈដោយសង្កត់ទុកដោយកម្លាំងរបស់ឧបចារសមាធិ និងអប្បនាសមាធិ*

**៣.សមុច្ឆេទប្បហានៈ** *លះកិលេសដោយដាច់ខាតដោយលោកុត្តរៈ*

**៤.បដិបស្សទ្ធិបហានៈ** *លះកិលេសដោយស្ងប់រម្ងាប់ ដោយលោកុត្តរផល*

**៥.និស្សរណប្បហានៈ** *លះកិលេសដោយស្ងប់ចេញចាកសង្ខារ សំដៅដល់ ព្រះនិព្វាន ។*

## ចម្រើនសតិប្បដ្ឋាន ៤ ដោយអានាបានស្សតិភាវនា

*ការចម្រើនអានាបានស្សតិភាវនានេះ ចាត់ចូលក្នុងការចម្រើនសតិប្បដ្ឋាន ៤ ពោលគឺន័យពួកដំបូងតាមវិធីគណនា និងអនុពន្ធនាដែលពោលមកហើយ ជាការរលឹកដឹងកងរូបគឺខ្យល់ចូល ខ្យល់ចេញ ដែលរាប់ចូលក្នុងកាយានុបស្សនា គឺការតាមដឹងកងរូប ដូចព្រះពុទ្ធវចនៈថា*

កាយេសុ កាយញ្ញតរាហំ ភិក្ខវេ ឯវំ វទាមិ, យទិទំ អស្សាសបស្សាសា ។[១]

*ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ខ្យល់ចូល ខ្យល់ចេញជាកងរូបមួយ៉ាង (វាយោធាតុ) ក្នុងកងរូបទាំងឡាយ ។*

*ការរលឹកដឹងខ្យល់ចូលខ្យល់ចេញតាមន័យពួកទី ២ ចាត់ជាវេទនានុបស្សនា គឺការតាមដឹងវេទនា ព្រោះប្រាកដវេទនា គឺការដឹងបីតិជាដើមក្នុងខណៈទទួលដឹងខ្យល់ចូល ខ្យល់ចេញជាអារម្មណ៍ ដូចព្រះពុទ្ធវចនៈថា*

វេទនាសុ វេទនាញ្ញតរាហំ ភិក្ខវេ ឯវំ វទាមិ, យទិទំ អស្សាសបស្សាសានំ សាធុកំ មនសិការោ[២] ។

*ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការរលឹកដឹងខ្យល់ចូល និងខ្យល់ចេញដោយល្អ ជាវេទនាមួយ៉ាង ក្នុងវេទនាទាំងឡាយ ។*

*ពាក្យថា សាធុកំ (ដោយល្អ) គឺការញ៉ាំងបីតិជាដើមឲ្យកើតឡើង។*

---

[១] *មជ្ឈិម.ឧបរិ.២៦/៣៦៣ ។* [២] *មជ្ឈិម.ឧបរិ.២៦/៣៦៤ ។*

ការរលឹកដឹងខ្យល់ចូល ខ្យល់ចេញតាមន័យពួកទី ៣ ចាត់ជាចិត្តានុបស្សនា គឺការតាមដឹងចិត្ត ព្រោះចិត្តមានសភាវៈប្រាកដជាក់ច្បាស់ក្នុងខណៈទទួលដឹងខ្យល់ចូល ខ្យល់ចេញជាអារម្មណ៍ ដូចព្រះអដ្ឋកថាពោលថា យស្មា ចិត្តប្បដិសំវេទី អស្សសិស្សាមីតិអាទិនា នយេន បវត្តោ ភិក្ខុ កិញ្ចាបិ អស្សាសបស្សាសនិមិត្តំ អារម្មណំ ករោតិ, តស្ស បន ចិត្តស្ស អារម្មណេ សតិញ្ច សម្បជញ្ញញ្ច ឧបដ្ឋបេត្វា បវត្តនតោ ចិត្តេ ចិត្តានុបស្សីយេវ នាមេស ហោតិ ។ ន ហិ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតិភាវនា អត្ថិ ។ តស្មា អារម្មណតោ ចិត្តប្បដិសំវេទិតាទិវសេន ចិត្តេ ចិត្តានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ ។

ភិក្ខុអ្នកបដិបត្តិដោយន័យថា យើងនឹងញុំាងចិត្តឲ្យប្រចក្សច្បាស់កាលដកដង្ហើមចូលជាដើម សូម្បីទទួលយកខ្យល់ចូល ខ្យល់ចេញជាអារម្មណ៍ តែលោកបានឈ្មោះថា ជាអ្នកតាមដឹងក្នុងចិត្តថា ជាចិត្តដោយពិត ព្រោះតាំងសតិនិងសម្បជញ្ញៈក្នុងអារម្មណ៍របស់ចិត្តនោះ ។ សេចក្ដីពិត ការចម្រើនអានាបានស្សតិ រមែងមិនមានដល់អ្នកដែលវង្វេងសតិប្រាសចាកបញ្ញា ដូច្នោះ ភិក្ខុទើបជាអ្នកតាមដឹងក្នុងចិត្តថា ជាចិត្តដោយភាព ជាអ្នកញុំាងចិត្តឲ្យប្រចក្សដោយអារម្មណ៍ជាដើម ។

*ព្រះពុទ្ធទ្រង់បង្ហាញត្រង់ពួកទី ៣ថា*

នាហំ ភិក្ខវេ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតិំ វទាមិ[១] ។

*ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវអានាបានស្សតិរបស់ភិក្ខុដែលមិនមានសតិ មិនប្រកបដោយបញ្ញាដឹងសព្វទេ ។*

*ចំណែកការរលឹកដឹងខ្យល់ចូល ខ្យល់ចេញតាមន័យពួកទី ៤ ដែលចាត់ជាធម្មានុបស្សនាគឺការតាមដឹងសភាវធម៌ ព្រោះជាការកំណត់ដឹងភាពមិនទៀង របស់អភិជ្ឈានិងទោមនស្ស ។ ជាប់ទាក់ទងការកម្ចាត់អភិជ្ឈានិងទោមនស្ស ដែលប្រាកដច្បាស់ក្នុងខណៈនោះ ដូចសេចក្ដីក្នុងអានាបានស្សតិសូត្រនោះថា*

សោ យន្តំ អភិជ្ឈាទោមនស្សានំ បហានំ, តំ បញ្ញាយ ទិស្វា សាធុកំ អជ្ឈុបេក្ខិតា ហោតិ[២] ។

*ការលះបង់នូវអភិជ្ឈានិងទោមនស្សណា ភិក្ខុនោះ បានឃើញដោយបញ្ញា ហើយប្រងើយកន្ដើយដោយការលះបង់នោះ ។*

---

[១] *មជ្ឈិម.ឧបរិ.២៦/៣៦៥ ។*[២] *មជ្ឈិម.ឧបរិ.២៦/៣៦៦ ។*

*អដ្ឋកថាពន្យល់ថា*

យស្មា អនិច្ចានុបស្សី អស្សសិស្សាមីតិអាទិនា នយេន បវត្តោ ន កោវលំ នីវរណាទិធម្មេ, អភិជ្ឈាទោមនស្សសីលេន បន វុត្តានំ ធម្មានំ បហានញាណម្បិ បញ្ញាយ ទិស្វា អជ្ឈុបេក្ខិតា ហោតិ, តស្មា ធម្មេសុ ធម្មានុបស្សី តស្មិំ សមយេ ភិក្ខុ វិហរតីតិ វេទិតព្វោ ។

*ភិក្ខុអ្នកបដិបត្តិដោយន័យថា យើងតាមដឹងសេចក្តីមិនទៀង កាលដកដង្ហើមចូលជាដើម មិនត្រឹមប្រងើយចំពោះនីវរណធម៌ជាដើម តែនៅដឹងឃើញការកម្ចាត់នីវរណធម៌ ដែលពោលទុកដោយមានអភិជ្ឈានិងទោមនស្សជាគោល ដូច្នោះ គួរជ្រាបថា ភិក្ខុជាអ្នកតាមដឹងក្នុងសភាវធម៌ថា ជាសភាវធម៌ ។*

## ចម្រើនពោជ្ឈង្គៈ ៧ ដោយអានាបានស្សតិភាវនា

*ការចម្រើនអានាបានស្សតិភាវនានេះ ចាត់ជាការចម្រើនពោជ្ឈង្គៈ ៧ ដូច្នេះ៖*

**១.សតិសម្ពោជ្ឈង្គៈ:** *ការចម្រើនសតិជាប់បន្តក្នុងកងរូប ដែលជាសភាវធម៌ ដែលបន្ថែមច្រើនឡើងៗរាល់ថ្ងៃ ៗ។*

**២.ធម្មវិចយសម្ពោជ្ឈង្គៈ:** *ការឃើញសភាវធម៌ ដែលប្រាកដក្នុងខណៈតាមដឹងខ្យល់ ដែលបន្ថែមច្រើនឡើងៗរាល់ថ្ងៃ ៗ។*

**៣.វិរិយសម្ពោជ្ឈង្គៈ:** *សេចក្តីព្យាយាម ដែលបន្ថែមច្រើនឡើងៗ រាល់ថ្ងៃ ៗ។*

**៤.បីតិសម្ពោជ្ឈង្គៈ** សេចក្ដីរីករាយ ដែលបន្ថែមច្រើនឡើងៗរាល់ថ្ងៃ ៗ។

**៥.បស្សទ្ធិសម្ពោជ្ឈង្គៈ** សេចក្ដីស្ងប់ ដែលបន្ថែមច្រើនឡើងៗរាល់ថ្ងៃ ៗ។

**៦.សមាធិសម្ពោជ្ឈង្គៈ** សេចក្ដីតាំងមាំ ដែលបន្ថែមច្រើនឡើងៗរាល់ថ្ងៃ ៗ។

**៧.ឧបេក្ខាសម្ពោជ្ឈង្គៈ** សេចក្ដីប្រងើយកន្ដើយ ដែលបន្ថែមច្រើនឡើងៗរាល់ថ្ងៃ ៗ។

ព្រះបរមសាស្ដាត្រាស់ដឹងរឿងនេះថា

យស្មិំ សមយេ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា ។ សតិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ[១] ។

ភិក្ខុទ្រទ្រង់សតិទុក មិនវង្វេងក្នុងកាលណា លោកជាអ្នកប្រារព្ធសតិសម្ពោជ្ឈង្គៈ ក្នុងកាលនោះ ។

សម្បីពោជ្ឈង្គៈដទៃៗ ក៏ព្រះអង្គត្រាស់ទុកដោយន័យដូចគ្នា ។

[១] មជ្ឈិម.ឧបរិ.២៦/៣៦៧ ។

## សាសនព្រហ្មចរិយៈ

ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀតសាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសំដែងហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេពចម្រើន ធ្វើរឿយៗ ដោយប្រការដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀតសាសនព្រហ្មចរិយៈនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណាដែលតថាគតសំដែងហើយដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃហើយសេពចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះធម៌ទាំងឡាយនោះតើដូចម្តេច ។ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍

ដល់ជនច្រើន ដើម្បីសេចក្ដីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសំដែងហើយដោយបញ្ញាដ៏ឧត្ដម អ្នកទាំងឡាយគប្បីរៀន ដោយប្រពៃ ហើយសេពចម្រើន ធ្វើឲ្យរឿយ ៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។

៩៨ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះដ៏ស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តម្កល់សតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។*



ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទៈ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែលៈ maha.panna@gmail.com

គេហទំព័រៈ http://www.mahapanna.org

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~